សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royal de droit et des sciences Economiquse
Royal University of Low and Economics

# សារណាបញ្ចប់ការសិក្សា

# ការផ្តល់សេវាសុខាភិបាលក្នុងបរិបទកូវីដ-១៩ នៅកម្ពុជា

## ( ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ )

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា គ្រឿង រចនី**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ ព្រឿង រចនី ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ឆ្នាំទី០៤ ជំនាន់ទី១៥ ក្រុម P4C6 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០២១ ២០២២។ អស់រយៈពេល ១ឆ្នាំនាងខ្ញុំបានបំពេញការសិក្សាអស់រយៈពេលមួយឆ្នាំ នៅវិទ្យាស្ថានជាតិសង្គមកិច្ច និងរយៈពេល ៣ឆ្នាំទៀតនាងខ្ញុំបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចាប់យកជំនាញសិក្សាលើមុខវិជ្ជា រដ្ឋបាលសាធារណៈ។ ក្នុងរយៈពេល ៤ឆ្នាំកន្លងមកនេះនាងខ្ញុំបានឆ្លងកាត់នូវការខិតខំប្រឹងប្រែងក្រេបយកចំណេះដឹង ដើម្បីសិក្សារៀនសូត្រពីសាស្ត្រាចារ្យដែលជាថ្នាល់បណ្ដុះបណ្ដាលនៅសាលានូវចំណេះដឹង និងបទពិសោធន៍ ដោយសារការខិតខំប្រឹងប្រែងមួយនេះបានធ្វើអោយនាងខ្ញុំមានឱកាសទទួលបាននូវលទ្ធផលល្អប្រសើរ និងទទួលបានឱកាសសរសេរសារណាបញ្ចប់ការសិក្សាដើម្បីចងក្រងជាស្នាដៃទុកសម្រាប់សិស្សនិស្សិតនូវជំនាញក្រោយជាឯកសារស្រាជ្រាវ។ តាមរយៈលទ្ធផលវិជ្ជាមាននេះនាងខ្ញុំសូមធ្វើការថ្លែងអំណរអរគុណ និងសម្ដែងនូវកញ្ញតាធម៌ការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកតា សាយ ព្រឿង និងលោកយាយ ប៉ុន សារឹម និងអ្នកម្ដាយ ព្រឿង សារឿន និងបងប្រុស ព្រឿង រចនា ដែលជាអ្នកមានគុណដល់ថ្លៃថ្លាមិនអាចកាត់ថ្លៃបាន លោកបានពុះពារគ្រប់ឧបសគ្គចិញ្ចឹមបីបាច់រក្សាផ្ដល់ភាពកក់ក្ដៅ និងផ្ដល់ការអប់រំ ជាពិសេសជាអ្នកប្រឹក្សាយោបល់រាល់គ្រប់កាលៈទេសៈរហូតមកបានធ្វើអោយខ្ញុំក្លាយជាយុវជនម្នាក់ដែលពោរពេញដោយសក្ដានុពលនៅក្នុងសង្គមនេះ។ គុណដែលថ្លៃថ្លារបស់អ្នកមានគុណទាំងអស់ កូនចៅនិងធ្វើការតបស្នងអោយអស់ពីកម្លាំងកាយចិត្ត នឹងប្ដេជ្ញាចិត្តថានិងធ្វើតែអំពើល្អ និងយកចំណេះដឹង បទពិសោធន៍ទៅជួយអភិវឌ្ឍសង្គមជាតិអោយរីកចម្រើនទៅមុខ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យ ដែលបានយកចិត្តទុកដាក់ក្នុងការផ្ដល់គុណភាពសិក្សាជូនសិស្សនិស្សិតគ្រប់រូប ក្នុងការបានយល់ពីទ្រឹស្ដី និងការអនុវត្តជាក់ស្ដែងផងដែរ។

នាងខ្ញុំសូមធ្វើការថ្លៃអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យបណ្ឌិត សឿន សោភ័ណ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីផ្ដល់ការណែនាំ និងផ្ដល់ជាគន្លិះបំពេញនូវរាល់ចំណុចខ្វះខាតរបស់នាងក្នុងស្រាវជ្រាវ និងរៀបចំសរសេរសារណា ដោយពុំក្លាយនឿយហត់។

ជាចុងក្រោយនាងខ្ញុំសូមគោរពប្រសិទ្ធពរជ័យ ដល់លោកអ្នកមានគុណ លោកឯកត្តម លោកជំទាវ ដែលជាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកដែលបម្រើការនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អោយជួបតែសេចក្ដីសុខ សុភមង្គល ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និងចាកឆ្ងាយផុតពីជំងឺកូវីដ-១៩។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សានៅថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ អស់រយៈពេលប្រមាណជាង ៣ឆ្នាំនៃឆ្នាំសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចជំណាន់ទី១៥ ក្រុម P4C6 នាងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ការងារជាច្រើនទាំងក្នុងមុខជំនាញនៅក្នុងសាលា និងបរិយាកាសបទពិសោធន៍ការងារនៅក្នុងសង្គមជាក់ស្តែង។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ និងការខិតខំប្រឹងប្រែងរៀនសូត្យជាពិសេសនៅក្នុងការសិក្សានៅក្នុងបរិបទកូវីដ-១៩ គឺការសិក្សាតាមប្រព័ន្ធឌីជីថល បានធ្វើអោយនាងខ្ញុំទទួលបានលទ្ធផលល្អ និងទទួលបានឱកាសក្នុងជ្រើសរើសប្រធានបទនៃកិច្ចការស្រាវ ឬសារណា។

វិបត្តិកូវីដ-១៩ ត្រូវបានគេចាត់ទុកជាវិបត្តិសកលមួយដែលលើបណ្តាលប្រទេសផ្សេងៗទៀតក៏បានរងគ្រោះដោយសារវិបត្តិនេះដែរ ជាពិសេសគឺបានជះឥទ្ធិពលលើសេដ្ឋកិច្ចសង្គម។ ដោយឡែកប្រទេសកម្ពុជាក៏បានជួបប្រទះនូវវិបត្តិកូវីដ-១៩ នេះផងដែរ។ ដោយសារតែវិបត្តិកូវីដ-១៩ ជាវិបត្តិដែលកើតមានចំពោះសុខភាពរស់នៅរបស់សាធារណៈជន ដែលពាក់ព័ន្ធជាមួយវិស័យសុខាភិបាលដែលមានតួនាទីភារកិច្ចយ៉ាងសកម្មក្នុងការជួយក្នុងការទប់ស្កាត់ ក្នុងការព្យាបាល ក្នុងថែទាំ និងតាមដានពិនិត្យ ដើម្បីជួយសង្រ្គោះសាធារណជនអោយឆ្លងផុតវិបត្តិនៃអាសន្នមួយនេះ ក្រៅពីនេះចូលរួមក្នុងការកាត់បន្ថយឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច សង្គមពីបណ្តាលប្រទេសក្នុង និងក្រៅតំបន់។

ដោយសារឆ្លងកាត់ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធនានា បានធ្វើអោយកម្ពុជាអាចបន្សាំខ្លួនរស់នៅជាមួយជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរទោះបីជាសេដ្ឋកិច្ចសង្គមជួនប្រទះនូវវិបត្តិក្តី តែការផ្តល់សេវាសុខាភិបាលកម្ពុជាបានផ្តល់អោយសាធារណជននូវប្រសិទ្ធភាព និងគុណភាព គឺការព្យាបាលជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃ និងការផ្តល់វ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋគ្រប់រូបក្នុងដែលសមត្ថកិច្ចរបស់កម្ពុជា។ ហេតុដោយយល់ឃើញថា ការផ្តល់សេវាសុខាភិបាលក៏ជាវិស័យអាទិភាពមួយក្នុងចង្កូតវិស័យរបស់កម្ពុជា និងជាក្របខណ្ឌកញ្ចប់នៃសេវារដ្ឋបាលផងដែលនោះ ទើបនាងខ្ញុំបានសម្រេចចិត្តធ្វើការស្រាវជ្រាវលើប្រធានបទស្តីពី **ការផ្តល់សេវាសុខាភិបាលនៅក្នុងបរិបទកូវីដ-១៩ នៅកម្ពុជា (ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១)** ដើម្បីចង់ក្រងជាស្នាដៃទុកសម្រាប់សិស្សនិស្សិតជំនាន់ក្រោយ។

តាមរយៈការជ្រើសរើសប្រធានបទមួយនេះ មកសិក្សា នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទមួយនេះនឹងក្លាយជាកម្រងឯកសារមួយទុកសម្រាប់សិស្សនិស្សិតជំនាន់ក្រោយបានសិក្សា និងស្វែងយល់ពីស្ថានភាពរបស់ក្រសួងសុខាភិបាល និងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-១៩ និងការផ្តល់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋអោយឥតមានគិតថ្លៃ។

ទោះជាយ៉ាងណាក៏ដោយ នាងខ្ញុំក៏សូមធ្វើការខន្តី និងអភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជាពាក្យពេចន៍ អត្ថន័យ និងកំហុសឆ្គងផ្សេងៗដោយអចេតនាណាមួយដែលមាននៅក្នុងសារណាមួយក្បាលនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលល្អឥតខ្ចោះនោះទេ។ ហេតុដូចនេះហើយនាងខ្ញុំតែងតែទទួលស្គាល់នូវរាល់កំហុស និងទទួលនូវរាល់ការរិះគន់ដើម្បីភាពស្ថាបនាពីមិត្តអ្នកអាន។

# មាតិកា

**សេចក្តីផ្តើម** ........ 1
១. លំនាំបញ្ហានៃកិច្ចការស្រាវជ្រាវ ........ 1
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 2
៣. គោលបំណងនៃការស្រាវជ្រាវ ........ 3
៤. ដែលកំណត់នៃការស្រាវជ្រាវ ........ 3
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 3
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 3
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 4

## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃជំងឺកូវីដ-១៩

**១.១ សាវតា និងកំណែទម្រង់វិស័យសុខាភិបាលកម្ពុជា** ........ 5
១.១.១ កំណែទម្រង់វិស័យសុខាភិបាលកម្ពុជា ........ 5
១.១.២ ផែនការគ្រប់ដណ្តប់សុខាភិបាល ........ 6
១.១.៣ ប្រព័ន្ធផ្តល់សេវាសុខាភិបាល ........ 6
១.១.៤ គោលដៅយុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាល ........ 7
**១.២ សាវតាជំងឺកូវីដ-១៩** ........ 8
១.២.១ និយមន័យ ........ 8
១.២.២ ការចម្លងជំងឺកូវីដ-១៩ ........ 9
១.២.៣ លក្ខណៈគ្លីនិកនៃជំងឺ ........ 9
**១.៣ កម្រិតនៃស្ថានភាពជំងឺកូវីដ-១៩** ........ 10
១.៣.១ កម្រិតស្រាល ........ 10
១.៣.២ កម្រិតមធ្យម ........ 11
១.៣.៣ កម្រិតធ្ងន់ធ្ងរ ........ 11
១.៣.៤ កម្រិតសង្គ្រោះបន្ទាន់ ........ 11

## ជំពូកទី២

## តួនាទីភារកិច្ចក្នុងការបង្ការ ការពារនិងព្យាបាលរបស់ក្រសួងសុខាភិបាល

**២.១. តួនាទីភារកិច្ចរបស់ក្រសួងសុខាភិបាល**......12

**២.២ មគ្គុទេសក៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩** ......13

២.២.១ ការវិភាគ និងការធ្វើរោគវិនិច្ឆ័យ......13

២.២.២ ការថែទាំ ព្យាបាលអ្នកជំងឺ......14

២.២.៣ ការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ ......16

២.២.៤ ការបូជាសព......17

២.២.៥ ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ ......19

**២.៣ ការគ្រប់គ្រង និងការវាយតម្លៃពីហានិភ័យរបស់បុគ្គលិកថែទាំសុខភាព**......19

**២.៤ ការធ្វើចត្តាឡីស័ក**......20

**២.៥ ការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩** ......21

២.៥.១. ទិដ្ឋភាពទូទៅនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ......21

២.៥.២. លក្ខខណ្ឌនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ......21

២.៥.៣. គោលការណ៍នៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ......23

២.៥.៤. យន្តការបន្ទាប់ពីការទទួលបានលទ្ធផលនៃការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ......26

**២.៦. ស្ថានភាពអ្នកឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា**......26

**២.៧ ការចាក់វ៉ាក់សាំង** ......29

**២.៨ ចំនួនអ្នកចាក់វ៉ាក់សាំងសរុប គិតត្រឹមឆ្នាំ ២០២១**......36

## ជំពូកទី៣

## របកគំហើញនៃការស្រាវជ្រាវ

**៣.១ ផលប៉ះពាល់លើប្រព័ន្ធសុខាភិបាល** ......38

**៣.២ វិធានការដោះស្រាយផលប៉ះពាល់លើប្រព័ន្ធសុខាភិបាល** ......40

៣.២.១ ការពង្រឹង និងពង្រីក សេវាសុខាភិបាល......40

៣.២.២ ចំណុចយុទ្ធសាស្ត្រអាទិភាពនៃសេវា......41

៣.២.៣ គម្រោងនៃការឆ្លើយតបរបស់ក្រសួងសុខាភិបាល ......42

៣.៣ ផលប៉ះពាល់ចំពោះសេដ្ឋកិច្ច-សង្គម ....................................................................................46
៣.៤ វិធានការដោះស្រាយផលប៉ះពាល់ចំពោះសេដ្ឋកិច្ច-សង្គម....................................................47
សេចក្តីសន្និដ្ឋាន .......................................................................................................................51
អនុសាសន៍.................................................................................................................................53
គន្ថនិទេស
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃកិច្ចការស្រាវជ្រាវ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្ដេចអគ្គមហាសេនាបតិតេជោ ហ៊ុន សែន បានកំណត់ច្បាស់លាស់ពីរបៀបវារៈនៃគោលនយោបាយសេដ្ឋកិច្ចសង្គមបានកំណត់យក វិស័យសុខាភិបាលជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យជាច្រើននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺដើម្បីធានាដល់សុខមាភាពជូនសាធារណៈជនទូទៅក្នុងការការពារ បង្ការ ព្យាបាល និងថែទាំសុខភាព។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកអនុវត្ត និងអ្នកប្រើប្រាស់ក្រសួងសាមី និងក្រសួងពាក់ព័ន្ធនានាបានព្យាយាមយកចិត្តដាក់ក្នុងការដាក់ចេញនូវជាគោលនយោបាយ យុទ្ធសាស្ត្រ និងធ្វើការកែទម្រង់នៃការផ្ដល់សេវាសុខភិបាលពីមួយឆ្នាំទៅមួយឆ្នាំក្នុងគោលបំណងធ្វើអោយកាន់តែប្រសើរឡើង និងឆ្លើយតបជាវិជ្ជមាន។ ជាពិសេសនៅក្នុងបរិបទកូវីដ-១៩ជាទឡ្ហីករណ៍ក្នុងការបង្ហាញអោយឃើញពីការយកចិត្តទុកក្នុងការបំពេញកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល និងក្រសួងសាមីក្នុងការស្តារភាពអាសន្នមួយនេះ។ វិបត្តិកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ច សង្គមនៅបណ្ដាលប្រទេសជាច្រើនលើពិភពលោក ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។

នៅខែមីនា ឆ្នាំ២០២០ កម្ពុជាមានការចាប់ផ្ដើមផ្ទុះឡើងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ហើយក៏នៅតាមបណ្ដាលប្រទេសជុំវិញសកលលោកនៅពុំទាន់យល់ច្បាស់ពីជំងឺកូវីដ-១៩ និងអំពីវិធីសាស្ត្រក្នុងការព្យាបាល មិនទាន់មានវ៉ាក់សាំងបង្ការ និងឱសថសម្រាប់ព្យាបាលជំងឺនេះ ព្រមទាំងមានការខ្វះខាតសម្ភារៈការពារផ្សេងៗដូចជា ម៉ាស និងអាល់កុលជាដើម។ នៅក្នុងដំណាក់កាលនោះ ដើម្បីជាមធ្យោបាយក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលក្នុងសហគមន៍ រាជរដ្ឋាភិបាលបានចេញនូវវិធានការដោយផ្ដោតលើ ការរឹតបន្តឹងនៅតាមច្រកទ្វារព្រំដែន ដូចជាការបិទជើងហោះហើរពីបណ្ដាលប្រទេសមួយចំនួន ការបិទច្រកចេញចូលជាមួយប្រទេសជិតខាង ការតម្រូវអោយធ្វើចត្តាឡីស័ក ការធ្វើតេស្តរកជំងឺកូវីដ-១៩ និងការទប់ស្កាត់ការចម្លងចូលក្នុងសហគមន៍ផ្ទៃក្នុងប្រទេសតាមរយៈការរុករក ការធ្វើតេស្ត ការធ្វើចត្តាឡីស័កអ្នកពាក់ព័ន្ធផ្ទាល់ និងប្រយោល ការបិទទីតាំងប៉ះពាល់ផ្ទាល់ និងការពង្រឹងសមត្ថភាពព្យាបាលរបស់ក្រុមមន្ត្រីសុខាភិបាល។

ជាលទ្ធផល ការដាក់ចេញនូវវិធានការយុទ្ធសាស្ត្រយ៉ាងតឹងរ៉ឹងនេះបានធ្វើអោយកម្ពុជាទប់ស្កាត់បានមិនអោយមានការនាំចូលនូវមេរោគកូវីដ-១៩ ពីបរទេស បានជួយបញ្ចៀសនូវការឆ្លងរាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩ បានរយៈពេលមួយឆ្នាំ និងបានធ្វើអោយកម្ពុជាទទួលបានកេរ៍ឈ្មោះល្អលើការប្រយុទ្ធ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ។

ក្រោយពីរក្សាបាននូវសុវត្ថិភាពពីជំងឺឆ្លង នៅថ្ងៃទី ៣ វិច្ឆកា ឆ្នាំ ២០២០ កម្ពុជាបានប្រទះនូវការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ជាលើដំបូង ដែលបានបង្កភាពអាក់អួលដល់ដំណើរការការងាររបស់រាជ

រដ្ឋាភិបាល ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការមួយចំនួនត្រូវបានធ្វើចត្តាឡីស័ក ក្រោយពីមានការទាក់ទងផ្ទាល់ និងប្រយោលជាមួយគណៈប្រតិភូជាន់ខ្ពស់នៃក្រសួងការបរទេសហុងគ្រី។

នៅថ្ងៃទី ២៨ វិច្ឆិការ ២០២០ កម្ពុជាបានជួបប្រទះនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ជា **រលកទី១** ដែលបានកើតចេញពីប្រភពផ្សេងមួយទៀត និងបានប៉ះពាល់ដល់ប្រជាជនទូទៅជាពិសេស នៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប។ ដូចនេះដើម្បីទប់ស្កាត់ និងគ្រប់គ្រងអោយបាននៃការរីករាលដាលនៃរលកទី១ នេះ រាជរដ្ឋាភិបាល និងក្រសួងសាមីបានជំរុញអោយមានការអនុវត្តនូវវិធានការ ៣-ធី (3-Ts) ពោលគឺ ការធ្វើតេស្ត (Testing) ការរុករក(Tracking) និងការព្យាបាល (Treatment) ដែលជាតួនាទីភារកិច្ចរបស់ក្រសួងសុខាភិបាល និងការគួបផ្សំជាមួយនឹងការរឹតត្បិតលើការធ្វើដំណើរ ការបិទទីតាំងដែលមានអ្នកកជំងឺកូវីដ-១៩ ចូលនិងតម្រូវអោយអ្នកប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ ទាំងអស់ធ្វើចត្តាឡីស័ក។ តាមរយៈការដាក់ចេញនូវវិធានការនេះ នៅថ្ងៃទី ២៩ ធ្នូ ២០២០ ព្រឹត្តិការណ៍រលកទី១ នេះត្រូវបានបិទបញ្ចប់ដោយរកឃើញអ្នកជំងឺកូវីដ-១៩ ចំនួន ៤១នាក់ និងពុំមានអ្នកបាត់បង់ជីវិតដោយសារជំងឺកូវីដ-១៩ ឡើយ។

នៅថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ២០២១ រាជរដ្ឋាភិបាលបានសម្រេចចិត្តក្នុងការបើក យុទ្ធនាការចាប់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជំហានទី១ ជូនដល់អ្នកបម្រើសេវាជួរមុខ ក្នុងក្របខណ្ឌទូទាំងប្រទេស (ដូចជា បុគ្គលិកសុខាភិបាល កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីសាធារណៈ)។ ទន្ទឹមជាមួយនឹងដំណើរការនៃ យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នេះ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០២១ មានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំ ដែលទុកជា **រលកទី២**។ ការឆ្លងរាលដាលនូវរលកទី២ នេះបានធ្វើអោយកម្ពុជាជួបនូវបញ្ហាប្រឈមធ្ងន់ធ្ងរលើសេដ្ឋកិច្ច សង្គម ប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ សកម្មភាពអាជីវកម្ម ពាណិជ្ជកម្ម សេដ្ឋកិច្ច និងជាពិសេសនោះ ព្រឹត្តិការណ៍នេះបានធ្វើអោយតួនាទីភារកិច្ចរបស់ក្រសួងសុខាភិបាលទទួលសុខត្រូវក្នុងផ្នែកមួយខ្ពស់ចំពោះសុខភាពសាធារណៈ។

ដូចនេះដើម្បីជាត្រីវិស័យក្នុងការរៀបរាប់ពីព្រឹត្តិការណ៍ ២០ កុម្ភៈ និងតួនាទីភារកិច្ចរបស់ក្រសួងសុខាភិបាល ជាអ្នកបានឆ្លងកាត់នូវព្រឹត្តិការណ៍ជាមួយប្រជាជនទូទាំងប្រទេស បានសម្រេចដកស្រង់ លើកឡើងនូវប្រធានបទស្តីពី **ការផ្តល់សេវាសុខាភិបាលក្នុងបរិបទកូវីដ-១៩ នៅកម្ពុជា** នេះឡើយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាត្រីវិស័យនាំទៅដល់ការបកស្រាយប្រធានបទអោយកាន់តែស៊ីជម្រៅ ដូច្នេះបានដាក់ចេញនូវចំណោទបញ្ហាសំខាន់ៗចំនួន៣ គឺ៖

1. តើក្រសួងសុខាភិបាលមានទំនួលខុសត្រូវដូចម្តេចខ្លះលើប្រជាជនក្នុងស្ថានភាពវិបត្តិកូវីដ-១៩ នេះ?
2. ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានាចំពោះសុខភាពសាធារណៈ តើក្រសួងសុខាភិបាលមានដំណោះស្រាយដូចម្តេចខ្លះ?

3. តើវិបត្តិកូវីដ-១៩ បានផ្តល់ផលប៉ះពាល់អ្វីខ្លះ ដល់វិស័យសុខាភិបាល និងសង្គម-សេដ្ឋកិច្ចកម្ពុជាដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងវាស់វែងអំពីសូចនាករនៃការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល និងយុទ្ធសាស្ត្ររាជរដ្ឋាភិបាលក្នុងការឆ្លើយតបជាមួយនឹងវិបត្តិនៃជំងឺដល់ធ្ងន់ធ្ងរមួយនេះ និងម៉្យាងទៀតនោះក្រោមប្រធានបទមួយនេះអាចក្លាយជាកត្តាមួយជំរុញអោយមានស្មារតីក្នុងការបណ្តុះនូវពុទ្ធិអោយយុវជនជំនាន់ក្រោយបានស្វែងយល់ និងបានទទួលបទពិសោធន៍ពីការឆ្លងកាត់នូវទុកលំបាកមួយនេះផងដែរ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ថ្វីត្បិតតែបញ្ហានៃការរីករាលដាលនៃជំងឺឆ្លងកូវីដ ១៩ បានជះផលប៉ះពាល់ពេញពិភពលោកក៏ពិតមែន តែក្នុងប្រធានបទដែលនាងខ្ញុំបានលើឡើងខាងលើនេះ នឹងលើឡើងតែពីការរីវដ្តនៃជំងឺឆ្លង និងការផ្តល់សេវាសុខាភិបាលក្នុងរង្វាង់ដែនសមត្ថកិច្ចរបស់កម្ពុជាតែប៉ុន្នោះ បើគិតជាឆ្នាំគឺត្រឹមឆ្នាំ ២០២០ ដល់២០២១ តែប៉ុណ្ណោះ។

## ៥. សារសំខាន់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវក្រោមប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ណាស់ព្រោះ បរិបទកូវីដ-១៩ ជាបរិបទនៃគ្រោះអាសន្នមួយដែលកើតមាននៅក្នុងបណ្តាលប្រទេសលើទូទាំងពិភពលោក ហើយក្នុងនោះតួនាទីរបស់ក្រសួងសុខាភិបាលគឺពិតជាមានភាពចាំបាច់ខ្លាំងណាស់ក្នុងការគ្រប់គ្រង និងជួយរាជរដ្ឋាភិបាលក្នុងការស្តារប្រទេសជាតិអោយបានធូរស្រាលពីវិបត្តិផ្សេងៗ ដែលអាចកើតមាននៅកំឡុងពេលវិបត្តិនេះ។ ជាក់ស្តែងប្រទេសកម្ពុជា បានធ្វើការងារយ៉ាងសកម្មក្នុងជួយទ្រទ្រង់សកម្មភាពរបស់ក្រសួងសុខាភិបាលក្នុងការចូលរួមទប់ស្កាត់ ការព្យាបាលដើម្បីរួមគ្នាក្នុងការទប់ឌីនភាពនៃសេដ្ឋកិច្ចសង្គមជាតិ និងការគ្រប់គ្រងស្ថានភាពសុខភាពសាធារណៈរបស់ប្រជាជនកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដោយកំឡុងពេលសិក្សាប្រធានបទមួយនេះ ប្រទេសកម្ពុជានូវមិនទាន់មានសុខសុវត្ថិភាពពីការរាលដាលនូវជំងឺឆ្លងនូវឡើង ហេតុនេះវាជាឧបសគ្គមួយសម្រាប់ការចុះទៅប្រមូលទិន្នន័យចម្បង ពីសំណាក់ភាគីពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ច។ តែទោះជាយ៉ាងណាក៏ដោយ ក៏ទិន្នន័យបន្ទាប់បន្សំ ក្លាយជាទិន្នន័យចម្បងដែលក្តោបបាននូវក្លឹបសារទាំងមូល ព្រោះដោយឆ្លងកាត់តាមដំណាក់ការនៃវិបត្តិនេះ ប្រព័ន្ធផ្សព្វបានក្លាយជាចំណុចចាប់ក្នុងការរស់នៅក្នុងបរិបទមួយថ្មី ដែលទន្និន័យលើប្រព័ន្ធផ្សព្វផ្សាយមានភាគរយអាចទុកចិត្តបាន ជាពិសេសនោះទន្និន័យដែលចេញផ្សាយដោយក្រសួងសុខាភិបាលផ្ទាល់។

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

សេចក្តីថ្លែងអំណរគុណ

អារម្ភកថា

សេចក្តីផ្តើម

ជំពូកទី១ ជំពូកទី១ ទិដ្ឋភាពទូទៅនៃជំងឺកូវីដ-១៩

ជំពូកទី២ តួនាទីភារកិច្ចក្នុងការបង្ការ ការពារនិងព្យាបាលរបស់ក្រសួងសុខាភិបាល

ជំពូកទី៣ របកគំហើញនៃការស្រាវជ្រាវ

សេចក្តីសន្និដ្ឋាន

អនុសាសន៍

គន្ថនិទេស

ឧបសម្ព័ន្ធ

# ជំពូកទី១

# និន្នាការទូទៅនៃ

# ជំងឺកូវីដ-១៩

# ជំពូកទី១

# ស្ថានភាពទូទៅនៃជំងឺកូវីដ-១៩

## ១.១ សាវតា និងកំណែទម្រង់វិស័យសុខាភិបាលកម្ពុជា

វិស័យសុខាភិបាលកម្ពុជា ជាវិស័យដែលមួយដែលជួយលើកស្ទួយស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា ដោយគ្មានការរើសអើង។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលបាលកម្ពុជា បានកំណត់ច្បាស់លាស់ពីរបៀបវារៈនៃគោលការនៃគោលនយោបាយសេដ្ឋកិច្ចសង្គម ដើម្បីពង្រឹងការអភិវឌ្ឍបានចាត់ទុកការលើស្ទួយស្ថានភាពសុខាភិបាលប្រជាពលរដ្ឋគ្រប់រូប ជាចំណុចអាទិភាពមួយក្នុងការវិនិយោគធនធានក្នុងវិស័យសង្គម។ ក្រសួងសុខាភិបាល ជាក្រសួងដែលមានសម្ថតកិច្ចក្នុងការផ្តត់ផ្គង់សេវាសុខាភិបាល និងបានកំពុងបន្តពង្រឹង និងពង្រឹងប្រតិបត្តិការនៃប្រពន្ធសុខាភិបាលអោយកាន់តែមានប្រសិទ្ធភាព គុណភាព សក្តិសិទ្ធភាព និងសមធម៌។

### ១.១.១ កំណែទម្រង់វិស័យសុខាភិបាលកម្ពុជា

ការធ្វើកំណែទម្រង់វិស័យសុខាភិបាល ក្នុងគោលបំណងពង្រឹងការគ្រប់ដណ្តប់នៃការផ្តល់សេវាសុខភាពតាមរយៈអន្តរាគមន៍នៃកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថមលើស្រ្តីនិងកុមារ កម្មវិធីប្រយុទ្ធនិងជំងឺឆ្លង ជំងឺឆ្លងមិនរាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ។ អន្តរាគមន៍សុខភាពសាធារណៈបានដើរទង្ហឹមគ្នានឹងការកែលម្អគុណភាពសេវាបង្ការ ពិនិត្យ ព្យាបាល និងថែទាំងអោយកាន់តែប្រសើរឡើង។ សមធម៌ក្នុងការមកទទួលបានសេវាសុខភាព និងក្នុងហិរញ្ញប្បទានសុខាភិបាលត្រូវបានលើកស្ទួយជាបន្តបន្ទាប់ តាមរយៈការគ្រប់ដណ្តប់នៃមូលនីធិសមធម៌នៅទូទាំងប្រទេសកម្ពុជាតាំងពីដំណាច់ឆ្នាំ ២០១៥ ដែលបានផ្តល់មូលនីធិដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ រួមជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកលែងការបង់ថ្លៃសេវា បានដករបាំងឧបសគ្គភូមិសាស្រ្តផង និងរបាំងឧបសគ្គហិរញ្ញវត្ថុផង ពោលគឺផ្តល់ការបង្ការហានិភ័យហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ អោយមកប្រើប្រាស់សេវាសុខភាព នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដោយគ្មានការបង់ថ្លៃ នៅពេលមានបញ្ហាសុខភាព។

ការផ្តល់សេវាសុខាភិបាលដែលមានគុណភាព ប្រសិទ្ធភាព និងសមធម៌ ជាផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ ដែលមានលក្ខណៈពិសេសគឺ

- ការប្តេជ្ញាចិត្តក្នុងការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋដោយដើរតាមមគ្គុទេសដែលបានសរសេរនៅក្នុងផែនការយុទ្ធសាស្ត្រ
- ការលើកកម្ពស់សុខភាព និងសុខមាលភាពប្រជាពលរដ្ឋ តាមរយៈស្នាដៃរឹងមាំនៃក្រសួងសុខាភិបាល និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ការកែលម្អកត្តាសង្គមដែលមានផលប៉ះពាល់លើសុខភាព ជាពិសេសកំណើនសេដ្ឋកិច្ច និងការធ្លាក់ចុះនៃភាពក្រីក្រ

- ការបង្ការហានិភ័យហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋក្រីក្រអោយបានចូលមកប្រើប្រាស់សេវាសុខាភិបាលសាធារណៈ តាមរយៈការពង្រីកមូលនីធិសមធម៌ រួមជាមួយអន្តរាគមន៍ហិរញ្ញប្បទានផ្សេងៗទៀត
- ការបង្កើនការផ្តល់សេវាសាធារណៈ ដោយផ្តោតលើលទ្ធភាពនៃការផ្តល់សេវា និងការគ្រប់ដណ្តប់ គុណភាពសេវា ប្រសិទ្ធភាព និងសមធម៌
- ការលើកកម្ពស់អភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាលទាំងមូល។

កំណែទម្រង់វិស័យសុខាភិបាលបាននាំមកនូវការផ្លាស់ប្តូរពី **ការរៀបចំប្រព័ន្ធសុខាភិបាល ឈរលើរចនាសម្ព័ន្ធរដ្ឋបាល ទៅរកប្រព័ន្ធសុខាភិបាលផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនប្រជាជន និងលទ្ធភាពមកទទួលយកសេវាសុខភាព។** ជាលទ្ធផល ប្រព័ន្ធសុខាភិបាលកម្ពុជាបច្ចុប្បន្ន ត្រូវបានរៀបចំជា ៣ថ្នាក់ គឺមានថ្នាក់កណ្តាល ថ្នាក់រាជធានីខេត្ត និងថ្នាក់ស្រុក។

### ១.១.២ ផែនការគ្រប់ដណ្តប់សុខាភិបាល

ផែនការគ្រប់ដណ្តប់សុខាភិបាលគឺជាក្របខណ្ឌ័សម្រាប់អភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យពីររួមគ្នា **ចំនួនប្រជាជន និងលទ្ធភាពទទួលសេវាសុខភាព** ព្រមទាំងគិតគូរហ្មត់ចត់អំពីគុណភាពនៃការថែទាំ និងធនធានដែលមានក្នុងគោលបំណងដើម្បីៈ

- អភិវឌ្ឍសេវាសុខាភាព ដោយកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ទីតាំង និងតំបន់ទទួលខុសត្រូវរបស់មូលដ្ឋានសុខាភិបាល
- បែងចែកធនធានហិរញ្ញវត្ថុ និងធនធានមនុស្សប្រកបដោយសមធម៌ ព្រមទាំងលើកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងអស់នោះ
- ធានាថាសេចក្តីត្រូវការផ្នែកសុខភាព របស់ប្រជាពលរដ្ឋត្រូវបានឆ្លើយតបប្រកបដោយសមធម៌ តាមរយៈការគ្រប់ដណ្តប់នៃសេវាសុខភាពលើប្រជាពលរដ្ឋទាំងអស់

### ១.១.៣ ប្រព័ន្ធផ្តល់សេវាសុខាភិបាល

ក្រសួងសុខាភិបាលបាននឹងកំពុងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ នូវអភិក្រមសមាហរណកម្មនៃការផ្តល់សេវាសុខាភិបាល រួមមាន សេវាបង្ការ អប់រំលើកកម្ពស់សុខភាព ការធ្វើរោគវិនិច្ឆ័យ ព្យាបាល និងថែទាំជំងឺ និងស្តារនិតិសម្បទា តាមរយៈការផ្តល់សេវាមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព នៅតាមមូលដ្ឋានសុខាភិបាល ពង្រឹងប្រព័ន្ធបញ្ជូនអ្នកជំងឺ និងការចុះផ្តល់សេវាតាមភូមិ ឃុំ ជាពិសេសនៅតាមតំបន់ជនបទ ដែលមានប្រជាពលរដ្ឋពិបាកក្នុងការទទួលយកសេវា។ ប្រព័ន្ធនៃការផ្តល់សេវាសុខាភិបាលបានផ្តោតជាចម្បងលើការផ្តល់សេវា ឬអន្តរាគមន៍សុខភាពសាធារណៈជាច្រើន ដែលទាក់ទងផ្ទាល់នឹងបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋផង និងទាក់ទងនឹងកត្តាសង្គមនានាដែលមានផលប៉ះពាល់លើសុខភាពផង។ ការផ្តល់សេវាសុខាភិបាលទាំងអស់នោះមានគោលដៅកាត់បន្ថយថែមទៀត ការឈឺនិងស្លាប់របស់មាតា

ទារក និងកុមារ បន្ថយបន្ទុកនៃជំងឺឆ្លង និងជំងឺមិនឆ្លង ជំងឺរ៉ាំរ៉ៃ ព្រមទាំងបញ្ហាសុខភាពសាធារណៈចម្បង ផ្សេងៗទៀត។

### ១.១.៤ គោលដៅយុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាល

គោលដៅយុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាលគឺធ្វើយ៉ាងណាអោយ ប្រជាពលរដ្ឋទទួលបាន សេវាសុខភាពគ្រប់ជ្រុងជ្រោយ មានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ទាំងនៅមូលដ្ឋានសុខាភិបាល សាធារណៈ និងឯកជន។

គោលដៅយុទ្ធសាស្ត្រនៃការផ្តល់សេវាសុខាភិបាលៈ

- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាសុខភាពបន្តពូជមានគុណភាព ជាពិសេសសម្រាប់ ស្ត្រីបុរសវ័យក្មេង និងវ័យជំទង់
- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាថែទាំគភ៌មុនសម្រាលមានសុវត្ថិភាព ថែទាំក្រោយសម្រាលសម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារកមានគុណភាព ព្រមទាំងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានវ៉ាក់សាំងបង្ការជំងឺ សេវាពិនិត្យព្យាបាលតាមបែបសមាហរណកម្មគ្រប់គ្រងជំងឺកុមារ និងទារកដោយរាប់បញ្ចូលជំងឺរាគរូស
- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាអាហារូបត្ថម្ភ ដើម្បីបន្ថយកង្វះថាមពលជាតិសាច់ (ប្រូតេអ៊ីន) និងមីក្រូសារជាតិក្នុងចំណោមស្ត្រីនិងកុមារ
- លុបបំបាត់ការណើថ្មីនៃជំងឺនៃការចម្លងមេរោគអេដស៍ និងបន្តកាត់បន្ថយការស្លាប់ទាក់ទងនិងជំងឺមេរោគអេដស៍/អេដស៍
- គ្មានករណីស្លាប់នៃជំងឺគ្រុនចាញ់ដែលបណ្តាលមកពីមេរោគហ្វាល់ស៊ីប៉ារ៉ូម និងកាត់បន្ថយការស្លាប់ដោយសារជំងឺគ្រុនឈាមអោយទាបបំផុត
- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលសេវាគ្រប់គ្រងជំងឺឆ្លងដទៃទៀត ដូចជាជំងឺដង្កូវព្រូន ជំងឺតំបន់ត្រូពិក និងជំងឺឆ្លងលេចឡើងម្តងទៀត និងជំងឺឆ្លងពីសត្វមកមនុស្ស។
- បន្ថយការប្រឈមរបស់ប្រជាពលរដ្ឋ និងកត្តាហានិភ័យជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ មានជាអាទិ៍ជំងឺមហារីក ជំងឺទឹកនោមផ្អែម និងជំងឺបេះដូង សរសៃឈាម លើកកម្ពស់ការស្រាវជ្រាវទាន់ពេលវេលានៃជំងឺមិនឆ្លង និងបង្ការនៅដំណាក់កាលបឋម និងដំណាក់កាលទីពីរ
- គ្រប់គ្រងព្យាបាលជំងឺមិនឆ្លងក្នុងដំណាក់កាលធ្ងន់ធ្ងរ មានជាអាទិ៍ការថែទាំរយៈពេលវែង ការព្យាបាលសម្រន់ការឈឺចាប់ និងការស្តារនិតិសម្បទា

- បង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាបឋម និងគ្រប់ជ្រុងជ្រោយនៃសុខភាពផ្លូវចិត្ត និងសេវាព្យាបាលបន្សាបការញៀន ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីហានិភ័យនៃជំងឺផ្លូវចិត្ត
- បន្ថយការខ្វាក់ភ្នែកនៅក្នុងតំបន់ភូមិសាស្ត្រមានហានិភ័យខ្ពស់ និងផ្តល់សេវាចុះខ្សោយសោតវិញ្ញាណដោយសារជំងឺ
- លើកកម្ពស់បរិស្ថាន អនាម័យល្អ សុខភាពមាត់ធ្មេញ និងសុវត្ថិភាពចំណីអាហារ និងសុខភាពសិស្សានុសិស្ស
- បន្ថយការប្រើប្រាស់បំពានថ្នាំញៀន គ្រឿងញៀនស្រវឹង និងថ្នាំជក់ ក្នុងចំណោមប្រជាជន
- បន្ថយករណីរបួសនិងពិការភាព បង្កឡើងដោយហឹង្សា គ្រោះថ្នាក់ ឬមូលហេតុផ្សេងៗទៀត និងបន្ថយហានិភ័យសុខភាព ឬផលប៉ះពាល់សុខភាពដែលបណ្តាលមកពីគ្រោះមហន្តរាយ ការបំពុលបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ។

## ១.២ សាវតាជំងឺកូវីដ-១៩

### ១.២.១ និយមន័យ

តាមន័យវេជ្ជសាស្ត្រ៖ ជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងរាលដាលថ្មី បង្កឡើងដោយវីរុស រលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរប្រភេទទី២ (Severe Acute Respiratory Syndrome Coronavirus2: SARS-CoV-2) ដែលបណ្តាលអោយមានបណ្តុំរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ។ ការចម្លងវីរុសនេះពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត គឺឆ្លងតាមរយៈដំណក់ទឹកតូចៗតាមផ្លូវដង្ហើម (Respiratory Droplets) និងតាមរយៈការប៉ះពាល់ទៅនឹងផ្ទៃដែលមានវីរុស។[១] វីរុសនេះក៏អាចចម្លងតាមរយៈភាគល្អិតតូចៗដែលអណ្តែតនៅក្នុងខ្យល់ (Aerosol Transmission) ដែលត្រូវបង្កើតឡើងក្នុងពេលអនុវត្តទម្រង់ការទាំងឡាយណាដែលនាំអោយមានការសាយភាយភាគល្អិតតាមផ្លូវដង្ហើម។

តាមន័យ wa.gov៖ កូវីដ-១៩ (COVID-19) គឺជាជំងឺផ្លូវដង្ហើមដែលបង្កឡើងដោយវីរុសប្រភេទថ្មី ឬវីរុសក្សូណា ដែលបង្កអោយមានលក្ខណៈជំងឺផ្លូវដង្ហើមដូចជាជំងឺផ្តាសាយធម្មតាដែរ។ ជំងឺនេះឆ្លងតាមរយៈចំហាយសារធាតុរាវចេញពីការកណ្តាស់ និងក្អក ឬការប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកផ្សេងទៀតដូចជាការចាប់ដៃណានិងការទទួលទានអាហារ និងភេទសង្ឃ:រួមគ្នាជាដើម។[២]

---

១. ឯកសារជំនួយស្មារតី ស្តីពី ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០ (ទំព័រទី ១)

២. doh.wa.gov ចូលមើលថ្ងៃទី 10 មេសា ២០២២

### ១.២.២ ការចម្លងជំងឺកូវីដ-១៩

វីរុសដែលបណ្តាលអោយមានជំងឺកូវីដ-១៩ គឺឆ្លងពីមនុស្ស ទៅមនុស្សតាមរយៈដំណក់តូចៗចេញពីផ្លូវដង្ហើមពេលអ្នកជំងឺក្អក ឬកណ្តាស់ និងការប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។ ផ្អែកទៅតាមភស្តុតាង វីរុសដែលបង្កអោយមានជំងឺកូវីដ-១៩ មិនឆ្លងតាមខ្យល់ទេ ប៉ុន្តែការឆ្លងនៃខ្យល់ (Airborne Transmission) អាចកើតមាននៅពេលអនុវត្តសកម្មភាពទាំងឡាយណាដែលបង្កើតអោយមានសាយភាយភាគល្អិតតូចៗហើរតាមខ្យល់ (Aerosol generation procedures: AGS)។ ការចម្លងកូវីដ-១៩ អាចកើតឡើងតាមរយៈដំណក់តូចៗ និងការប៉ះពាលអ្នកមានផ្ទុកជំងឺ។

ដំណក់តូចៗ៖ ដំណក់តូចៗតាមផ្លូវដង្ហើម (ភាគល្អិតៗទំហំ >5-10um) បង្កឡើងនៅពេលដែលអ្នកមានជំងឺមានផ្ទុកវីរុស ក្អក ឬកណ្តាស់។ បុគ្គលដែលមានរោគសញ្ញាផ្លូវដង្ហើម (ក្អក កណ្តាស់) មានហានិភ័យនៃការឆ្លង ដោយសារ មាត់ ច្រមុះ ឬភ្នែករបស់អ្នកទាំងនោះបានប៉ះពាល់ទៅនឹងតំណក់ទឹកតូចៗដែលមានផ្ទុកមេរោគនៅតាមផ្លូវដង្ហើម។

ការប៉ះពាល់៖ ការឆ្លង ក៏អាចកើតមានឡើងតាមរយៈការប៉ះពាល់អ្នកផ្ទុកកូវីដ-១៩ ផ្ទាល់និងដោយប្រយោលជាមួយផ្ទៃវត្ថុដែលមានវីរុស និងឧបករណ៍ផ្សេងៗ។

### ១.២.៣ លក្ខណៈគ្លីនិកនៃជំងឺ

១. រយៈពេលគិតចាប់ពីការចម្លងជំងឺរហូតដល់មានចេញជារោគសញ្ញាគឺភាគច្រើនបំផុតចាប់ពី ៣-៧ ថ្ងៃ (ចន្លោះ ១-១៤ថ្ងៃ)

២. រោគសញ្ញាដែលតែងតែជួបប្រទះញឹកញាប់ជាងគេរួមមាន៖ គ្រុនក្តៅ ក្អកស្ងួត ហត់ ឬពិបាកដកដង្ហើម និងអស់កម្លាំងជាដើម

៣. រោគសញ្ញាបន្ទាប់បន្សំរួមមាន៖ ឈឺសាច់ដុំ ឈឺបំពង់ក ក្អួត រាគ ជំងឺភ្នែកក្រហម ឈឺក្បាល បាត់បង់រសជាតិ ឬក្លិន និងការឡើងកន្ទួល ឬម្រាមជើងប្រែពណ៌ស្វាយ

៤. អ្នកជំងឺដែលមានស្ថានភាពស្រាល អាចមានតែ គ្រុនក្តៅតិចតួច និងអស់កម្លាំង

៥. កុមារ មនុស្សចាស់ ឬអ្នកដែលមានវិបត្តិភាពស៊ាំ អាចមានរោគសញ្ញាមិនជាក់លាក់

៦. អ្នកជំងឺដែលមានវិវត្តទៅជំងឺធ្ងន់ធ្ងរ (Severe) ឬសង្គ្រោះបន្ទាន់ (Critical) ជាទូទៅកើតឡើងក្នុងអំឡុងពេល មួយសប្តាហ៍

៧. អ្នកជំងឺកូវីដ-១៩ កម្រិតសង្គ្រោះបន្ទាន់មានលេចចេញនូវរោគសញ្ញា រួមមាន បណ្តុំរោគសញ្ញាវិបត្តិផ្លូវដង្ហើមស្រួចស្រាវ (Acute Respiratory Distress Syndrome) ស្តុកសិបទិក (septic shock) វិបត្តិអាស៊ីដូមេតាបូលិក (Metabolic Acidosis) វិបត្តិកំណកឈាម និងសរីរាង្គជាច្រើនចុះខ្សោយ។ មិនមែនគ្រប់អ្នកជំងឺស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ ឬសង្គ្រោះបន្ទាន់ទាំងអស់ សុទ្ធតែមានគ្រុនក្តៅ។

៨. អ្នកជំងឺកូវីដ-១៩ ភាគច្រើនមានការវិវត្តទៅល្អប្រសើរ តែដោយឡែកមនុស្សចាស់ដែលមានអាយុលើស ពី ៦០ឆ្នាំ និងអ្នកដែលមានជំងឺរ៉ាំរ៉ៃប្រចាំកាយដែលមានដូចជា ជំងឺធាត់ (BMI>30), ជំងឺបេះដូង, ជំងឺទឹកនោមផ្អែម, ជំងឺសួតរ៉ាំរ៉ៃ, ជំងឺមហារីក និងជំងឺសរសៃឈាមខួរក្បាល សុទ្ធតែជាកត្តាប្រឈមដែលបណ្តាលអោយងាយវិវត្តទៅរកស្ថានភាពជំងឺធ្ងន់ធ្ងរ

៩. ស្រ្តីមានផ្ទៃពោះដែលមានជំងឺកូវីដ-១៩ អាចប្រឈមនឹងហានិភ័យខ្ពស់ នៃការរអូសបន្លាយជំងឺ និងត្រូវការសម្រាកក្នុងផ្នែកសង្គ្រោះបន្ទាន់ជាង ស្រ្តីដែលមិនមានផ្ទៃពោះ ទោះពួកគេមានអាយុស្របាលគ្នាក៏ដោយ

១០. ចំពោះកុមារជាទូទៅមានរោគសញ្ញាស្រាល តែមានករណីខ្លះអាចធ្ងន់ធ្ងរដោយសារបណ្តុំរោគសញ្ញារលាកនៅប្រព័ន្ធសរីរាង្គជាច្រើន (Multisystem Inflammatory Syndrome) ដែលមានលក្ខណៈពិសេសស្រដៀងនឹងជំងឺ Kawasaki Disease and Toxic shock syndrome ហើយដែលត្រូវបានពិពណ៌នា

១១. វិរុសអាចចម្លងពី ១ដល់៣ ថ្ងៃមុនពេលចេញរោគសញ្ញា (Pre-Symptomatic Transmission) ហើយករណីគ្មានរោគសញ្ញាក៏អាចមានដែលតែនៅក្នុងកម្រិតទាបបំផុត។[៣]

ជំងឺកូវីដ-១៩ ជាជំងឺផ្លូវដង្ហើមស្រួចស្រាវប្រភេទថ្មីដែលកើតឡើងនៅទីក្រុងវូហានប្រទេសចិនកាលពីខែធ្នូ ឆ្នាំ២០១៩ ហើយបានរីករាលដាលទូទាំងពិភពលោក។ វីរុសនេះ ខ្លាចពន្លឺកាំរស្មីអ៊ុលត្រាវីយូឡេ កម្តៅ និងសារធាតុរំងាប់មេរោគដែលផ្ទុកអេតាណុល និងក្លរីន ទើបីជាវីសុសចាប់ផ្តើមផ្ទុះចេញពីការចម្លងពីសត្វមកមនុស្សក្តី បច្ចុប្បន្នអ្នកជំងឺនេះ (អ្នកផ្ទុកវីរុស SARS-CoV-2) បានក្លាយប្រភពចម្លងជាចម្បង។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ ២០២០ អង្គការសុខភាពពិភពលោក បានប្រកាសជាសកលថា ការផ្ទុះកូវីដ-១៩ នេះគឺជាភាពអាសន្នផ្នែកសុខភាពសាធារណៈដែលជាការព្រួយបារម្ភអន្តរជាតិ។ នៅថ្ងៃទី ១១ មីនា ឆ្នាំ២០២០ អង្គការសុខភាពពិភពលោកបានចាត់ទុកការផ្ទុះឡើងនៃជំងឺនេះជាការរាតត្បាតសកល។

## ១.៣ កម្រិតនៃស្ថានភាពជំងឺកូវីដ-១៩

ការធ្វើចំណាត់ថ្នាក់កម្រិតនៃភាពធ្ងន់ធ្ងរសម្រាប់ករណីវិជ្ជមាន ដោយប្រើលក្ខខណ្ឌដូចជាៈ

### ១.៣.១ កម្រិតស្រាល

- មានផ្តាសាយ ហៀរសំបោរ ឈឺបំពង់ក ឈឺសាច់ដុំ ឬឈឺសន្លាក់
- កម្តៅតិចជាង ៣៨អង្សារសេ
- ចង្វាក់ដង្ហើមធម្មតា (១៤ ដល់២០ដងក្នុងមួយនាទី សម្រាប់មនុស្សពេញវ័យ)
- កំហាប់អុកស៊ីសែន ($SpO_2$) លើសពី ៩៥% (ដោយមិនទាន់ដាក់អុកស៊ីសែន)

៣. មគ្គុទេស៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២១ (ទំព័រ២)

### ១.៣.២ កម្រិតមធ្យម

- ❖ កម្តៅលើពី ៣៨អង្សារសេ
- ❖ ចង្វាក់បេះដូង ច្រើនជាង១០០ដងក្នុងមួយនាទី
- ❖ ចង្វាក់ដង្ហើម ២០ ដល់២៥ដងក្នុងមួយនាទី
- ❖ $SpO_2$ ៩២% ដល់ ៩៤% (ដោយមិនទាន់ដាក់អុកស៊ីសែន)
- ❖ រូបថតសួតមិនធម្មតា មានសញ្ញាស្រអាប់ដាបនៅផ្នែកខាងនៃសួត

### ១.៣.៣ កម្រិតធ្ងន់ធ្ងរ

- ❖ កម្តៅលើពី ៣៨អង្សារសេ
- ❖ ចង្វាក់បេះដូង > (ច្រើនជាង)១២០ដងក្នុងមួយនាទី
- ❖ ចង្វាក់ដង្ហើម >២៥ ដងក្នុងមួយនាទី
- ❖ វិបត្តិនៃការដឹងស្មារតី (ពិន្ទុ Glasgow Coma Scale ធំតិចជាងឬស្មើ ១៤)

❖ មានការវិវត្តលឿន នៃសញ្ញារលាកសួតលើរូបភាពថតសួត ដោយកាំរស្មីអ៊ិច តិចជាងឬស្មើ ៥០% ក្នុងអំឡុងពេល ២៤ ដល់៤៨ម៉ោង

### ១.៣.៤ កម្រិតសង្គ្រោះបន្ទាន់

- ❖ ដង្ហើមចុះខ្សោយ តម្រូវប្រើម៉ាស៊ីនជំនួយការដកដង្ហើម
- ❖ ស្តុក (Shock)
- ❖ សរីរាង្គផ្សេងចុះខ្សោយ តម្រូវការថែទាំនៅផ្នែក ICU។

---

៤. មគ្គុទេស៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២១ (ទំព័រ២)

# ជំពូកទី២

## តួនាទីភារកិច្ចក្នុងការបង្ការ ការពារនិងព្យាបាលរបស់ក្រសួង សុខាភិបាល

# ជំពូកទី២

# តួនាទីភារកិច្ចក្នុងការបង្ការ ការពារនិងព្យាបាលរបស់ក្រសួងសុខាភិបាល

## ២.១. តួនាទីភារកិច្ចរបស់ក្រសួងសុខាភិបាល

ករណីទី១ នៃជំងឺកូវីដ-១៩ ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញនៅក្នុងប្រទេសកម្ពុជាថ្ងៃទី២៧ មករា ឆ្នាំ ២០២០។ ជំងឺឆ្លងដល់កាចសាហាវនេះបានរីករាលដាលឆ្លងបន្តិចម្តងៗរហូតដល់ចុងក្រោយមានការផ្ទុះឡើង ការឆ្លងលក្ខណៈសហគមន៍គួរអោយកត់សម្គាល់ ដែលត្រូវកំណត់ថាជាព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដោយមានចំនួនកើនឡើងពីមួយថ្ងៃទីមួយថ្ងៃ ដែលភាគច្រើនកើតមាននៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និង ខេត្តកណ្តាល ហើយបន្តឆ្លងដល់តំបន់ផ្សេងៗទៀត រហូតគ្រប់ខេត្តក្រុងទាំងអស់ទូទាំងប្រទេសកម្ពុជា។ ករណីឆ្លងរាលដាលបានបង្កការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ដល់គ្រប់តួអង្គ ជាពិសេសគឺរាជរដ្ឋាភិបាលបាន សម្រេចបិទខ្ទប់រាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងតំបន់មួយចំនួនទៀតដែលបានឆ្លងធ្ងន់ធ្ងរ។ ក្នុងពេលជាមួយគ្នាដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈរាជរដ្ឋាភិបាលបានធ្វើការជាមួយបណ្តាលក្រសួងពាក់ព័ន្ធចេញជាបទដ្ឋានគតិយុត្តិជាច្រើន រួមមានច្បាប់ស្តីពីការដាក់ប្រទេសក្នុងភាពអាសន្ន ត្រូវបានអនុម័តឡើង យ៉ាងប្រញាប់ គោលការណ៍ណែនាំការការពារសុខភាព និងអនាម័យ និងមានវិធានការរដ្ឋបាលផ្សេងៗ មាន ដូចជាបម្រាមគោចរណ៍នៅពេលយប់ និងការធ្វើបច្ចុប្បន្នភាពនៃជំងឺឆ្លងពីករណីឆ្លងថ្មី ករណីអ្នកស្លាប់ និង ករណីជាសះស្បើយ។

ក្រសួងសុខាភិបាលបានចេញវិធានការ ក៏ដូចជានីតិវិធីក្នុងការបែងចែកបុគ្គលិក និងការបង្ការ និងការ ត្រួតពិនិត្យការចម្លងមេរោគជំងឺកូនវីដ-១៩ នៅមូលដ្ឋានសុខាភិបាល និងកន្លែងថែទាំដល់បុគ្គលិកដែលនឹង ទៅផ្តល់សេវាសុខាភិបាលដោយផ្ទាល់នៅតាមមូលដ្ឋានសុខាភិបាលដែលមានតួនាទៅភារកិច្ចដូចខាងក្រោម ៖

### ក. មូលដ្ឋានសុខាភិបាលៈ មន្ទីរពេទ្យ និងមណ្ឌលសុខភាព

- បុគ្គលិកថែទាំសុខភាពទាំងអស់ដែលនៅផ្នែកជួរមុខ ឬប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺដែល មានការសង្ស័យថាអាចផ្ទុកជំងឺកូវីដ-១៩ ឬជាមួយអ្នកជំងឺ ត្រូវអនុវត្តនូវការការពារដោយពាក់អាវសុវត្ថិភាព ពាក់ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬបាំមុខជាដើម។ ការប្រមូលយកសំណាកពីផ្លូវដង្ហើម សម្រាប់មន្ទីពិសោធន៍ ត្រូវធានាអោយបានថាគ្មានការសាយភាយភាគល្អិតតូចៗតាមខ្យល់ដែល អាចបង្កអោយមានការចម្លងថ្មីឡើយ។
- បុគ្គលិកអនាម័យ មានតួនាទីក្នុងការលាងសម្អាតបន្ទប់ពិគ្រោះជំងឺក្រៅ នៅបន្ទប់សម្រាកពេទ្យត្រូវ ពាក់ម៉ាស់វះកាត់ ពាក់ស្រោមដៃក្រាស់ វ៉ែនតាកាពារភ្នែក ឬបាំងការពារមុខ អាវបំពង់ និងស្បែកជើង បិទជិត។

- អ្នកជំងឺទាំងអស់ ត្រូវចូលមកក្នុងមូលដ្ឋានមន្ទីរពេទ្យត្រូវពាក់ម៉ាស់និងរក្សាគម្លាតយ៉ាងតិច ១.៥០ ម៉ែត្រ ដើម្បីបញ្ចៀសនូវផលប៉ះពាល់នៃជំងឺឆ្លងកូវីដ-១៩ នេះ

**ខ. មធ្យោបាយធ្វើដំណើរៈ រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ**

- បុគ្គលិកថែទាំសុខភាពៈ មានតួនាទីក្នុងការទទួលដំណឹង និងផ្តល់ជាមធ្យោបាយសម្រាប់ដឹកអ្នកដំណើរអោយទៅសម្រាក់ព្យាបាលជំងឺនៅមូលដ្ឋានសុខាភិបាលដែលរាជរដ្ឋាភិបាលបានរៀបចំទុកសម្រាប់អ្នកដែលមានផ្ទុកជំងឺឆ្លងកូវីដ-១៩ ដោយមិនអនុញ្ញាតអោយមានការសម្រាកព្យាបាលនៅតាមផ្ទះនោះទេ។ មានន័យថារាល់បុគ្គលដែលមានរោគសញ្ញាដូចទៅនឹងលក្ខណៈគ្លីនិកនៃជំងឺឆ្លងកូវីដ-១៩ ត្រូវតែផ្តល់ដំនឹងទៅខាងមូលដ្ឋានសុខាភិបាលដែលនៅគៀកនឹងកន្លែងរស់នៅដើម្បីទទួលបានការព្យាបាល និងការថែទាំ
- អ្នកបើកបរៈ ត្រូវអនុវត្តតាមគោលការសុវត្ថិភាពនៃការវិធានការសុខាភិបាលដោយអនុវត្តនូវការពាក់អាវបំពង់ ស្រោមដៃក្រាស់ ម៉ាសវះកាត់ និងស្បែងជើងបិតជិត
- បុគ្គលិកអនាម័យ បន្ទាប់ពីរថយន្តដឹកអ្នកដំណើរបានដឹកអ្នកដំណើររួច បុគ្គលិកអនាម័យត្រូវលាងសម្អាត និងសម្លាប់មេរោគដោយប្រើប្រាស់ការសម្លាប់តាមគោលការណ៍ដែលចេញដោយសមត្ថកិច្ចរបស់ខ្លួន។

**គ. នៅសហគមន៍ និងផ្ទះ**

- ក្រុមអ្នកឆ្លើយតបបន្ទាន់ មានតួនាទីក្នុងការចុះទៅកន្លែងដែលមានករណីផ្ទុះកូវីដ-១៩ និងធ្វើការសាកសួរដោយផ្ទាល់ជាមួយអ្នកសង្ស័យ ឬអ្នកប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺដើម្បីធ្វើការរក្សាសណ្តាប់ធ្នាប់ និងធ្វើហាមឃាត់រាល់ការធ្វើដំណើរផ្សេងៗជាប្រការសម្រាប់ការបញ្ចៀសនូវរាល់ការចម្លងករណីថ្មី។ ម៉្យាងទៀតគឺដើម្បីធ្វើការតាមដានត្រួតពិនិត្យអ្នកដែលប៉ះពាល់ដោយផ្ទាល់រៀងរាល់២ទៅ៣ថ្ងៃម្តងរហូតដល់១៤ ឬ២៧ថ្ងៃ។

**ឃ. នៅមន្ទីពិសោធន៍**

- អ្នកបច្ចេកទេសនៃមន្ទីពិសោធន៍ ការធ្វើតេស្តរោគវិនិច្ឆ័យប្រើប្រាស់វិធីសាស្ត្រ ម៉ូលីគុល (រៀបចំធ្វើ RT-PCR) ត្រូវគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាលជាធរមាន។

## ២.២ មគ្គុទេសក៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩

### ២.២.១ ការវិភាគ និងការធ្វើរោគវិនិច្ឆ័យ

- **ការប្រមូលសំណាកសម្រាប់ធ្វើតេស្ត**

ប្រសិនបើអ្នកសង្ស័យថាមានផ្ទុកជំងឺឆ្លងមានរោគសញ្ញាត្រូវនឹងការសង្ស័យដូចនិយមន័យខាងលើត្រូវយកភាគសំណាក់ដើម្បីធ្វើការបញ្ជាក់ និងក្រុមគ្រូពេទ្យត្រូវគោរពតាមនីតិវិធីដូចជាៈ

- យកជាតុសំណាក់តាមច្រមុះ និងបំពង់ករ

- ដាក់សំណាក់នៅក្នុងបំពង់ VTM ( Viral Transport Media )
- បំពេញឯកសារស្នើសុំ និងបញ្ជូនទៅមន្ទីរពិសោធន៍សម្រាប់ការធ្វើតេស្ត PCR
- វិធីសាស្ត្រនៃការវិភាគដទៃទៀតសម្រាប់ធ្វើតេស្ត SARS-Cov-2 ដូចជា ការប្រើប្រាស់តេស្តរហ័ស ត្រូវគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល គោលការណ៍ណែនាំប្រតិបត្តិ ស្ដីពីការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន ស្ថាប័ននិងអង្គភាពរដ្ឋមិនដែនសុខាភិបាល បណ្ដាលច្រកទ្វារចេញ ចូលប្រទេស ក្រុមហ៊ុនឯកជន រោងចក្រ សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងៗទៀត និងសម្រាប់បុគ្គលឯកជន

❖ **ការបញ្ជាក់ការឆ្លងពីមន្ទីរពិសោធន៍**

បន្ទាប់ពីបានបញ្ជូនភាគសំណាក់ទៅកាន់មន្ទីរពិសោធន៍នឹងទទួលបាលលទ្ធផងជាបីដំណាក់កាល៖

- ករណីសង្ស័យ៖ អ្នកជំងឺស្ដែងចេញនូវអាការៈដូចជានិយមន័យដែលបានកំណត់ ហើយត្រូវធ្វើចត្តាឡីស័កដើម្បីរងចាំការធ្វើតេស្តសំណាក់ម្ដងទៀតតាមការកំណត់របស់ក្រុមគ្រូពេទ្យ
- ករណីប្រហែល ជាករណីសង្ស័យ ប៉ុន្តែមន្ទីរពិសោធន៍មិនអាចតេស្តបញ្ជាក់បាន ដូចនេះអ្នកជំងឺត្រូវធ្វើចត្តាឡីស័កបន្តរហូតមានការយកសំណាក់ម្ដងទៀតក្រោយមានការកំណត់ ឬការណាត់ជួបរបស់ក្រុមគ្រូពេទ្យ និងបុគ្គលដែលមានករណីប្រហែលត្រូវស្ថិតនៅក្នុងកន្លែងដាច់ដោយឡែក និងធ្វើការកាត់សម្គាល់រោគសញ្ញាសុខភាពរបស់ខ្លួន
- ករណីមានផ្ទុកមេរោគ គឺជាករណីតេស្តឃើញវិជ្ជមាន ដូចនេះបុគ្គលនោះត្រូវទៅសម្រាកព្យាបាលនៅមន្ទីពេទ្យ ឬកន្លែងដែលរាជរដ្ឋាភិបាលបានផ្ដល់អោយក្រសួងសុខាភិបាលជាបណ្ដោះអាសន្នក្នុងការដាក់អ្នកជំងឺអោយសម្រាកព្យាបាលរហូតជាសះស្បើយ។

កត្តាប្រឈមដែលនាំអោយអ្នកជំងឺកូវីដ-១៩ វិវត្តទៅរកភាពគ្រោះថ្នាក់ និងធ្ងន់ធ្ងរ គឺជាអ្នកជំងឺដែលមានអាយុលើសពី ៦០ឆ្នាំ និងអ្នកជំងឺដែលមានជំងឺផ្សេងៗទៀតមានហានិភ័យខ្ពស់ ក្នុងការវិវត្តទៅដល់ការស្លាប់។[៥]

### ២.២.២ ការថែទាំ ព្យាបាលអ្នកជំងឺ

ក្នុងការបង្ការ និងត្រួតពិនិត្យការចម្លងរោគ ក្រុមគ្រូពេទ្យជួរមុខត្រូវរៀបចំដាក់អ្នកដែលមានករណីសង្ស័យ និងករណីវិជ្ជមាន អោយបានដាច់ដោយឡែកពីគ្នា និងទទួលការព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ឬនៅផ្ទះទៅតាមស្ថានភាពអ្នកជំងឺដូចការណែនាំក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ការគ្រប់គ្រងថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ ។

---

៥. មគ្គុទេស៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២១ ( ទំព័រ៣ )

ការព្យាបាលអ្នកជំងឺកូវីដ-១៩ មានច្រើនរបៀបនិងទៅតាមរោគសញ្ញាជាក់ស្តែង ក្រសួងសុខាភិបាលបានបែងចែកការព្យាបាលដូចខាងក្រោម៖

- ការព្យាបាលដោយការគាំទ្រ គឺជាការព្យាបាលតាមរយៈការគាំពារបានល្អ រួមមានធានាបាននូវអាហារូបត្ថម្ភគ្រប់គ្រាន់ ត្រួតពិនិត្យជាតិទឹក និងតុល្យភាពអេឡិចត្រូលីត តាមដានសញ្ញាជីវិតយ៉ាងជិតដិត និងតាមដានកំហាបអុកស៊ីសែន ដើម្បីរកមើលនូវការចុះខ្សោយ។ ត្រូវវាយតម្លៃពីតម្រូវការទាក់ទងនឹងចិត្តសាស្ត្រ និងការគាំទ្រ ត្រូវកំណត់ការព្យាបាលចិត្តសាស្ត្រ អាស្រ័យទៅតាមកម្រិតនៃភាពធ្ងន់ធ្ងរនៃអ្នកជំងឺ។
- ការព្យាបាលដោយអុកស៊ីសែន៖ អ្នកជំងឺកូវីដ-១៩ ប្រមាណ២០% អាចវិវត្តទៅរកភាពធ្ងន់ធ្ងរដែលត្រូវអោយមានការផ្តល់អុកស៊ីសែន ក្នុងចំណោមអ្នកជំងឺធ្ងន់ធ្ងរទាំងអស់ប្រមាណ ២៥% ត្រូវការជំនួយអុកស៊ីសែនបច្ចេកទេសខ្ពស់។ អ្នកជំងឺដែលមានរោគសញ្ញាសង្គ្រោះបន្ទាន់ (ស្ទះដង្ហើម ឬមិនដកដង្ហើម វិបត្តផ្លូវដង្ហើមធ្ងន់ធ្ងរ ឡើងស្វាយពេញខ្លួន ស្តុក សន្លប់ ឬប្រកាច់) អ្នកដែលមានកំហាប់អុកស៊ីសែនតិចជាង ឬស្មើ ៩៥% ត្រូវព្យាបាលដោយផ្តល់អុកស៊ីសែនជាបន្ទាន់។
- ការព្យាបាលតាមរោគសញ្ញា៖ គឺជាការព្យាបាលតាមរយៈការផ្តល់ថ្នាំទៅតាមអាការៈដែលមានជាក់ស្តែង ដូចជាគ្រុនក្តៅ ឈឺបំពង់ក ផ្តាសាយ រាគជាដើម។
- ការព្យាបាលដោយ Corticosteroid៖ កុំផ្តល់ថ្នាំពពួក Corticosteroid សម្រាប់ការព្យាបាលអ្នកកជំងឺកូវីដ-១៩ ដែលមិនត្រូវការអុកស៊ីសែនព្រោះភស្តុតាងបានបង្ហាញថា ការធ្វើបែបនេះអាចបង្កើនហានិភ័យនៃការស្លាប់ ដោយសារការកើនឡើងនូវផលវិបាក និងការចម្លងជំងឺផ្សេងៗ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មិនត្រូវបញ្ឈប់ការផ្តល់ថ្នាំ Corticosteroid ដល់អ្នកជំងឺកូវីដ-១៩ ដែលមិនត្រូវការអុកស៊ីសែន ដែលទទួលបានការព្យាបាលដោយមូលហេតុផ្សេងៗ។
- ការព្យាបាលបូកនិងការព្យាបាលសុខភាពផ្លូវចិត្ត និងការគាំត្រផ្លូវចិត្ត៖ ការផ្តួចផ្តើមប្រាស្រ័យទាក់ទងយ៉ាងសកម្មជាមួយអ្នកជំងឺ និងក្រុមគ្រួសារដើម្បីផ្តល់ការគាំទ្រ និងព័ត៌មានពីការវិវត្តអាការៈរោគរបស់ជំងឺ។ ស្វែងយល់គុណតម្លៃ និងចំណង់ចំណូលចិត្តរបស់អ្នកជំងឺទាក់ទងនឹងអន្តរាគមន៍ដែលជួយទ្រទ្រង់ជីវិត និងការថែទាំងចុងក្រោយ។ អ្នកជំងឺ និងក្រុមគ្រួសារអ្នកជំងឺជារឿយៗទទួលបរងការថប់បារម្ភ និងការភ័យខ្លាច ដែលពួកគាត់គួរតែត្រូវបានគាំទ្រដោយការប្រឹក្សាខាងផ្លូវចិត្ត។
    - រោគសញ្ញានៃការថប់បារម្ភ និងការបាក់ទឹកចិត្តអាចជាប្រតិកម្មទូទៅរបស់មនុស្សក្នុងបរិបទនៃការធ្វើរោគវិនិច្ឆ័យជំងឺកូវីដ-១៩ ជាពិសេសចំពោះអ្នកដែលអាចត្រូវសម្រាកពេទ្យ ដោយសារការបារម្ភចំពោះសុខភាពផ្ទាល់ខ្លួន ឬសុខភាពអ្នកដទៃ ឬការតម្រូវ

អោយដាក់នៅដាច់ដោយឡែក (ដែលនាំអោយមានការផ្តាច់ចេញពីសហគមន៍) ការប្រឈមនឹងហានិភ័យនៃការស្លាប់ដែលអាចកើតឡើង បារម្ភចំពោះហានិភ័យនៃការចម្លងទៅអ្នកដទៃ និងបារម្ភពីការទុកចោលគ្រួសារដែលត្រូវការថែទាំអោយនៅតែឯង។

- ○ ផ្តល់ការគាំទ្រផ្លូវចិត្ត និងសុខភាពផ្លូវចិត្តជាមូលដ្ឋានដល់គ្រប់អ្នកដែលសង្ស័យ ឬបញ្ជាក់កូវីដ-១៩ ដោយសាកសួរពួកគាត់ពីសេចក្តីត្រូវការ និងការបារម្ភ ហើយដោះស្រាយជូនគាត់តាមលទ្ធភាពជាក់ស្តែង។ កំណត់អោយបានឆាប់ និងការវាយតម្លៃនូវរោគសញ្ញាថប់បារម្ភ បាក់ទឹកចិត្តក្នុងបរិបទជំងឺកូវីដ-១៩ ចាប់ផ្តើមយុទ្ធសាស្ត្រគាំទ្រផ្លូវចិត្ត អន្តរាគមន៍ជួរទីមួយដើម្បីព្យាបាលរោគសញ្ញាថ្មីនៃការថប់បារម្ភ និងបាក់ទឹកចិត្ត។ ប្រើយុទ្ធសាស្ត្រគាំត្រផ្លូវចិត្តជាអន្តរាគមន៍ជួរទីមួយ ដើម្បីព្យាបាលបញ្ហាដំណេកក្នុងករណីស្ត្រេសស្រួចស្រាវ។

- ➢ ការត្រួតពិនិត្យតាមដាន សម្រាប់ករណីជំងឺកម្រិតស្រាល គួរតាមដានសញ្ញាជីវិត និងកំហាប់អុកស៊ីសែនមួយដងក្នុងមួយថ្ងៃ។ សម្រាប់ករណីជំងឺមធ្យម តាមដានសញ្ញាជីវិត និងកំហាប់អុកស៊ីសែនអោយបាលដិតដល់រៀងរាល់ពី ៦ទៅ៨ម៉ោង និងយកចិត្តទុកដាកចំពោះសញ្ញាគ្លីនិកដែលបានចុះខ្សោយដូចជា វិបត្តិដង្ហើម ប្រសិនបើអ្នកជំងឺមានវិបត្តិការដកដង្ហើម កំហាប់អុកស៊ីសែនទាប ឬខ្សោយសរីរាង្គដទៃទៀត ដែលមិនអាចគ្រប់គ្រងក្នុងមូលដ្ឋានព្យាបាលនេះ។ ការចាប់ផ្តើមផលវិបាកតាមលក្ខណៈគ្លីនិកនៃនាំអោយទៅជាមានបណ្តុំរោគសញ្ញាវិបត្តិផ្លូវដង្ហើម (ARDS) គឺកើតឡើងក្នុងរយៈពេលពី ៦ដល់៧ថ្ងៃចាប់ពីរោគសញ្ញាចាប់ផ្តើម។[៦]

### ២.២.៣ ការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩

- ➢ លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតស្រាល សម្រាកព្យាបាលនៅផ្ទះ៖ ជាគោលការណ៍ ការសម្រាកព្យាបាលនៅផ្ទះ និងការធ្វើចត្តឡីស័កមានរយៈពេលសរុប ២៨ថ្ងៃ ដោយរាប់ចាប់តាំងពីថ្ងៃដឹងលទ្ធផលតេស្តដំបូង និងត្រូវតាមដានស្ថានភាពជំងឺរហូតដល់ថ្ងៃទី ១៣ ដើម្បីធ្វើតេស្តពីមន្ទីពិសោធន៍ដោយ PCR និងរងចាំមួយថ្ងៃដើម្បីរកចាំលទ្ធភាពពីមន្ទីពិសោធន៍ បានរាប់បញ្ចូលជារយៈពេលនៃការធ្វើចត្តាឡីស័ក១៤ថ្ងៃ
- ➢ លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅមណ្ឌលព្យាបាលជំងឺកូវីដ-១៩ កម្រិតស្រាល៖ ប្រសិនបើគ្មានរោគសញ្ញាក្នុងរយៈពេលបីថ្ងៃជាប់គ្នា ទោះបីជានៅតែរកឃើញ PCR វិជ្ជាមានក៏ដោយ នៅថ្ងៃទី ២១រាប់ចាប់ពីថ្ងៃរកឃើញដំបូង ក៏ត្រូវបានអនុញ្ញាតអោយបញ្ចប់ការព្យាបាលដែល ដោយត្រូវធ្វើចត្តាឡីស័កបន្តនៅផ្ទះចំនួន១៤ថ្ងៃបន្ត។

៦. មគ្គុទេស៍សម្រាប់ការគ្រប់គ្រង និងព្យាបាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២១ (ទំព័រ៦)

- លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងធ្ងន់ នៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ៖ ការធ្វើតេស្តនៅថ្ងៃទី ១០ រកឃើញអវិជ្ជមានត្រូវបន្តសម្រាកព្យាបាល និងយកសំណាករហូតដល់ថ្ងៃទី១២ និងត្រូវអនុញ្ញាតអោយបញ្ចប់ការព្យាបាល ដោយបន្តសម្រាក និងធ្វើចត្តាឡីស័កបន្តនៅផ្ទះចំនួន១៤ថ្ងៃទៀត។
- បន្ទាន់ពីចាក់ចេញពីមន្ទីរពេទ្យ មណ្ឌលព្យាបាល អ្នកជំងឺត្រូវបានណែនាំអនុវត្តដូចជា៖
  - ត្រូវតាមដានសុខភាពផ្ទាល់ខ្លួនដោយស្នាក់នៅក្នុងបន្ទប់ដាច់ដោយឡែករយៈពេល១៤ថ្ងៃ
  - ពាក់ម៉ាស់វះកាត់ និងអនុវត្តអនាម័យដៃអោយបានទៀតទាត់ជាមួយសាប៊ូ ឬអាល់កុល
  - ស្នាក់នៅក្នុងបន្ទប់ម្នាក់ឯង មានខ្យល់ចេញចូលគ្រប់គ្រាន់ កាត់បន្ថយការទាក់ទងជិតស្និតជាមួយសមាជិកគ្រួសារ បរិភោគអាហារដោយឡែកពីគ្នា
  - ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក អ្នកជំងឺមិនចាំបាច់ត្រឡប់មកធ្វើតេស្តឡើងវិញទេ។

### ២.២.៤ ការបូជាសព

ការគ្រប់គ្រងសពត្រូវឈរលើគោលការណ៍គ្រិះ ៣យ៉ាងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់ពិសេស និងរក្សាតុល្យភាពរបាំងសិទ្ធិរបស់គ្រួសារសព និងភាពចាំបាច់ក្នុងការបង្ការហានិភ័យនៃសុខាភាពសាធារណៈ។

គោលការណ៍គ្រិះ នៃការគ្រប់គ្រងសពអ្នកជំងឺទូទៅ

1. សុវត្ថិភាពនៃការរៀបចំទុកដាក់សព៖ អនុវត្តវិធានការបង្ការការឆ្លងរោគតាមនិយមស្តង់ដារដោយមានសម្ភារៈលាងសម្អាតដៃ ឬទឹកសម្លាប់មេរោគនិងពាក់ឧបករណ៍ការពារខ្លួនអោយបានត្រឹមត្រូវ។
2. គោលរពសេចក្តីថ្លៃថ្នូររបស់សព៖ រៀបចំទុកដាក់សពអោយបានសមរម្យតាមទម្លាប់ប្រពៃណី និងសាសនាដោយផ្អែកតាមកម្រិតហានិភ័យនៃការចម្លងជំងឺ និងវិធានការសុខាភិបាលជាធរមាន
3. បន្ថយហានិភ័យសុខភាពសាធារណៈ៖ សម្អាតបរិស្ថាននិងរក្សាអនាម័យល្អ ដើម្បីបង្ការចម្លងរោគនៅគេហដ្ឋាន កន្លែងរក្សាសព ទីបូជាសព ឬបញ្ចុះសព និងទីតាំងជុំវិញ។[៧]

គោលការណ៍នេះ គឺជាឧបករណ៍បច្ចេកទេសជាសារវន្តសម្រាប់បុគ្គលិកពេទ្យ និងគ្រួសារសព អាចារ្យវត្ត ព្រះសង្ឃ ឬអ្នកកាន់សាសនាផ្សេងទៀត ក្រុមអ្នកបញ្ចុះសព ប្រជាជនទាំងអស់ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ប្រើប្រាស់ក្នុងការគ្រប់គ្រង រៀបចំចាត់ចែងសពអ្នកជំងឺទូទៅនៅតាមមន្ទីរពេទ្យ និងផ្ទះប្រកបដោយសុវត្ថិភាព។ ការគ្រប់គ្រងសព គឺជាវំហូរសកម្មភាពនៃការរៀបចំចាត់ចែងសពអ្នកជំងឺដែលបានស្លាប់ ដោយចាប់ផ្តើមពីការរៀបចំសពនៅក្នុងបន្ទប់អ្នកជំងឺនៅមន្ទីរពេទ្យ ការចាត់ចែងដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យ រហូតដល់រៀបចំពីធីបូជាសព ឬបញ្ចុះសព។ សកម្មភាពទាំងអស់ប្រព្រឹត្តឡើងនៅតាមទីតាំងផ្សេងៗគ្នា ហើយទាក់ទងនិងអ្នកអនុវត្តច្រើនផ្នែក។

៧. គោលការណ៍គ្រិះនៃការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩

ការគ្រប់គ្រងសពអ្នកជំងឺទូទៅទាក់ទងនិងសកម្មភាពសំខាន់ៗមួយចំនួនដូចជា៖

1. **ការរៀបចំសពនៅមន្ទីរពេទ្យ**

ការគ្រប់គ្រងសពអ្នកជំងឺដែលបានស្លាប់នៅក្នុងមន្ទីរពេទ្យ ជាសមត្ថកិច្ចរបស់មន្ទីរពេទ្យ។ ការរៀបចំសពបន្ទាប់ពីស្លាប់ភ្លាម និងការតម្កល់សពមុនពេលបញ្ចូលចេញពីមន្ទីរពេទ្យ គឺជាភារកិច្ចរបស់មន្ទីរពេទ្យ។ ក្នុងករណីពុំមានក្រុមគ្រួសារសពមកទទួលយកទេ មន្ទីរពេទ្យអាចប្រគល់សាកសពជូ អាជ្ញាធរមានសមត្ថកិច្ច ឬវត្តអារាម ឬសមាគមសាសនា ដើម្បីរៀបចំពីធីបុណ្យសព និងចាត់ចែងបូជា ឬបញ្ចុះសពអោយបានសមរម្យតាមទំនៀមទំលាប់ប្រពៃណី។

2. **ការរៀបចំសព ការតំកល់សព និងពីធីបុណ្យសពនៅគេហដ្ឋាន**

ការគ្រប់គ្រងសពដែលសម្លាប់នៅផ្ទះ ជាបន្ទុករបស់ក្រុមគ្រួសារសព។ ក្នុងការរៀបចំសពបន្ទាប់ពីស្លាប់ភ្លាម និងការរក្សារតំកល់សព ក្រុមគ្រួសារអាចស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន ឬបុគ្គលិកសុខាភិបាល។ ក្នុងការរៀបចំពីធីបុណ្យសព និងចាត់ចែងបូជា ឬបញ្ចុះសព ក្រុមគ្រួសារសពត្រូវរៀបចំផ្ទាល់ ឬអាចស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន វត្តអារាម ឬសមាគមសាសនា ដើម្បីអោយរៀបចំអោយបានសមរម្យតាមទំនៀមទំលាប់ប្រពៃណីសាសនា។

3. **ការបូជា ឬបញ្ចុះសព**

4. **ការគ្រប់គ្រង និងសម្អាតបរិស្ថាន នៅមន្ទីរពេទ្យ គេហដ្ឋាន ទីតាំងបូជា ឬបញ្ចុះសព**

ដើម្បីជាយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានធ្វើការយ៉ាងសកម្មជាមួយក្រសួងសុខាភិបាលក្នុងការអនុម័ត និងចេញវិធានការផ្សេងៗក្នុងការទប់ស្កាត់ការកើនឡើងចំនួនអ្នកឆ្លងនៅក្នុងសហគមន៍ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១។

តាមរយៈសេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការបូជាសពអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ចុះថ្ងៃទី ១១ កក្កដា ឆ្នាំ២០២១ អនុញ្ញាតអោយមន្ត្រីសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញក្រោយពីមន្ត្រីសុខាភិបាលបានវេចខ្ចប់សពអ្នកជំងឺកូវីដ-១៩ បានត្រឹមត្រូវលក្ខណៈបច្ចេកទេសរួចរាល់ ក្រុមគ្រួសារអាចទទួលយកសពទៅបូជាជាទីកន្លែងដែលបានកំណត់មានដូចជា

- វត្តអង្គតាមិញ ស្ថិតនៅភូមិគោកចំបក់ សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ
- វត្តគោកបញ្ជាន់ ស្ថិតនៅផ្លូវវេងស្រេង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ
- វត្តជង្គង់ម្លូ ស្ថិតនៅភូមិព្រៃវៀង សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល
- វត្តក្រាំងធ្នង់ ស្ថិតនៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ

ចំណែកក្រុមគ្រួសារនៃសពអ្នកជំងឺកូវីដ-១៩ ត្រូវបានអនុញ្ញាតអោយចូលរួមកម្មវិធីបុណ្យសពបានត្រឹមតែ ១០នាក់ប៉ុណ្ណោះ ដោយអនុវត្តអោយបានត្រឹមត្រូវតាមវិធានការសុខាភិបាល។

### ២.២.៥ ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ

- រាល់កាកសំណល់វេជ្ជសាស្ត្រ ដែលមានក្នុងអំឡុងពេលនៃការថែទាំងអ្នកជំងឺកូវីដ-១៩ ត្រូវតែអនុវត្តដូចគ្នាតាមនីតិវិធីប្រតិបត្តិស្តង់ដារនៃការចោលសំណល់ឆ្លងរោគរបេង និងមេរោគអេដស៍
- ប្រសិនបើកាកសំណល់ត្រូវយកចេញពីមូលដ្ឋានសុខាភិបាល វាជាការសំខាន់ណាស់ដែលត្រូវយល់ដឹងថាតើកាកសំណល់នោះនឹងត្រូវគេធ្វើប្រព្រឹត្តិសម្លាប់មេរោគ និងកម្ទេចចោលនៅទីកន្លែងណា និងយ៉ាងដូចម្តេច។

## ២.៣ ការគ្រប់គ្រង និងការវាយតម្លៃពីហានិភ័យរបស់បុគ្គលិកថែទាំសុខភាព

- ➢ បុគ្គលិកថែទាំសុខភាពដែលផ្តល់ការថែទាំងដោយផ្ទាល់ដល់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវតាមដានអាការៈរោគសញ្ញាដោយខ្លួនឯង (ឧទាហរណ៍ គ្រុនក្តៅ ក្អក ហៀរសំបោរ ដង្ហើមខ្លី) និងត្រូវធ្វើការវាយតម្លៃពីហានិភ័យ ប្រសិនបើគាត់មានទាក់ទងនិងការប្រឈម និងវីរុស
- ➢ មូលដ្ឋានសុខាភិបាលអាចប្រើឧបករណ៍វាយតម្លៃពីហានិភ័យទាក់ទងនឹងជំងឺកូវីដ-១៩ របស់អង្គការសុខភាពពិភពលោក សម្រាប់បុគ្គលិកថែទាំសុខភាពដើម្បីវាយតម្លៃកម្រិតហានិភ័យ។

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវបានចាត់ទុកថាមានការប្រឈមហានិភ័យខ្ពស់

| សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ | សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ |
|---|---|
| • បញ្ឈប់រាល់សកម្មភាពទាក់ទងជាមួយអ្នកជំងឺក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩<br>• ធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្នុងកន្លែងដែលបានរៀបចំ<br>• ត្រូវធ្វើតេស្តវីរុសកូវីដ-១៩ | • ផ្តល់ការបណ្តុះបណ្តាលឡើងវិញពីការបង្ការ និងទប់ស្កាត់ការចម្លងរោគសម្រាប់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាល រួមមានស្តង់ដា និងការប្រុងប្រយ័ត្នដាក់ដាច់ដោយឡែក និងការប្រើប្រាស់ឧបករណ៍ការពារខ្លួនអោយបានត្រឹមត្រូវ<br>• ផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមដល់បុគ្គលិកសុខាភិបាល ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ឬអំឡុងពេលឈឺ ប្រសិនបើគាត់ក្លាយជាអ្នកជំងឺកូវីដ-១៩<br>• ផ្តល់ការទូទាត់ជូនបុគ្គលិកសុខាភិបាលសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬឈឺ (ប្រសិនបើមានប្រាក់បៀវត្សប្រចាំខែ) ឬ |

| | |
|---|---|
| | បន្តកិច្ចសន្យាសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬមានជំងឺ។ |

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវចាត់ទុកថាមានហានិភ័យទាប

| សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ | សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ |
|---|---|
| • កត់ត្រាសម្រាប់ ១៤ថ្ងៃពីថ្ងៃបានប៉ះពាល់ចុងក្រោយជាមួយអ្នកជំងឺកូវីដ-១៩<br>• ទាក់ទងទៅមូលដ្ឋានសុខាភិបាលក្នុងករណីមន្ត្រីសុខាភបាលនោះមានកើតនូវរោគសញ្ញា ដែលអាចសន្មតថាជាជំងឺកូវីដ-១៩ | • ពង្រឹងការប្រុងប្រយ័ត្នស្តង់ដារ និងការប្រុងប្រយ័ត្នលើការដាក់ដាច់ដោយឡែក និងការប្រើឧបករណ៍ការពារខ្លួនត្រឹមត្រូវ ដល់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាលទាំងអស់ |

## ២.៤ ការធ្វើចត្តាឡីស័ក

អ្នកធ្វើចត្តាឡីស័ក (ការដាក់ខ្លួនដាច់ដោយឡែក) ពីព្រោះអ្នកមានទំនាក់ទំនងផ្ទាល់ជិតស្និតជាមួយអ្នកដែលមាន ឬអាចមានជំងឺកូវីដ-១៩ ។ ចំពោះបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬប្រយោងជាមួយអ្នកមានផ្ទុកមេរោគ ឬអ្នកជំងឺគឺត្រូវៈ

- **តាមដានសុខភាពរបស់អ្នកនៅពេលធ្វើចត្តាឡីស័ក**
  - រោគសញ្ញា និងអាការៈនានារបស់ជំងឺកូវីដ-១៩ អាចរួមមានគ្រុន ឬរងា ដកដង្ហើមមិនដល់គ្នា ឬពិបាកដកដង្ហើម អស់កម្លាំង ឈឺសាច់ដុំ ឬឈឺពេញខ្លួន ឈឺក្បាល បាត់បង់ការដឹងក្លិន ឬរសជាតិ ក្នុងពេលថ្មីៗ ឈឺបំពង់ក តឹងចម្រុះ ឬហៀរសំបោរ ចង្អោរ ឬក្អួត ឬរាករូស។
  - ប្រសិនបើមានចេញរោគសញ្ញាដូចខាងលើ គឺត្រូវតេស្តរកកូវីដដោយខ្លួនឯង បើចេញលទ្ធផលវិជ្ជមាន ត្រូវដាក់ខ្លួនដាច់ដោយឡែកភ្លាមៗ និងធ្វើការជូនដំណឹងទៅកាន់ស្ថាប័នមានសមត្ថកិច្ចដើម្បីទទួលបានសេវានៃការព្យាបាលដោយមិនគិតថ្លៃ ឬជូនដំណឹតទៅកាន់ក្រសួងសុខាភិបាលស្នាក់នៅផ្ទះ លើកលែងតែទៅទទួលសេវាការព្យាបាល ឬធ្វើតេស្ត។
  - បុគ្គលដែលមានផ្ទុះមេរោគកូវីដ-១៩ ឬមិនកំពុងធ្វើចត្តាឡីស័កមិនត្រូវបានអនុញ្ញាតអោយចេញទៅតាមទីសាធារណៈនោះទេ ក្នុងករណីបុគ្គលនោះចេញមកទីសាធារណៈនឹងបានផ្តល់នូវផលប៉ះពាល់ដល់សុខមាភាពប្រជាជនផ្សេងទៀត បុគ្គលនោះនិងត្រូវទទួលទណ្ឌកម្មតាមស្ថានទំងន់ទោសរបស់ខ្លួន

- **ញែកខ្លួនចេញពីសមាជិកនៅក្នុងផ្ទះ**
  - នៅក្នុងបន្ទប់ដាក់លាក់មួយ ហើយនៅឆ្ងាយពីមនុស្សផ្សេងទៀតនៅក្នុងផ្ទះ ក្នុងចំងាយយ៉ាងតិច ៣ម៉ែត្រ និងប្រើប្រាស់នូវសម្ភារៈដាច់ដោយឡែកដូចជា ចាន ស្លាបព្រា....
  - ប្រើបន្ទប់ទឹកដាច់ដោយឡែក
  - បើកបង្អួច អោយកម្ដៅព្រះអាទិត្យចូលក្នុងបន្ទប់គេងអោយបានគ្រប់គ្រាន់ប្រសិនបើមាន
  - កុំចាប់ ឬប៉ះសត្វចិញ្ចឹម ឬសត្វដទៃទៀត ពេលដែលកំពុងឈឺ ឬចត្តាឡីស័ក។
- **ពាក់ម៉ាសប្រភេទបិទជិតខ្លាំង ប្រភេទពាក់ពេលវះកាត់ ឬប្រភេទដែលមានរន្ធជំនួយដកដង្ហើម។**

## ២.៥ ការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

### ២.៥.១. ទិដ្ឋភាពទូទៅនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលកំពុងដាក់អោយប្រើប្រាស់នៅកម្ពុជា សុទ្ធតែមានចំណុចខ្សោយមួយ គឺមានករណី False Negative ដែលមានន័យថា មានអ្នកផ្ទុកមេរោគកូវីដ-១៩ មួយចំនួនតូច ដែលប្រើឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ រកមិនឃើញ ហើយចេញលទ្ធផលអវិជ្ជមានទៅវិញ។ ទោះបីជាយ៉ាងណាក៏ដោយឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ទាំងនោះគឺជាឧបករណ៍យុទ្ធសាស្ត្រដែលជួយកាត់ផ្ដាច់ខ្សែបណ្ដាញចម្លងជំងឺកូវីដ-១៩ ព្រមទាំងមានអត្ថប្រយោជន៍ច្រើន ដើម្បីរួមចំណែកដល់ការគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ជាអាទិ៍មានភាពងាយស្រួលក្នុងការប្រើប្រាស់ដោយមិនតម្រូវអោយឆ្លងកាត់មន្ទីរពិសោធន៍ មានការវាយតម្លៃសមរម្យដែលអាចប្រើប្រាស់បានទូលំទូលាយ និងមានសមត្ថភាពខ្ពស់ក្នុងការរកឃើញបានឆាប់រហ័សនូវមេរោគកូវីដ-១៩ ជាពិសេស នៅពេលដែលអ្នកមានផ្ទុកមេរោគនេះកំពុងចេញរោគសញ្ញា ឬនៅពេលដែលចំនួនមេរោគកូវីដ-១៩ ដែលផ្ទុកក្នុងខ្លួនកើនឡើងខ្ពស់។ ដូច្នេះការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលត្រឹមត្រូវ និងជួយពន្លឿនការរកមេរោគកូវីដ-១៩ បាននៅក្នុងស្ថានភាពចំបាច់។

### ២.៥.២. លក្ខខណ្ឌនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការសម្រេចទទួលស្គាល់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងធានាមិនអោយមានការនាំចូលផ្ដាច់មុខនូវឧបករណ៍តេស្តរហ័សនេះទេ ព្រមទាំងធានាផ្គត់ផ្គង់ឧបករណ៍តេស្តរហ័សអោយបានគ្រប់គ្រាន់ទៅតាមបណ្ដាលរាជធានី ខេត្ត ជាពិសេសច្រកចេញ-ចូលប្រទេសនៅតាមបណ្ដាលខេត្តជាប់ព្រំដែន។ មានតែឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាល ប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់ក្នុងព្រះរាជណាចក្រកម្ពុជា ហើយដែលលទ្ធផលចេញពីការប្រើឧករណ៍តេស្តរហ័សរកអង់ទីហ្សែកូវីដ-១៩ នេះ ត្រូវបានទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាល។ គិតត្រឹមថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ នេះក្រសួងសុខាភិបាលបាន

ផ្តល់ការទទួលស្គាល់ និងអនុញ្ញាតអោយប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំនួន ៤ប្រភេទដូចខាងក្រោម៖

- ABBOTT PANBIO™ COVID19 Ag RAPID TEST DEVICE
- ROCHE SARS-CoV-2 Rapid Antigen Test 25T
- STANDARD Q COVID-19 Ag Test
- INDICAID COVID-19 Rapid Antigen Test។[៣]

បន្ថែមលើប្រភេទឧបករណ៍តេស្តរហ័សទាំង ៤ខាងលើ ក្រសួងសុខាភិបាល និងសិក្សាលើឧបករណ៍តេស្តផ្សេងទៀត ដើម្បីផ្តល់ការទទួលស្គាល់ និងការអនុញ្ញាតអោយមានការប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគោលការណ៍ ប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងភាពងាយស្រួលក្នុងការប្រើប្រាស់ ភាពឆាប់រហ័សនៃការរកឃើញលទ្ធផល និងតម្លៃទាបសមរម្យ។ គោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងសុខាភិបាល ក៏មានវិសាលភាពអនុវត្តចំពោះឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលត្រូវទទួលស្គាល់នាពេលអនាគត ដោយក្រសួងសុខាភិបាលផងដែរ។

ម៉្យាងទៀតគ្រឹះស្ថានឯកជន, ស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាលច្រកចេញ-ចូលប្រទេស រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកមន្លែងអាជីវកម្មផ្សេងៗទៀត ត្រូវបានអនុញ្ញាតអោយប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយត្រូវអនុវត្តតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងសុខាភិបាលស្តីពី គោលការណ៍នៃប្រតិបត្តិស្តីពី ការប្រើប្រាសតេស្តអង់ទីហ្សែនកូវីដ-១៩ សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាលច្រកទ្វារចេញ-ចូលប្រទេ, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងៗទៀត និងសម្រាប់បុគ្គលឯកជន។

ឧបករណ៍តេស្តរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ក្នុងករណីដូចជា៖

១. នៅពេលមានការសង្ស័យការចម្លងកូវីដ-១៩ ដើម្បីជាវិធានការតាមដាន និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩

២. នៅពេលមានការផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដើម្បីជាវិធានការស្រាវជ្រាវ និងរុករកអ្នកមានវិជ្ជមានមេរោគកូវីដ-១៩ ដទៃទៀតតាមរយៈការពាក់ព័ន្ធដោយផ្ទាល់ ឬពាក់ព័ន្ធដោយប្រយោល។ ដោយឡែកឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នេះនឹងត្រូវប្រើប្រាស់នៅតាមបណ្តាលច្រកទ្វារចេញ-ចូលប្រទេសដើម្បីជាមធ្យោបាយក្នុងការគ្រប់គ្រងអោយបានទាន់ពេលវេលានូវការនាំចូលមេរោគកូវីដ-១៩ ជាពិសេសមេរោគប្រភេទថ្មីមួយផ្សេងទៀត និងមេរោគបំលែងខ្លួនថ្មីប្រភេទផ្សេងទៀត។ ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ ក៏ត្រូវបានអនុញ្ញាតអោយប្រើប្រាស់នៅតាមផ្ទះ ឬជាលក្ខណៈឯកជន ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌសុវត្ថិភាព និងការណែនាំចាំបាច់នានា ដែលមានចែងក្នុងគោលការណ៍ណែនាំប្រតិបត្តនេះ។

វិធីសាស្ត្រនៃការប្រើប្រាស់ និងការគ្រប់គ្រងកាកសំណល់របស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវធ្វើទៅតាមការណែនាំដែលភ្ជាប់ជាមួយឧបករណ៍តេស្តរហ័សនីមួយៗ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ សម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខាភាព (Infection, Prevention and Control Guideline= IPC Guideline)។

ក្រុមគ្រូពេទ្យ រួមទាំងពេទ្យយោធា ពេទ្យការងារ ពេទ្យស្ម័គ្រចិត្ត និងគ្រូពេទ្យប្រចាំរោងចក្រ-សហគ្រាស ដែលចុះបញ្ជីក្នុងប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារ (Occupational Safety and Heath Network=OSH-NET) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកទទួលបន្ទុកធ្វើតេស្តហ័សនៅតាមស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជន ក៏ដូចជានៅតាមបណ្តាលច្រកចេញ-ចូលប្រទេស ត្រូវទទួលបានការអនុញ្ញាតអោយអនុវត្តការយកសំណាកវិភាគរកមេរោគដោយប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ប៉ុន្តែត្រូវទទួលបានការបណ្តុះបណ្តាលជាមុនអំពីរបៀបប្រើប្រាស់តេស្តរហ័សនេះ និងការគ្រប់គ្រងកាកសំណល់ដោយសុវត្ថិភាព ដោយមន្ត្រីសុខាភិបាល ឬតាមរយៈការអប់រំបណ្តុះបណ្តាលដែលផ្សព្វផ្សាយជាសាធារណៈ ពីសំណាក់ក្រសួងសុខាភិបាល។

នៅតាមទីតាំងតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ , ស្ថាប័ន និងអង្គភាពដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវរៀបចំអោយមានទីកន្លែងដាច់ដោយឡែកសម្រាប់ការធ្វើតេស្ត ទីកន្លែងដាច់ដោយឡែកសម្រាប់ការរង់ចាំលទ្ធផលនៃការធ្វើតេស្ត និងទីកន្លែងដាច់ដោយឡែកសម្រាប់អ្នកត្រូវបានរកឃើញថាមានវិជ្ជមានមេរោគកូវីដ-១៩ ក្នុងអំឡុងពេលរង់ចាំបញ្ជូនទៅទីកន្លែងព្យាបាល។

### ២.៥.៣. គោលការណ៍នៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

- **គោលការណ៍នៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ទីកន្លែងផ្តល់សេវាសុខាភិបាលឯកជនស្របច្បាប់៖** ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សម្រាប់ទីកន្លែងផ្តល់សេវាសុខាភិបាលឯកជនស្របច្បាប់ ដែលរួមមានមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងសម្ពពព្រមទាំងគ្រឹះស្ថានសុខាភិបាលឯកជនផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល។ គ្រឹះស្ថានសុខាភិបាលឯកជនត្រូវអនុវត្តតាមលក្ខខណ្ឌដោយឡែក ក្នុងការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីត១៩ ដូចខាងក្រោម៖
    - ត្រូវមានបុគ្គលិកសុខាភិបាលដែលទទួលបានការបណ្តុះបណ្តាលអំពីការយកសំណាកធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងមានទីតាំងយកសំណាកសមរម្យ
    - អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ CamLIS ឬទម្រង់ស្នើសុំពិសោធន៍ (តេស្តកូវីដ-១៩ ) របស់ក្រសួងសុខាភិបាល
    - ត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួងពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព (IPC Guideline)

- ត្រូវធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត និងមានការឈប់ព្រមពីសាមីខ្លួន
- ត្រូវមានតារាងតម្លៃធ្វើតេស្តសមរម្យដែលអាចទទួលយកបាន និងដាក់បង្ហាញជាសាធារណៈនៅគ្រឹះស្ថានសុខាភិបាលឯកជនរបស់ខ្លួន
- ត្រូវបង្ហាញលទ្ធផលវិជ្ជមាន ឬអវិជ្ជមានលើឧបករណ៍តេស្តរហ័ស ដែលមានចុះលេខកូដ ឬឈ្មោះដល់សាមីខ្លួន ដើម្បីផ្ទៀងផ្ទាត់ និងថតរូបទុកជាឯកសារ
- ក្នុងករណីឃើញអ្នកមានវិជ្ជមានមេរោគកូវីដ-១៩ ត្រូវជូនដំណឹងទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ ១២២២ សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធដោយមន្ត្រីសុខាភិបាល។

➢ **គោលការណ៍ណែនាំការប្រើប្រាស់តេស្ត រកអង់ទីហ្សែនកូវីដ-១៩ នៅតាមស្ថាននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត៖** បន្ថែមពីលើការអនុវត្តវិធានការសុខាភិបាលផ្នែកសុខាភិបាលអោយបានខ្ជាប់ខ្ជួន ដូចជា ការលាងសម្អាតដៃដោយអាល់កុល ឬជែល អនាម័យផ្លូវដង្ហើម ការវាស់កម្តៅ កាតពាក់ម៉ាស់ និងការរក្សាគម្លាតសុវត្ថិភាពបុគ្គល និងសង្គម ដែលមានភាពចាំបាច់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ , តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតប្រើប្រាស់ ដើម្បីជាយន្តការគ្រប់គ្រងផ្ទៃក្នុង ការឃ្លាំងមើល តាមដាន ទប់ស្កាត់ និងបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងចំណោមមន្ត្រី បុគ្គលិក ឬកម្មករ-និយោជិករបស់ខ្លួន ក៏ដូចជាដើម្បីស្វែងរកករណីវិជ្ជមានអោយបានឆាប់រហ័ស ក្នុងករណីសង្ស័យមានការឆ្លងមេរោគកូវីដ-១៩ នៅទីតាំងនោះព្រមទាំងស្វែងរកអ្នកដែលពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល បានទាន់ពេលវេលា និងញែកចេញពីមន្ត្រី បុគ្គលិក ឬកម្មករ-និយោជិត ដែលមិនមានការពាក់ព័ន្ធ ក្នុងគោលបំណងធានានិរន្តរភាពការងារនៅក្នុងបណ្តាញស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជនផងដែរ។

ក្នុងករណីមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជន មន្ត្រីបុគ្គលិក ឬ កម្មករ-និយោជិក នឹងត្រូវញែកជា២ក្រុម ដើម្បីធ្វើការសម្ភាស និងពិនិត្យសុខាភាពដូចជា៖

- ក្រុមទី១៖ បុគ្គលដែលមានការសង្ស័យ ឬមានរោគសញ្ញា ឬបុគ្គលដែលជាប់ពាក់ព័ន្ធជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩ ទោះជាមាន ឬគ្មានរោគសញ្ញាក៏ដោយ ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

- ក្រុមទី២៖ បុគ្គលដែលជាប់ពាក់ព័ន្ធដោយប្រយោលជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩ និងគ្មានរោគសញ្ញា និងបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងអ្នកផ្ទុកមេរោគកូវីដ-១៩ អាចរស់នៅ និងធ្វើការបានជាធម្មតា ដោយត្រូវគោរពតាមវិធានការសុវត្ថិភាពផ្នែកសុខាភិបាល

ចំពោះអ្នកមានផ្ទុកកូវីដ-១៩ ត្រូវដាក់អោយនៅដាច់ដោយឡែកពីគេ ហើយស្ថាប័ន អង្គភាពពាក់ព័ន្ធត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ ១២២២ សម្រាប់ភូមិសាស្រ្តរាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល តាមរយៈការបញ្ជូនអ្នកផ្ទុកមេរោគកូវីដ-១៩ នោះទៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធដោយមន្ត្រីសុខាភិបាល។ ចំពោះអ្នកវិជ្ជមានកូវីដ-១៩ ត្រូវធ្វើចត្តាឡីស័ក ឬនៅតាមផ្ទះអាស្រ័យលើការវាយតម្លៃកត្តាពាក់ព័ន្ធ។

វិធានការខាងលើនេះ ក៏ត្រូវអនុវត្តផងដែរ នៅពេលស្ថាប័ន និងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជនរោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀតអនុវត្តការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាលក្ខណៈផ្ទៃក្នុងប្រចាំសប្តាហ៍ ប្រចាំអឌ្ឍមាន និងប្រចាំខែលើបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពមានហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ នៃប្រព័ន្ធសុខាភិបាល (OSH NET) របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់វិស័យការងារ។

- **គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមច្រកចេញ-ចូលប្រទេស៖** ដោយផ្អែកតាមស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងវត្តមាននៃករណីនាំចូលមកក្នុងប្រទេសកម្ពុជានូវមេរោគបំប្លែងខ្លួនថ្មីចូលក្នុងសហគមន៍, ការត្រួតពិនិត្យសុខភាព និងការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវអនុវត្តចំពោះគ្រប់អ្នកដំណើរទាំងអស់ (ទោះមាន ឬគ្មានរោគសញ្ញា) ដែលចូលមកប្រទេសកម្ពុជា តាមច្រកចេញ-ចូលប្រទេស។ ចំពោះអ្នកដំណើរដែលធ្វើដំណើរចូលមកប្រទេសកម្ពុជាតាមព្រំដែនគោក និងព្រំដែនទឹក និងត្រូវបានរកឃើញថាមានលទ្ធផលអវិជ្ជមានដោយឧបករណ៍តេស្តរហ័ស ត្រូវអនុវត្តការធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក ដែលអាជ្ញាធរមូលដ្ឋានបានរៀបចំនៅច្រកព្រំដែន ចំណែកឯអ្នកដំណើរត្រូវបានរកឃើញមានលទ្ធផលវិជ្ជមាន ត្រូវបញ្ជូនទៅព្យាបាលនៅមណ្ឌលព្យាបាល ឬមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ។ ដោយឡែកចំពោះអ្នកដំណើរចូលមកប្រទេសកម្ពុជាតាមច្រកទ្វារចេញ-ចូលប្រទេស តាមផ្លូវអាកាសត្រូវបន្តអនុវត្តតាមការធ្វើតេស្តរកអង់ទីហ្សែនកូវីដ-១៩ និងតេស្ត RT-PCR។
- **គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាលក្ខណៈឯកជន៖** បុគ្គលដែលមានការសង្ស័យថាមានឆ្លងជំងឺកូវីដ-១៩ អាចប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-

១៩ ដោយខ្លួនឯង ដោយត្រូវអនុវត្តអោយបានត្រឹមត្រូវតាមវិធីសាស្ត្រនៃការប្រើប្រាស់ និងគ្រប់គ្រងកាកសំណល់របស់តេស្តរកអង់ទីហ្សែនកូវីដ-១៩ (ការណែនាំលម្អិតមានភ្ជាប់ជាមួយឧបករណ៍តេស្តរហ័សនីមួយៗ) និងត្រូវអនុវត្តតាមគោលការណ៍ណែនាំសុវត្ថិភាពផ្នែកសុខាភិបាល ដើម្បីចៀសវាងការចម្លងមេរោគកូវីដ-១៩ ជាយថាហេតុ។ សាមីខ្លួនដែលបានធ្វើតេស្តរកមេរោគកូវីដ-១៩ ដោយខ្លួនឯង ហើយរកឃើញវិជ្ជមានកូវីដ-១៩ មានកាតព្វកិច្ចជូនដំណឹងទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ ១២២២ សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបល ដើម្បីទទួលបាននូវសេវាព្យាបាលនៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធ ដោយមន្ត្រីសុខាភិបាល។[៨]

**២.៥.៤. យន្តការបន្ទាប់ពីការទទួលបានលទ្ធផលនៃការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩**

បន្ទាប់ពីការធ្វើតេស្តរហ័សស្របតាមគោលការណ៍ណែនាំដូចបានកំណត់ខាងលើ និងក្នុងករណីដែលត្រូវបានរកឃើញថាមានវិជ្ជមានមេរោគកូវីដ-១៩ , គ្រូពេទ្យ អ្នកទទួលបន្ទុកធ្វើតេស្តរហ័ស អ្នកតំណាងនៃស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ឬសាមីខ្លួនដែលបានធ្វើតេស្តរកមេរោគកូវីដ-១៩ ដោយខ្លួនឯង មានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការជូនដំណឹងជាបន្ទាន់ទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទលេខ ១២២២។ ដោយឡែកចំពោះបុគ្គលដែលបានរកឃើញវិជ្ជមានមេរោគកូវីដ-១៩ នៅតាមច្រកចេញ-ចូលព្រំដែន ត្រូវបញ្ជូនទៅកាន់ទីកន្លែងព្យាបាលជំងឺកូវីដ-១៩ ដោយឡែក នៅតាមច្រកចេញ-ចូលព្រំដែននោះ។ ហើយចំពោះបុគ្គលដែលត្រូវបានរកឃើញថាអវិជ្ជមានមេរោគកូវីដ-១៩ និងក្នុងករណីដដែលតម្រូវអោយធ្វើចត្តាឡីស័កត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងវិធានផ្នែកសុខាភិបាលជាធរមាន។

## ២.៦. ស្ថានភាពអ្នកឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា

ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១ ជាសោកនាដកម្មរបស់កម្ពុជា ដែលចាប់ផ្តើមប្រកាសពីអ្នកស្លាប់ដោយសារតែការឆ្លងជំងឺកូវីដ-១៩ ។ អ្នកស្លាប់ដំបូងនៅថ្ងៃទី ១១ មីនា ជាអ្នកបើកបររថយន្តអោយជនជាតិចិន នៅឯខេត្តព្រះសីហនុ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល។ ចាប់តាំងពីពេលនោះមក កម្ពុជាក៏ចាប់ផ្តើមកត់ត្រាអ្នកឆ្លងពីព្រឹត្តិការណ៍មួយនេះ ហើយអ្នកស្លាប់ក៏ចាប់ផ្តើមមានជាហូរហែរ។[៩]

៨. គោលការណ៍ណែនាំប្រតិបត្តិស្តីពី ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន ស្ថាប័ន និងអង្គភាពរដ្ឋមិនមែនសុខាភិបាល បណ្តាច្រកទ្វារចេញចូលប្រទេស ក្រុមហ៊ុនឯកជន រោងចក្រ សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងទៀត និងសម្រាប់បុគ្គលឯកជន ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០២១

ក្រសួងសុខាភិបាល បានចាប់ផ្តើមបង្កើតយន្តការ និងវិធានការជាបន្តបន្ទាប់គឺវិធានការ ៣កុំ ៣ការពារ និងមានការកត់ត្រារចំនួនអ្នកឆ្លងថ្មី ចំនួនអ្នកជាសះស្បើយ និងចំនួនអ្នកស្លាប់ជាបន្តបន្ទាប់របស់ដល់ការបិទបញ្ចប់ព្រឹត្តិការណ៍កូវីដ-១៩ នៅថ្ងៃទី ២០ ធ្នូ ឆ្នាំ២០២១។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា ខ្ញុំព្រះករុណាខ្ញុំមានកិត្តយស ដើម្បីទូលប្រគេន និងជម្រាបជូនចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ អោយបានជ្រាបថា ខ្ញុំព្រះករុណាខ្ញុំសម្រេចប្រកាសបញ្ចប់ព្រឹត្តិការណ៍ ២០ កុម្ភៈ ដែលយើងសម្រេចចាប់ផ្តើមជូនព្រឹត្តិការណ៍សោនាកម្មសម្រាប់ប្រទេសយើង ដោយសារជំងឺកូវីដ-១៩ ។

លោកនាយករដ្ឋមន្ត្រីរូបនេះ បានសម្តែងការចូលរួមមរណទុក្ខអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ កន្លងមកហើយតាមការសង្កេតរបស់អាជ្ញាធរសុខាភិបាល អ្នកស្លាប់ភាគច្រើនជាមនុស្សមានវ័យចំណាស់ និងមានជំងឺរ៉ាំរ៉ៃប្រចាំកាយ បន្ថែមលើការឆ្លងជំងឺកូវីដ-១៩ ។

**តារាងទី១. ចំនួនអ្នកឆ្លងសរុប អ្នកជាសះស្បើយ និងអ្នកស្លាប់ពីមួយខែ ទៅមួយខែនៃព្រឹត្តិការណ៍២០ កុម្ភៈ**

| កាលបរិច្ឆេទ | ចំនួនអ្នកឆ្លងសរុប | ចំនួនអ្នកជាសះស្បើយសរុប | ចំនួនអ្នកស្លាប់សរុប |
|---|---|---|---|
| ២០ កុម្ភៈ ២០២១ | ៣២ នាក់ | ០ នាក់ | ០ នាក់ |
| ២៨ កុម្ភៈ ២០២១ | ៨០៥ នាក់ | ៤៧៧ នាក់ | ០ នាក់ |
| ៣០ មីនា ២០២១ | ២ ៣៧៧ នាក់ | ១ ១៧៦ នាក់ | ១១ នាក់ |
| ៣០ មេសា ២០២១ | ១៣ ៤០២ នាក់ | ៥ ១៥២ នាក់ | ៩៣ នាក់ |
| ៣១ ឧសភា ២០២១ | ៣០ ០៩៤ នាក់ | ២២ ៦៣៦ នាក់ | ២១៤ នាក់ |
| ៣០ មិថុនា ២០២១ | ៥០ ៣៨៥ នាក់ | ៤៤ ១៤៣ នាក់ | ៦០២ នាក់ |
| ៣១ កក្កដា ២០២១ | ៧៧ ២៤៣ នាក់ | ៦៩ ៩៩៦ នាក់ | ១ ៣៩៧ នាក់ |
| ៣០ សីហា ២០២១ | ៩២ ៦១៦ នាក់ | ៨៨ ៤៤៣ នាក់ | ១ ៨៩២ នាក់ |
| ៣០ កញ្ញា ២០២១ | ១១២ ៦៥១ នាក់ | ១០២ ៨២៧ នាក់ | ២ ៣១៩ នាក់ |
| ៣១ តុលា ២០២១ | ១១៨ ៥២២ នាក់ | ១១៤ ៧២៧ នាក់ | ២ ៧៨៨ នាក់ |
| ៣០ វិច្ឆិកា ២០២១ | ១២០ ១៣៤ នាក់ | ១១៦ ៥០៧ នាក់ | ២ ៩៤០ នាក់ |
| ២១ ធ្នូ ២០២១ | ១២០ ៤៩៣ នាក់ | ១១៦ ៩១៧ នាក់ | ៣ ០១២ នាក់ |

( ប្រភពពីឯកសារធារណៈ Telegram Channel ផ្សាយចេញពីទិន្នន័យក្រសួងសុខាភិបាល )

យោងតាមការចុះផ្សារតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាលកម្ពុជា ចំនួនអ្នកដែលឆ្លងជំងឺកូវីដ-១៩ អ្នកជាសះស្បើយ អ្នកស្លាប់មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃក្រោយព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ រហូតមានការថយចុះម្តងបន្តិចៗរហូតឈានដល់ការប្រកាសបិទបញ្ចប់ព្រឹត្តិនៃរលកទី២នេះ។

ក្នុងអំឡុងខែកុម្ភៈចំនួនអ្នកឆ្លងសរុបមានចំនួន ៨០៥នាក់ អ្នកជាសះស្បើយចំនួន ៤៧៧នាក់ និងអ្នកស្លាប់មានចំនួន ១១នាក់។ នៅក្នុងអំឡុងខែមីនាចំនួនអ្នកឆ្លងមានការកើនឡើងរហូតដល់ ២ ៣៧៧នាក់ អ្នកជាសះស្បើយចំនួន ១ ១៧៦នាក់ អ្នកស្លាប់មានចំនួន ៩៣នាក់។

នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០២១ ចំនួនអ្នកឆ្លងសរុបមានចំនួន ៧៧ ២៤៣ នាក់ ក្នុងនោះអ្នកថ្មីមានចំនួនរហូតដល់ទៅ ២៦ ៨៥៨នាក់ អ្នកជាសះស្បើយមានចំនួន ៦៩ ៩៩៦នាក់ ក្នុងនោះអ្នកដែលជាសះស្បើយថ្មីមានចំនួនត្រឹមតែ ២៥ ៨៥៣នាក់ប៉ុណ្ណោះ ចំណែកចំនួនអ្នកស្លាប់សរុបមានចំនួន ១ ៣៩៧នាក់ ដែលក្នុងនោះអ្នកស្លាប់ក្នុងអំឡុងខែ កក្កដាមានចំនួនរហូតដល់ទៅ ៧៩៥នាក់ក្នុងមួយខែ ដែលទិន្នន័យជាទិន្នន័យដែលមានការឆ្លង និងស្លាប់ខ្ពស់បំផុតក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈនេះ។

តែទោះជាយ៉ាងណាក្តីទិន្នន័យនៃការឆ្លង និងស្លាប់មានថយចុះបន្តិចម្តងៗ រហូតដល់ថ្ងៃទី ២០ ធ្នូ ២០២១ មានការប្រកាសបិទព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ប៉ុន្តែវិធានការសុខាភិបាលនៅតែមានការរឹតបន្តឹងដដែល។

**រូបភាពទី១. ដ្យាក្រាមចំនួនអ្នកឆ្លងថ្មី អ្នកជាសះស្បើយ និងអ្នកស្លាប់ក្នុងមួយខែៗ នៃព្រឹត្តិការណ៍២០ កុម្ភៈ**




| | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ២០ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|
| អ្នកឆ្លងថ្មី | 1572 | 11025 | 16692 | 20291 | 26858 | 15373 | 20035 | 5871 | 1612 | 289 |
| អ្នកជាសះស្បើយ | 699 | 3976 | 17484 | 21507 | 25853 | 18447 | 14384 | 11900 | 1780 | 296 |
| អ្នកស្លាប់ | 11 | 82 | 121 | 388 | 795 | 495 | 427 | 469 | 152 | 65 |

(ប្រភពពីឯកសារធារណៈ Telegram Channel ផ្សាយចេញពីទិន្នន័យក្រសួងសុខាភិបាល)

**រូបភាពទី២. ដ្យាក្រាមចំនួនអ្នកឆ្លងថ្មី អ្នកជាសះស្បើយ និងអ្នកស្លាប់ក្នុងមួយសប្តាហ៍មុនក្រោយនៃព្រឹត្តិការណ៍២០ កុម្ភៈ**




(ប្រភពពីឯកសារធារណៈ: Telegram Channel ផ្សាយចេញពីទិន្នន័យក្រសួងសុខាភិបាល)

## ២.៧ ការចាក់វ៉ាក់សាំង

ក្រសួងសុខាភិបាលបានរៀបចំ ផែនការជាតិស្តីពីការចាក់វ៉ាក់សាំងកូវីដ-១៩ (NDVP) និងបានចាប់ផ្តើមធ្វើផែនការគ្រប់ចំណុចទាំងអស់ ដើម្បីត្រៀមចាក់វ៉ាក់សាំងថ្មីនេះដូចជា ការរៀបចំជាលិខិតបទដ្ឋានគតិយុត្ត ការរៀបចំភស្តុភារ ការពិនិត្យតាមដានសុវត្ថិភាព ការកំណត់ក្រុមអាទិភាព សម្រាប់ចាក់វ៉ាក់សាំង ព្រមទាំង ការ អប់រំផ្សព្វផ្សាយនិងការ បំផុសចលនាសហគមន៍ជាដើម។

ដោយសារតែភ្លាមៗគេពុំមានវ៉ាក់សាំងក្នុងចំនួនដូសគ្រប់គ្រាន់សម្រាប់ប្រជាជនទាំងអស់ ដែលនេះក៏ជាអ្វីដែលកំពុងកើតមាននៅក្នុងប្រទេសផ្សេងទៀតក្នុងសកលលោកដែរ នោះរដ្ឋាភិបាលគ្រោងនឹងចាក់វ៉ាក់សាំងជាដំណាក់កាលៗ។ ក្រុមអាទិភាព គឺជាក្រុមដែលត្រូវទទួលបានការចាក់វ៉ាក់សាំងមុនគេ។ ប្រទេសកម្ពុជាមានអាជ្ញាធរនិយ័តកម្មថ្នាក់ជាតិមួយដែលស្ថិតនៅក្រោមក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាលនឹងចេញការអនុញ្ញាតសម្រាប់ការប្រើប្រាស់បន្ទាន់ដល់វ៉ាក់សាំងណាមួយក្រោយពេលពិនិត្យលើសុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងទិន្នន័យដែលបានពីអាជ្ញាធរនិយ័តកម្មដទៃទៀតឬក្រោយពេលដែលវ៉ាក់សាំងនេះបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់បន្ទាប់ពីអង្គការសុខភាពពិភពលោក។ ក្រោយពេលដាក់ឱ្យប្រើប្រាស់នឹង

មានការបន្តពិនិត្យតាមដានវ៉ាក់សាំងដើម្បីធានាថាវ៉ាក់សាំងទាំងនេះពិតជាមានប្រសិទ្ធភាព ពេញលេញសម្រាប់អ្នកដែលបានចាក់វ៉ាក់សាំងនេះរួច។

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ មានគោលបំណងធានាអោយយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ដើម្បីឈានទៅកាត់បន្ថយការចម្លង ភាពធ្ងន់ធ្ងរនៃជំងឺ មរណៈភាពណ និងផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច។ ដើម្បីអោយយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ រាជរដ្ឋាភិបាលបានបង្កើត គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស មួយដើម្បីទទួលខុសត្រូវរួមលើយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះដែលមានរចនាសម្ព័ន្ធ និងតួនាទីដូចខាងក្រោមះ

**រូបភាពទី៣. រចនាសម្ព័ន្ធគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**




( ប្រភពះនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ )

- **តួនាទី ភារកិច្ចរបស់មន្ទីរពេទ្យថ្នាក់ជាតិ**
  - ជ្រើសរើសអ្នកសម្របសម្រួលមន្ទីរពេទ្យដែលត្រូវធ្វើការងារយ៉ាងជិតស្និតជាមួយអ្នកសម្របសម្រួលដទៃទៀត និងក្រុមប្រធានក្រុមចាក់វ៉ាក់សាំង
  - បូកសរុបការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការចាក់អោយប្រជាជនគោលដៅ
  - គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗដែលរក្សាទុកបន្ទាប់ពីទទួលបានពីឃ្លាំងឱសថកណ្តាល ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
  - ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
  - ធានាថាធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) គ្រប់គ្រាន់ដើម្បីដំណើរការចាក់វ៉ាក់សាំង
  - ចុងបញ្ចប់នៃថ្ងៃនីមួយៗ មន្ទីរពេទ្យត្រូវត្រួតពិនិត្យ (ការគ្រប់ដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារ) និងប្រាកដថាសកម្មភាពអនុវត្តបានត្រឹមត្រូវតាមបច្ចេកទេស
  - ធានាថាបានរបាយការណ៍ជាបន្ទាន់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងទៅនឹងហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង ព្រមទាំងពិនិត្យព្យាបាល និងសង្គ្រោះបន្ទាន់ និងការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
  - ប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុកទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការមិនអោយហួស ៧ថ្ងៃបន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានបញ្ចប់។
- **តួនាទី ភារកិច្ចរបស់មន្ត្រីសុខាភិបាលរាជធានី ខេត្ត**
  - ជ្រើសរើសអ្នកសម្របសម្រួលមន្ទីរសុខាភិបាលខេត្តដែលនឹងត្រូវធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលដទៃទៀត និងប្រធានក្រុមចាក់វ៉ាក់សាំង
  - បូកសរុបការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់ស្រុកប្រតិបត្តិនីមួយៗ
  - គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និងការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈបរិក្ខារគ្រប់គ្រាន់តាមចំនួនប្រជាជនគោលដៅ
  - ប្រមូលធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត

- ចុងបញ្ចប់នៃថ្ងៃនីមួយៗ មន្ទីរសុខាភិបាលរាជធានី ខេត្តត្រូវសួរនាំ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអំពីការបំពេញការងារ (ការគ្រប់ដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារ) និងប្រាកដថាសកម្មភាពកែតម្រូវបានធ្វើ (បើចាំបាច់)
- ធានាថាបានរាយការណ៍ជាបន្ទាន់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងទៅនឹងហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង ព្រមទាំងពិនិត្យព្យាបាល និងសង្គ្រោះបន្ទាន់ និងការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
- ប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុកទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការមិនអោយហួស ៧ថ្ងៃបន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានបញ្ចប់។

❖ **តួនាទី-ភារកិច្ចរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ**

- ជ្រើសរើសអ្នកសម្រាប់សម្រួលការិយាល័យសុខាភិបាលស្រុកប្រតិបត្តិដែលត្រូវធ្វើការងារជិតស្និទ្ធជាមួយអ្នកសម្របសម្រួលខេត្ត និងប្រធានក្រុមចាក់វ៉ាក់សាំង
- ប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់កន្លែងចាក់វ៉ាក់សាំងនីមួយៗ
- បើការចុះឈ្មោះត្រូវបានធ្វើចប់សព្វគ្រប់ក្នុងតំបន់គ្រប់ដណ្តប់របស់ខ្លួន ត្រូវធ្វើកាប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងដែលត្រូវការតាមចំនួនប្រជាជនគោលដៅដែលបានចុះឈ្មោះ៖
  - ➢ ប្រជាជនម្នាក់ត្រូវការវ៉ាក់សាំង ២ដូស (លើកលែងករណីពិសេស ដែលមានណែនាំបន្ថែម) និង
  - ➢ អាត្រាខាតបង់នៃវ៉ាក់សាំងកូវីដ-១៩ ១៥%
- បើការចុះឈ្មោះពុំទាន់ចប់សព្វគ្រប់ទេ ត្រូវធ្វើការប៉ាន់ប្រមាណចំនួនដូសតាមចំនួនប៉ាន់ស្មាននៃប្រជាជនគោលដៅដោយប្រើជំរឿន ឬស្ថិតិរបស់រដ្ឋបាលមូលដ្ឋាន និងដោយប្រើប្រាស់សន្មតដូចខាងលើ
- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗ ដែលរក្សាទុកបន្ទាប់ពីទទួលបានពីមន្ទីរសុខាភិបាលរាជធានីខេត្ត ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
- ធានាថា រាល់កន្លែងចាក់វ៉ាក់សាំងទាំងអស់មានការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈបរិក្ខារផ្សេងៗគ្រប់គ្រាន់ទៅតាមចំនួនប្រជាជនគោលដៅ
- ប្រមូលធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត

- ចុងបញ្ចប់នៃថ្ងៃនីមួយៗ ត្រូវសួរនាំប្រធានក្រុមទាំងអស់ពីការបំពេញការងារ (ការគ្រប់ដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀត) និងប្រាដកថាសកម្មភាពកែតម្រូវបានធ្វើ (ចាំបាច់)
- ត្រូវប្រាដកថា ចំនួនប្រអប់សុវត្ថិភាពដែលពេញត្រូវប្រមូល និងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងត្រូវបានបញ្ជូនទៅកន្លែងដុត (ឡដុងកម្តៅលើសពី ៨០០អង្សាសេ ឬស្នេរីលផេរ) ដែលត្រូវបានកំណត់ចំនួន ឬបរិមាណជាគីឡូក្រាមជារៀងរាល់ថ្ងៃ
- ធានាថា បានរាយការណ៍ជាបន្ទាន់ទៅមន្ទីរសុខាភិបាលក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
    - ➢ ហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំងធ្ងន់ធ្ងរ និងបញ្ជូនទៅត្រួតពិនិត្យបន្តនៅមន្ទីរពេទ្យ
    - ➢ ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
- ត្រូវប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុកទៅមន្ទីរសុខាភិបាលមិនអោយហួស ៥ថ្ងៃបន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវបានបញ្ចប់។

❖ **តួនាទី-ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន**

- សម្របសម្រួលនីតិវិធីនៃការចុះឈ្មោះប្រជាជនគោលដៅជាមុន តាមប្រព័ន្ធអេឡិចត្រូនិច (KhmerVacc) ដែលបានណែនាំដោយក្រសួងសុខាភិបាល
- គាំទ្រដល់ការរៀបចំកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ពិសេសការរៀបចំច្រកចេញ ចូល និងកន្លែងរង់ចាំ
- សម្របសម្រួលនៅកន្លែងចាក់វ៉ាក់សាំងអោយមានសន្តិសុខនិងសណ្តាប់ធ្នាប់ល្អ ដោយជួយរៀបចំចរន្តអ្នកមកទទួលវ៉ាក់សាំង អោយរក្សាគម្លាតសង្គម និងជៀសវាងភាពកកកុញគ្នា
- ធានាសន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
- គាំទ្រ និងធានាសុវត្ថិភាពមន្ត្រីសុខាភិបាល ដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (ចាក់វ៉ាក់សាំង ការរក្សាទុកដាក់វ៉ាក់សាំង អង្កេតស្រាវជ្រាវហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង គាំទ្រផ្នែកយុត្តាធិការក្នុងករណីមានហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយពេលចាក់វ៉ាក់សាំង
- គាំទ្រដល់ការប្រាស្រ័យទាក់ទងហានិភ័យ។[៩]

កម្ពុជាប្រកាសចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២១ ហើយការចាក់វ៉ាក់សាំងនេះត្រូវធ្វើជាដំណាក់កាលៗទៅតាមចំនួនវ៉ាក់សាំងដែលទទួលបាន។ ការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រភេទ SINOPHARM ដែលកម្ពុជាទទួលបានពីចិនចំនួន ៦០ម៉ឺនដូសត្រូវធ្វើឡើងនៅមន្ទីរពេទ្យ

ចំនួន៥ នៅក្នុងតំបន់រាជធានីភ្នំពេញ មានមន្ទីរពេទ្យចំនួន ៤គឺបើកសម្រាប់ជនស៊ីវិល និងមន្ទីរពេទ្យមួយទៀតសម្រាប់តែកងកម្លាំងប្រដាប់អាវុធ។

ក្រសួងសុខាភិបាលចាប់ផ្ដើមចាក់វ៉ាក់សាំង ៣០ម៉ឺនដូសនៅមន្ទីរពេទ្យរដ្ឋចំនួន៤មានដូចជាៈ[៩]

- មន្ទីរពេទ្យកាល់ម៉ែត្រសម្រាប់ឥស្សរជនជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ
- នៅមន្ទីរពេទ្យព្រះអង្គឌួង សម្រាប់ឥស្សរជនជាអនុលេខាធិការ ឬមានឋានៈស្មើ
- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សម្រាប់ឥស្សរជនជាអភិបាលរាជធានីខេត្ត
- នៅមន្ទីរពេទ្យកុមារជាតិ សម្រាប់អ្នកសារព័ត៌មាន។

ដោយឡែកនៅមន្ទីរពេទ្យព្រះកេតុមាលា ឬមន្ទីរទាហាន និងបើកចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូហ្វាមជូននាយទាហានជាន់ខ្ពស់ ថ្នាក់ដឹកនាំ ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធាពលខេមរភូមិន្ទ ដើម្បីបង្ហាញពីប្រសិទ្ធភាពវ៉ាក់សាំងរបស់ចិន។

ដើម្បីអោយការចាក់វ៉ាក់សាំងនេះប្រព្រឹត្តិទៅតាមពិធីសារ ស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងសុខាភិបាល កាលពីថ្ងៃទី៩ ខែកុម្ភៈ បានណែនាំជាអាទិ៍ៈ ក្នុងដំណាក់កាលទី១នេះ ចំនួនអ្នកដែលស្ម័គ្រចិត្ត ចាក់វ៉ាក់សាំងកូវីដ-១៩ គឺនឹងត្រូវកំណត់មានចំនួនត្រឹមតែ ១៤៩ ៥០០នាក់ ដែលនឹងត្រូវប្រើប្រាស់វ៉ាក់សាំង ស៊ីណូហ្វាម ដែលទទួលបានពីសាធារណរដ្ឋប្រជាមានិតចិន ហើយដែលបានប្រកាសចាប់ផ្តើមចាក់ចាប់ពីថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២១។ ក្រសួងសុខាភិបាលបានបន្ថែមថា ដោយអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែនក្នុងការផ្តល់នូវទំនុកចិត្ត ជូនដល់បងប្អូនប្រជាពលរដ្ឋមានថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល និងបុត្រាបុត្រី ជាឥស្សរជនជាន់ខ្ពស់ អភិបាលរាជធានីខេត្ត ថ្នាក់ដឹកក្រសួងសុខាភិបាល ក្រុមគ្រូពេទ្យជួរមុខទាំងអស់ អ្នកនាំពាក្យនៅតាមក្រសួងស្ថាប័ននានា និងអ្នកសារព័ត៌មានដែលមានអាយុពី ១៨ឆ្នាំ ដល់ ៥៩ឆ្នាំជាដំបូងគេទៅតាមទីកន្លែងបានប្រកាស។

ចំណែកក្រុមមនុស្សដែលត្រូវបានអនុញ្ញាតអោយចាក់ជាបន្តបន្ទាប់ នៅពេលបន្តបន្ទាប់ទៀតនោះគឺកម្លាំងជំនាញនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាជ្ញាធរថ្នាក់ក្រោមជាតិជួរមុខ រួមមានថ្នាក់ខេត្ត ស្រុក ខណ្ឌ សង្កាត់ ឃុំ ភូមិ និងកងកម្លាំងមានសមត្ថកិច្ច ប៉ូលីសជួរមុខ ដែលកំពុងសកម្មក្នុងការជួយអន្តរាគមន៍ នៅក្នុងការប្រយុទ្ធនឹងកូវីដ-១៩ និងប៉ូលីសដែលនៅឈរជើងតាមព្រំដែន និងត្រូវចាក់ជូនដោយក្រសួងការពារជាតិ។

៩. នីតិវិធីប្រតិបត្តិការស្តង់ដារស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ខែ មិថុនា ឆ្នាំ ២០២១

អង្គការសុខភាពពិភពលោក (WHO) បានទទួលស្គាល់ការប្រើប្រាស់ជាបន្ទាន់ នៃវ៉ាក់សាំងកូវីដ-១៩ SINOVAC កាលពីថ្ងៃទី ០១ មិថុនា ឆ្នាំ ២០២១។ ការទទួលស្គាល់នេះ បើកផ្លូវអោយវ៉ាក់សាំងទី២ដែលផលិតនៅប្រទេសចិនត្រូវបានចែកចាយនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍។ បូករួមទាំងវ៉ាក់សាំង SINOVAC នេះមានវ៉ាក់សាំងកូវីដ-១៩ ចំនួន ៦ប្រភេទហើយដែលត្រូវបានទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក។ កន្លងមកអង្គការសុខភាពពិភពលោក បានផ្តល់ការចុះបញ្ជីការប្រើប្រាស់បន្ទាន់ដល់វ៉ាក់សាំងកូវីដ-១៩ ចំនួន ៥ប្រភេទរួមមាន Pfizer-BioNTech, Moderna, Jonhson&Jonhson, Astrezeneca, និង Sinovac។ អង្គការសុខភាពពិភព លោកនិងយូនីសេហ្វគឺដៃគូអង្គការសហប្រជាជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។ អង្គការសុខភាពពិភពលោក និងយូនីសេហ្វក៏ជាដៃគូសំខាន់ៗរបស់អង្គការសហប្រជាជាតិដែលផ្តល់ការគាំទ្រដល់ការត្រៀម និងការចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុង ប្រទេស កម្ពុជាផងដែរ។ អង្គការទាំងពីរនេះកំពុងផ្តល់ដំបូន្មាន និងការគាំទ្របច្ចេកទេស សំខាន់ៗ ដូចជា ការរៀបចំយុទ្ធសាស្ត្រ ការធ្វើផែនការ ខ្សែច្រវាក់ ផ្គត់ផ្គង់ ការកសាងសមត្ថភាព ការអប់រំផ្សព្វផ្សាយសុវត្ថិភាព និងការឃ្លាំមើល និងការពិនិត្យតាមដានជាដើម។ រាជរដ្ឋាភិបាលកម្ពុជាគឺជា អ្នកធ្វើការសម្រេចចិត្តចុងក្រោយ។

ទីភ្នាក់ងារអង្គការសហប្រជាជាតិ មិនចូលរួមផ្ទាល់នៅក្នុងការធ្វើលទ្ធកម្មវ៉ាក់សាំងដែលបានពីកិច្ចសហប្រតិបត្តិការ ឬកិច្ចព្រមព្រៀងទ្វេភាគីនោះឡើយ។ ប៉ុន្តែយូនីសេហ្វនឹងជួយធ្វើលទ្ធកម្មវ៉ាក់សាំងតាមរយៈយន្តការកូវ៉ាក់ដែលជាយន្តការសកល ព្រោះថាយូនីសេហ្វត្រូវបានជ្រើសរើសឱ្យបំពេញតួនាទីជាស្ថាប័នដឹកនាំការងារនេះនៅទូទាំងសកលលោកទាំងមូល។ យន្តការកូវ៉ាក់នឹងផ្តល់ឱ្យប្រទេស ដែលចូលរួមនូវវ៉ាក់សាំងដែលបានទទួលការអនុម័តឱ្យប្រើប្រាស់បន្ទាន់ពីអង្គការសុខភាពពិភពលោក។

ជាមួយនឹងការកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រ, រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងក្នុងទិញវ៉ាក់សាំងផ្ទាល់ពីប្រទេសអ្នកផលិត និងស្វែងរកជំនួយជាវ៉ាក់សាំងពីស្ថាប័នអន្តរជាតិនានា និងពីប្រទេសជាមិត្ត។ ជាផ្លែផ្ការនៃការខិតខំប្រឹងប្រែងនេះ, កម្ពុជាបានក្លាយជាប្រទេសទីមួយក្នុងចំណោមបណ្តាលប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍, ដែលទទួលបានវ៉ាក់សាំងពីស្ថាប័នកូវ៉ាក់ក៏ដូចជាទទួលបានជំនួយ មនុស្សធម៌ជាវ៉ាក់សាំងពីមិត្តចិន និងដែលបានអនុញ្ញាតអោយកម្ពុជាចាប់ផ្តើមយុទ្ធនាការជាតិចាក់វ៉ាក់សាំងនៅដើមខែ កុម្ភៈ ឆ្នាំ ២០២១។ លើសពីនេះទៅទៀត, វ៉ាក់សាំងដែលកម្ពុជាបានបញ្ជាទិញ ក៏បានមកដល់កម្ពុជាជាហូរហែរ។ រហូតមកទាល់ថ្ងៃទី ៣០ មេសា ឆ្នាំ ២០២១ កម្ពុជាទទួលបានវ៉ាក់សាំងសរុបចំនួន ៤ ០២៤ ០០០ ដូស។

គោលបំណងនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណាក់កាលទី១ គឺបង្កើតភាពស៊ាំដល់អ្នកផ្តល់សេវាជួរមុខទូទាំងប្រទេស ដែលរួមមាន បុគ្គលិកសុខាភិបាល, កងកម្លាំងប្រដាប់អាវុធ, និងមន្ត្រីសាធារណៈ ព្រមទាំងក្រុមជនងាយរងគ្រោះមួយចំនួនទៀត។ ក្នុងរយៈពេលត្រឹម ៣ខែ, គិតចាប់

ពីខែ កុម្ភៈ ដល់ខែ មេសា ឆ្នាំ២០២១ មន្ត្រីសាធារណៈជួរមុខ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋចំនួនប្រមាណជាង ១.៣ លាននាក់ ទទួលបាននូវការចាក់វ៉ាក់សាំង។

ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតអោតបាននូវភាពស៊ាំសហគមន៍នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា គឺជាវិធានការយុទ្ធសាស្ត្រគន្លឹះដ៏មានប្រសិទ្ធភាពមួយ ដែលត្រូវអនុវត្តគួបផ្សំជាមួយនឹងវិធានការចាំបាច់ផ្សេងទៀត ជាពិសេសវិធានការ ៣-កុំ និង ៣-ការពារ ដើម្បីធានាអោយកម្ពុជាអាចបន្តដំណើរអភិវឌ្ឍន៍ទៅមុខលើគន្លងនៃ ប្រក្រតីភាពថ្មី ។

## ២.៨ ចំនួនអ្នកចាក់វ៉ាក់សាំងសរុប គិតត្រឹមឆ្នាំ ២០២១

កម្ពុជាបានចាប់ផ្ដើមយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី១ នៅថ្ងៃទី១០ កុម្ភៈ ឆ្នាំ ២០២១ លើប្រជាពលរដ្ឋអាចាប់បី ១៨ឆ្នាំឡើង សម្រាប់គោលដៅ ១០លាននាក់ តាមរយៈការអនុវត្ត ផែនការមេសម្រាប់យុទ្ធនាករចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ថ្ងៃទី ៣១ មីនា ឆ្នាំ ២០២១ និងផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតបាននូវភាពស៊ាំសង្គម សេដ្ឋកិច្ចនៅកម្ពុជា នៅខែឧសភា ឆ្នាំ ២០២១។

នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០២១ សម្ដេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងសារបញ្ជាក់ពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យដែលមានអាយុចាប់ពី ១២ឆ្នាំទៅក្រោម ១៨ឆ្នាំ (កុមារ-យុវវ័យ)។ សារនេះបានបង្ហាញអំពីឆន្ទៈនយោបាយដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការការពារអាយុជីវិតប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ចំពោះមុខស្ថានភាពនៃការចម្លងនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្នផង និងការបង្កើតនូវបរិយាកាសប្រកបដោយទំនុកចិត្តផង សម្រាប់ការបើកដំណើរការឡើងវិញជាបណ្ដើរៗ នូវសកម្មភាពសង្គម សេដ្ឋកិច្ច ឆ្ពោះទៅកាន់ការបើកប្រទេសពេញលេញឡើងវិញ និងការរស់នៅប្រកបដោយ សុវត្ថិភាពរបស់ប្រជាពលរដ្ឋ ជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី។

គិតត្រឹម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ប្រទេសកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ដល់ប្រជាពលរដ្ឋដែលមានអាយុពី ១៨ឆ្នាំឡើងបានចំនួន ៧ ០៤៣ ៩៦៩នាក់ ឬស្មើនឹង ៧០,៤៤% និងដូសទី២ បាន ៤ ៦២៦ ៦៤៨នាក់ ឬស្មើនឹង ៤៦,២៦% នៃប្រជាពលរដ្ឋគោលដៅ ១០លាននាក់។ គួរកត់សម្គាល់ថា ០,៩៥% នៃប្រជាពលរដ្ឋ ៧ ០៤៣ ៩៦៩នាក់ ដែលបានស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនត្រូវបានគ្រូពេទ្យអោយចាក់វ៉ាក់សាំង ដោយសារបញ្ហាសុខភាពផ្ទាល់ខ្លួន។ រីឯផលរំខានដែលបានកើតឡើងក្រោយពេលចាក់វ៉ាក់សាំងមានចំនួន ១៥៥ករណី ក្នុងចំណោម វ៉ាក់សាំងដែលបានចាក់សរុប ៥ ៧៩៦ ១៦៤ដូស (សរុបដូសទី១ និងដូសទី២) ឬក្នុងអត្រា ២ករណី ផលរំខានក្នុងវ៉ាក់សាំង ១០០ ០០០ដូស គិតត្រឹមថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២១។[១០]

១០.ផែនការសកម្មភាពសម្រាប់ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យអាយុពី ១២ឆ្នាំទៅក្រោម ១៨ឆ្នាំ

# ជំពូកទី៣

## របកគំហើញនៃការស្រាវជ្រាវ

# ជំពូកទី៣
# របកគំហើញនៃការស្រាវជ្រាវ

ឆ្លងកាត់បទពិសោធន៍អស់រយៈពេលជិតពីរឆ្នាំនៃបរិបទកូវីដ-១៩ បានធ្វើអោយសេដ្ឋកិច្ច សង្គមកម្ពុជាជួបប្រទះនូវវិបត្តិជាច្រើន តែទោះជាយ៉ាងណាក៏ដោយក្រោមការយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចបានរួមសហការគ្នាយ៉ាងសកម្មក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ បានធ្វើអោយរលកទី២ នៃព្រឹត្តិការសហគមន៍ ២០ កុម្ភៈ មានការស្ងប់ស្ងាត់ទៅវិញ ដែលធ្វើអោយអាជីវកម្មប្រជាពលរដ្ឋកម្ពុជាបានក្រោកចេញពីហានិន័យនៃភាពក្រីក្រ និងភាពអត់ឃ្លានបានមួយកម្រិត។ តាមរយៈប្រកាស ភាពប្រក្រតីបែបគន្លងថ្មីកម្ពុជាបានបន្សាំខ្លួនជាមួយនឹងការរស់ជាមួយនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ។ ក្នុងសេចក្តីថ្លែងការក្នុងវិមានសន្តិភាពជាងមួយម៉ោងក្នុងពិធីបិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារអាយុ៦ឆ្នាំឡើង និងការចាប់ផ្តើមចាក់អោយកុមារមានអាយុ៥ឆ្នាំ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរៀបរាប់ពីវិធានការនានារបស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលកូវីដ-១៩ ។ លោកបានលើកឡើងថា ប្រជាពលរដ្ឋស្ទើរតែគ្រប់រូបបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលជាហេតុផលមួយអាចចាប់ផ្តើមបញ្ចប់ការរឹតត្បិតក្នុងប្រទេស ។ លោកបានអោយដឹងថា ប្រជាពលរដ្ឋមានអាយុចាប់ពី៦ ឆ្នាំឡើងចំនួន ១៣,៧លាននាក់បានទទួលវ៉ាក់សាំង ឬប្រហែល៨៥ភាគរយនៃប្រជាពលរដ្ឋកម្ពុជាសរុប។

ការអនុញ្ញាតអោយបើកដំណើរការឡើងវិញនូវសាលារៀនចាប់ពីបឋមសិក្សា ដល់ថ្នាក់វិទ្យាល័យនៅថ្ងៃទី ១ ខែវិច្ឆិកា ២០២១ ហើយលោកនាយករដ្ឋមន្ត្រី បានបញ្ជាក់ផងដែលថា ចាប់ពីពេលនេះតទៅ រាជរដ្ឋាភិបាលនឹងកំណត់វិធានការសុខាភិបាលតឹងរឹងលើអ្នកឆ្លងថ្មីតែប៉ុណ្ណោះ។ ការណ៍នេះបានន័យថា បើសិនជាសិស្ស អ្នកលក់ដូរ ឬកម្មកររោងចក្រមានវិជ្ជមានកូវីដ-១៩ សាលារៀន ផ្សារ និងរោងចក្រនឹងមិនត្រូវបិទទ្វារនោះទេ។ វិធានការសុខាភិបាលនឹងផ្តោតសំខាន់តែលើការធ្វើចត្តាឡីស័កអ្នកឆ្លង និងតាមស្វែងរកអ្នកពាក់ព័ន្ធក្នុងករណីបន្ទាន់ផ្សេងៗតែប៉ុណ្ណោះ។ យោងតាមប្រសាសន៍របស់លោកនៅថ្ងៃដដែល រាជរដ្ឋាភិបាលបានចំណាយថវិកាប្រហែល ២,៣លានដុល្លារក្នុងការដោះស្រាយវិបត្តិកូវីដ-១៩ ក្នុងរយៈពេលពីរឆ្នាំមកនេះ។ ក្នុងនោះរួមមានការចំណាយប្រមាណជាង ៨២១លានដុល្លារក្នុងឆ្នាំ២០២០ និងប្រមាណជាង ១,៥៣ន់លានដុល្លារក្នុងឆ្នាំ ២០២១។[១១]

១១. ខេមបូចាញ ចំណងជើង (លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនប្រកាសបើកប្រទេសឡើងវិញបន្ទាប់ពីឆ្លងកាត់ជិតពីរឆ្នាំនៃវិបត្តិកូវីដ១៩ (ចូលមើលថ្ងៃទី ៣ កក្កដា ឆ្នាំ ២០២១)

## ៣.១ ផលប៉ះពាល់លើប្រព័ន្ធសុខាភិបាល

រហូតមកទាល់បច្ចុប្បន្ននេះ វិបត្តិនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរមកពីមកលើសង្គម សេដ្ឋកិច្ចនៃសកលលោក ហើយកំពុងបន្តបង្កនូវភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់ដោយសាររលកថ្មីនៃការបំលែងខ្លួនថ្មីនៃមេរោគកូវីដ-១៩ ដែលអាចមានសមត្ថភាពចម្លងកាន់តែលឿន និងអាចមានសភាពកាន់តែកាចសាហាវព្រមទាំងបន្តនូវផលប៉ះពាល់ដល់សកម្មភាពសង្គម សេដ្ឋកិច្ចទូទៅ ជាពិសេសនោះគឺបានធ្វើអោយការផ្តល់សេវាសាធារណៈកម្ពុជាបានជួបនូវបញ្ហាប្រឈមជាច្រើនៈ

- នៅក្នុងក្របខណ្ឌតំបន់ និងថ្នាក់មូលដ្ឋាន មេរោគកូវីដ-១៩ ចេះតែបន្តរីករាលដាលពីម្នាក់ទៅម្នាក់ និងមានការកើនឡើងជារៀងរាល់ថ្ងៃ ដែលជាបញ្ហារបស់ក្រសួងសុខាភិបាលមានភាពពិបាកក្នុងការទប់ស្កាត់ និងកំណត់មុខសញ្ញាយកសំណាក់មកតេស្តជាដើម
- ការផ្ទុះកូវីដ-១៩ នាថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ២០២១ សមត្ថភាពនៃការតេស្តបញ្ជាក់វិជ្ជមានមេរោគកូវីដ-១៩ (PCR) មានតែមួយកន្លែង និងមានសមត្ថភាពតេស្តបាន ៥000 សំណាក់ក្នុងមួយថ្ងៃដែលមានន័យថា ក្រសួងសុខាភិបាលមិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រងក្នុងការទប់ស្កាត់ និងតេស្តបញ្ជាក់អោយបានទាន់ពេលវេលានោះទេ
- ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដែលបណ្តាលដោយ មន្ត្រីសុខាភិបាលមានការបែងចែកទៅតាមតំបន់ដើម្បីជាការឆ្លើយតបតម្រូវការ និងការទប់ស្កាត់អោយបានទាន់ពេលវេលា
- ព្រឹត្តិការណ៍ ២០ កុម្ភៈ បានធ្វើអោយមានការកើនឡើងនូវចំនួនមណ្ឌលចត្តាឡីស័កនៅតាមតំបន់មូលដ្ឋានជាពិសេសនៅតាមព្រំដែនចេញ ចូល រាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងបណ្តាលខេត្តផ្សេងៗទៀត ដែលតម្រូវអោយមានក្រុមគ្រូពេទ្យប្រចាំការនៅតាមមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាល។ គ្រូពេទ្យ បុគ្គលិកបម្រើការងារ នៅមន្ទីរពេទ្យ និងមណ្ឌលព្យាបាលមានចំនួន ២១ ០១៩នាក់ ក្នុងនោះរួមមានៈ វេជ្ជបណ្ឌិតឯកទេស/វេជ្ជបណ្ឌិត ១ ៤៨៦នាក់ គិលានុប្បដ្ឋាក/ឆ្មប និងបុគ្គលិកជំនាញសុខាភិបាលផ្សេងទៀត ៤ ៥៧៧នាក់ មន្ត្រី បុគ្គលិកសុខាភិបាលដទៃទៀត ៦ ០៦៣នាក់។ គ្រូពេទ្យ បុគ្គលិកប្រមាណជាង ៣ ០០០នាក់បានត្រៀមបំរុងទុកសម្រាប់ករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ។
- ជំងឺកូវីដ-១៩ ទំនងជាប៉ះពាល់ខ្លាំងលើប្រទេសដែលដែលមានប្រព័ន្ធសុខាភិបាលមិនទាន់រឹងមាំ ជាពិសេសប្រទេសកម្ពុជា។ ថ្វីត្បិតតែកម្ពុជាជាប់ជាប្រទេសដែលមានការគ្រប់គ្រងការរីករាលដាលនៃការឆ្លងជំងឺកូវីដ-១៩ បានល្អជាងគេកាលពីឆ្នាំ ២០២០ ក៏ពិតមែន តែចំនួនអ្នកស្លាប់ និងចំនួនអ្នកឆ្លងនូវតែមានការឡើងនៅក្រោយព្រឹត្តិការណ៍ ២០ កុម្ភៈ ដែលធ្វើអោយ

ក្រសួងសុខាភិបាលមានភាពមមាញឹកក្នុងការរកដំណោះស្រាយ និងចាត់វិធានការ យុទ្ធសាស្ត្រជាបន្តបន្ទាប់ ជាពិសេសគឺឆ្លើយតបនឹងសុខភាពសាធារណៈ។

- បញ្ហាកូវីដ-១៩ បានធ្វើអោយលទ្ធភាពនៃការទទួលបានសេវាសុខភាព មាតា និងទារក និងបណ្តាលអោយមានការកើនឡើងនូវចំនួនមាតា និងទារកដែលជាប្រឈមនឹងផលវិបាល ឬស្លាប់ក្នុងអំឡុងពេលមានផ្ទៃពោះ សម្រាល និងក្រោយសម្រាល។ ដែលកត្តាបានធ្វើអោយក្រសួងសុខាភិបាលមានសម្ពាធ និងការទទួលខុសត្រូវខ្ពស់ក្នុងការរក្សា និងផ្តល់ការមើលថែយ៉ាងដឹតដល់ ដល់ក្រុមងាយរងគ្រោះ។ ស្ត្រីដែលមានផ្ទៃពោះទាំងអស់រួមទាំងអ្នកដែលមានការឆ្លងមេរោគកូវីដ-១៩ ត្រូវបានបញ្ជាក់ ឬសង្ស័យថាមានជំងឺកូវីដ-១៩ ត្រូវទទួលបានការព្យាបាលដែលប្រកបដោយគុណភាពខ្ពស់ និងការថែទាំសុខាភាពផ្លូវចិត្ត។
- ការថែទាំ អ្នកជំងឺកូវីដ-១៩ ដែលមានជំងឺក្រៅក្នុងកម្រិតដែលមិនអាចវាស់ស្ទង់បាន គឺជាករណីដែលផ្តល់ផលវិបាកដល់ក្រុមគ្រូពេទ្យជំនាញក្នុងការព្យាបាល និងថែទាំ សង្គ្រោះជីវិត ជាពិសេសអ្នកដែលមាជំងឺផ្លូវដង្ហើម ជំងឺទឹកនោមផ្អែម ជំងឺសួតជាដើម
- ក្រុមគ្រូពេទ្យ មន្ត្រីសុខាភិបាលដែលជាក្រុមសង្គ្រោះជួរមុខជាក្រុមរងគ្រោះដែលអាចប្រឈមជាមួយនិងការឆ្លងជំងឺកូវីដ-១៩ នៅក្នុងករណីធ្ងន់ធ្ងរណាមួយ
- ក្រសួងសុខាភិបាល ត្រូវធានាការគ្រប់គ្រងប្រព័ន្ធអាហារ ការផ្គត់ផ្គង់ទឹកស្អាត
- បញ្ហាខ្វះគ្រឿហបរិក្ខារក្នុងការ ព្យាបាល នឹងថែទាំងអ្នកជំងឺនៅតាមតំបន់មូលដ្ឋាន
- ខ្វះធនធានក្នុងការផ្គត់ផ្គង់ក្រុមគ្រូពេទ្យ និងថ្លៃសេវាឆ្លើយតប
- ការវិវត្តិនៃប្រភេទវីរុសបំប្លែងខ្លួនថ្មីជាបន្តបន្ទាប់ ស្ថានការនេះបានផ្តល់ផលវិបាកសម្រាប់ក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដែលវិវត្តិពីការឆ្លងក្នុងកម្រិតទាបឈានមកការឆ្លងរហ័សគួរជាទីកត់សម្គាល់ ។ ការចម្លងនៃវីរុសបំលែងខ្លួនប្រភេទថ្មីពីក្ស៊ូណាទៅជាប្រភេទដែលតា ដែលមានកម្រិតនៃការឆ្លងកាន់តែរហ័ស ក្រោយមកមានការវិវត្តិទៅជាប្រភេទអូមីក្រុង ដែលជាកត្តាព្រួយបារម្ភមួយរបស់ក្រសួងសុខាភិបាល។
- បើយោងតាមអង្គការយូនីសេហ្វ និងនៃគូនានារបស់ខ្លួនបានធ្វើការវាយតម្លៃពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមក្នុងបរិបទកូវីដ-១៩ និងតាមដានសុខាមាលភាពរបស់ប្រជាជនកម្ពុជា ក្នុងចំណោមសូចនាករជាច្រើន។ នៅក្នុងការស្ទង់មតិមាន ៤៥% នៃក្មេងជំទង់ដែលត្រូវបានស្ទង់មតិ (យុវជនមានអាយុពី ១៥ឆ្នាំដល់ ១៩ឆ្នាំ) បាននិយាយថា ពួកគេព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួននៅក្នុងកំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ រីឯក្មេងជំទង់ ១៦% ផ្សេងទៀតបានលើកឡើងថា ពួកគេមានអារម្មណ៍តានតឹងក្នុងចិត្ត ឬធ្លាក់ទឹកចិត្តចាប់តាំងពីវិបត្តិកូវីដ-១៩ បានចាប់ផ្តើមឡើង។

## ៣.២ វិធានការដោះស្រាយចំពោះផលប៉ះពាល់លើវិស័យសុខាភិបាល

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាពលរដ្ឋ។ បន្ថែមលើវិធានការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះ និងជាខ្សែក្រវ៉ាត់ការពារសំខាន់ជាងគេ ដើម្បីបង្កើតអោយមានភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅការពារសុខភាពនិងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឆ្ពោះទៅបើកដំណើរការប្រទេសឡើងវិញគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺតាមគន្លងប្រក្រតីថ្មី។

### ៣.២.១ ការពង្រឹង និងពង្រីក សេវាសុខាភិបាល

គិតមកត្រឹមថ្ងៃទី៣០ កញ្ញា ឆ្នាំ ២០២១ សមត្ថភាពនៃប្រព័ន្ធសុខាភិបាលៈ

- សមត្ថភាពនៃការធ្វើតេស្តបញ្ជាក់វិជ្ជមានមេរោគកូវីដ-១៩ (PCR) ត្រូវបានបង្កើតឡើង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ ទូលំទូលាយ នៅក្នុងវិស័យសាធារណៈ និងឯកជន។
- ចំនួនមន្ទីរពិសោធន៍សម្រាប់បម្រើការធ្វើតេស្តសំណាក មានទីតាំងសរុបចំនួន ១៦ រាជធានី ខេត្ត និងមានសមត្ថភាពអាចធ្វើតេស្តចន្លោះពី ៧ ០០០ ដល់ ៨ ០០០ តេស្តក្នុងថ្ងៃ។ ក្នុងករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ មន្ទីរពិសោធន៍ទាំងនោះអាចមានលទ្ធភាពធ្វើតេស្តបានដល់ ១០ ០០០ ដល់ ១២ ០០០ តេស្តក្នុងមួយថ្ងៃ ដែលនេះមិនទាន់រាប់បញ្ចូលនូវមន្ទីរពិសោធន៍ខ្នាតតូចនៅទូទាំងប្រទេស និងផ្នែកឯកជនផង។
  - មន្ទីរពិសោធន៍នៅភ្នំពេញ មានចំនួន ០៥ ទីតាំងៈ ១. វិទ្យាស្ថានជាតិសុខភាពសាធារណៈ ២. វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ៣. មន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលជាតិផ្តល់ឈាម, ៤. មន្ទីរពិសោធន៍មន្ទីរពេទ្យព្រះកេតុលា និង ៥. មន្ទីរពិសោធន៍នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
  - មន្ទីរពិសោធន៍នៅតាមបណ្តាលខេត្ត មានចំនួន ០២ ទីតាំងៈ ១.ខេត្តប៉ៃលិន និង ២. ខេត្តពោធិ៍សាត់
- បណ្តាញមណ្ឌលចត្តាឡីស័កត្រូវបានពង្រីកនៅតាមបណ្តាលរាជធានី ខេត្ត ជាពិសេស នៅតាមបណ្តាលខេត្តនៅជាប់ព្រំដែនភាគខាងលិច រួមជាមួយនឹងការពង្រីកទីតាំងចត្តាឡីស័កក្នុងវិស័យឯកជាន (ដូចជានៅតាមសណ្ឋាគារជាដើម) និងបណ្តាលនៃការធ្វើចត្តាឡីស័កតាមលំនៅឋាន
- មន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ មានចំនួន ៧៩កន្លែង និងមណ្ឌលព្យាបាលជំងឺកូវីដ-១៩ មានចំនួន ១៤៥ កន្លែងក្នុងនោះរួមមានៈ

- ➢ គ្រែកម្រិតស្រាល ៤៣ ៧៦៥គ្រែ (នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាលមិនមែនជាសាលារៀនមានចំនួន ២៧ ៧៩៤គ្រែ និងជាសាលារៀនមានចំនួន ១ ៥៩៧គ្រែ) និងគ្រែដែលត្រូវបានត្រៀមបំរុងទុកចំនួន ១៣ ១៧៩គ្រែ
- ➢ គ្រែសង្គ្រោះបន្ទាន់កម្រិតធ្ងន់ ICU មានចំនួនសរុប ១ ៦២៦គ្រែ នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាលរដ្ឋ និងគ្រែដែលត្រូវបានត្រៀមបំរុងទុកមានចំនួន ៧០២គ្រែ
- ➢ គ្រែទំនេរនៅសល់សរុប ៥២.៩៦% ក្នុងនោះគ្រែធម្មតានៅសល់ ៥២.៩២% និងគ្រែ ICU នៅសល់ ៥៤.៥០%

- ត្រៀមបំរុងសម្ភារៈបរិក្ខារចាំបាច់នានា សម្រាប់ករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ ដូចជា ម៉ាស៊ីនផលិតអុកស៊ីហ្សែន, ឧបករណ៍តេស្ត, ឳសថ, ឧបករណ៍ការពារខ្លួន (PPE) ជាដើម
- គ្រូពេទ្យ បុគ្គលិកបម្រើការងារ នៅមន្ទីរពេទ្យ និងមណ្ឌលព្យាបាល មានចំនួន ២១ ០១៩នាក់ក្នុងនោះរួមមាន៖ វេជ្ជបណ្ឌិតឯកទេស/វេជ្ជបណ្ឌិត ១ ៤៨៦នាក់, គិលានុប្បដ្ឋាក/ឆ្មប និងបុគ្គលិកជំនាញ សុខាភិបាលផ្សេងទៀត ៤ ៥៧៧នាក់ មន្ត្រី បុគ្គលិកសុខាភិបាលដទៃទៀត ៦ ០៦៣នាក់។ គ្រូពេទ្យ បុគ្គលិកប្រមាណ ៣ ០០០នាក់ បានត្រៀមបំរុងទុកសម្រាប់ករណីមានការផ្ទុះឆ្លងរាលដាលក្នុងទ្រង់ទ្រាយធំ
- ខណៈពេល ដែលប្រទេស កម្ពុជា មានករណី កូវីដ-១៩ តិចតួច រហូត មកដល់ពេល បច្ចុប្បន្ននេះ ប្រទេស នេះ រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ មកលើ សង្គមសេដ្ឋកិច្ច ដោយសារ តែការ រាតត្បាតជាសកលនៃជំងឺនេះ។ វ៉ាក់សាំង មិនត្រឹមតែ ជួយសង្គ្រោះជីវិត និងរក្សា លំនឹង ប្រព័ន្ធសុខាភិបាលប៉ុណ្ណោះទេ វាក៏អាច ជួយ ពន្លឿនការស្តារសេដ្ឋកិច្ចឡើងវិញផងដែរ តាមរយៈការស្តារសង្គមកម្ពុជាឡើងវិញដែលអាចធ្វើឱ្យសាលារៀន និងអាជីវកម្មនានានៅតែបន្តបើកទ្វារ។ ដើម្បីឱ្យមនុស្សអាចធ្វើដំណើរបាន និងនៅជាមួយគ្រួសាររបស់ពួកគេនិងដើម្បីឱ្យកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលទាបនៅតែអាចបន្តបំពេញការងាររបស់ពួកគេ និងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនផ្សេងទៀត។

### ៣.២.២ ចំណុចយុទ្ធសាស្ត្រអាទិភាពនៃសេវា

លើសពីនេះទៅទៀតការរៀបចំយុទ្ធសាស្ត្រអាទិភាពចំនួន ៤ ក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទកូវីដ-១៩ បានចែងដូចខាងក្រោម៖

- លើកកម្ពស់ការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប ក្នុងការរស់នៅ និងក្នុងការចូលរួមក្នុងសកម្មភាពសង្គម សេដ្ឋកិច្ចតាមគន្លងប្រក្រតីថ្មី

- ពង្រឹងប្រព័ន្ធសុខាភិបាលដោយប្រសិទ្ធភាព ក្នុងការបង្ការ និងការគ្រប់គ្រងជំងឺកូវីដ-១៩ និងលើសមត្ថភាពនៃការផ្តល់សេវាព្យាបាល និងថែទាំ ជាពិសេសការស្វះស្វែងរកឱសថ វិធីសាស្ត្រ និងបច្ចេកទេសវេជ្ជសាស្ត្រថ្មី ដែលធានាដល់ការផ្តល់សេវាព្យាបាលប្រកបដោយប្រស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាពលរដ្ឋ និងរក្សាអោយបាននូវនិរន្តភាពនៃកិច្ចដំណើរការនៃសកម្មភាពសង្គម សេដ្ឋកិច្ច។
- បើកដំណើរការឡើងវិញនូវសកម្មភាពសង្គម សេដ្ឋកិច្ច ប្របកដោយសុវត្ថិភាព និងនិរន្តភាព ដោយភ្ជាប់ជាមួយវិធានការសុវត្ថិភាព វិធានការសុខាភិបាល និងវិធានការរដ្ឋបាល សង្គម សេដ្ឋកិច្ចស្របតាមកម្រិតហានិភ័យនៅតាមតំបន់ ទីតាំង និងតាមប្រភេទនៃសកម្មភាពសង្គម សេដ្ឋកិច្ចនីមួយៗ
- តាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយជាប្រចាំ នូវសភាពការណ៍នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងផលប៉ះពាល់លើសុខភាពសាធារណៈ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពសង្គម សេដ្ឋកិច្ច នៅតាមតំបន់ និងទូទាំងប្រទេស។[១២]

### ៣.២.៣ គម្រោងនៃការឆ្លើយតបរបស់ក្រសួងសុខាភិបាល

គម្រោងឆ្លើយតបបន្ទាប់ទៅនិងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា មានគោលបំណងជួយប្រទេសកម្ពុជាក្នុងការការពារ ស្រាវជ្រាវ និងឆ្លើយតបទៅនិងការគម្រោងកំហែងនៃជំងឺកូវីដ-១៩ នេះនិងពង្រឹងប្រព័ន្ធសុខាភិបាលសាធារណៈសម្រាប់ការត្រៀមជាស្រេច។ គម្រោងនេះមានសមាសធាតុបួនៈ

- សមាសធាតុទី១៖ ការស្រាវជ្រាវ និងការគ្រប់គ្រងករណីជំងឺ (Case Detection and Management) សរុបទឹកប្រាក់ US$8.5 លានដុល្លារអាមេរិក។ សកម្មភាពនៃសមាសធាតុនេះរួមមាន៖ បង្កើតនិងបង្កើនសមត្ថភាពមន្ទីរពិសោធន៍ បន្ទប់ដាក់ឱ្យនៅដោយឡែក ( Isolation) និងមជ្ឈមណ្ឌលព្យាបាល (Treatment Centers) និងផ្គត់ផ្គង់សម្ភារនិងបរិក្ខារពេទ្យ គ្រឿងសង្ហារឹម និងតម្លើងបណ្តាញទំនាក់ទំនង (Network Installation)។ វិទ្យាស្ថានជាតិសុខភាពសាធារណៈនិងត្រូវបានបង្កើនសមត្ថភាព (Upgraded), កសាងសមត្ថភាពធ្វើរោគវិនិច្ឆ័យរបស់មន្ទីរពិសោធន៍ទាំង២៥ នៅមន្ទីរពេទ្យបង្អែករាជធានីខេត្ត ហើយនិងបង្កើតបន្ទប់ដាក់ឱ្យនៅដោយឡែក និងមជ្ឈមណ្ឌលព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែករាជធានីខេត្ត ទាំង២៥។
- សមាសធាតុទី២៖ ផ្គត់ផ្គង់សម្ភារនិងបរិក្ខារពេទ្យ (Medical Supplies and Equipment) ដែលមានទឹកប្រាក់សរុប US$6.5 លានដុល្លារអាមេរិក។ សមាសធាតុនេះនិងផ្តល់ហិរញ្ញវត្ថុសម្រាប់ធ្វើលទ្ធកម្ម សម្ភារនិងបរិក្ខារពេទ្យដែលត្រូវការសម្រាប់សកម្មភាពដែលបានបរិយាយនៅក្នុងផែនការមេនៃជំងឺកូវីដ-១៩ (COVID-19 Master Plan) ដែលរួមមានការបន្តធ្វើធុរៈកិច្ច នៃសេវាសារវ័ន្តដូចជា (i) ការគ្រប់គ្រងករណីជំងឺ និង (ii) ការទប់ស្កាត់និងការបង្ការការចម្លងរោគ។ ជា

ពិសេសទៅទៀត សម្ភារដែលត្រូវធ្វើលទ្ធកម្មរួមមាន ឱសថនិងបរិក្ខារពេទ្យសម្រាប់ការគ្រប់គ្រងករណីជំងឺ និងការបង្ការការចម្លងរោគ។ សមាសធាតុនេះ ក៏និងអនុញ្ញាតឱ្យមានភាពបត់បែនក្នុងការវិភាគជន៍ធនធានសម្រាប់ទិញឱសថសារវ័ន្ត (ថ្នាំពេទ្យ និងវ៉ាក់សាំង) ហើយនិងការផ្គត់ផ្គង់សម្ភារពេទ្យទៀតផង ដោយហេតុថាភាពមាន (Availability) នៃសម្ភារ និងបរិក្ខារទាំងនោះនៅក្នុងប្រទេសអាចនិងចុះថយ ដោយសារផលប៉ះពាល់សេដ្ឋកិច្ចដែលបណ្តាលមកពីការរាតត្បាតសកលនៃជំងឺនេះ ហើយនិងយន្តការដែលមានស្រាប់គឺមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនិងតម្រូវការចាំបាច់របស់ប្រព័ន្ធសុខាភិបាលឡើយ។

- សមាសធាតុទី៣៖ ការត្រៀមជាស្រេច ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល ដែលមានទឹកប្រាក់សរុប US$3.5 លានដុល្លារអាមេរិក។ សមាសធាតុនេះនិងផ្តល់ហិរញ្ញវត្ថុសម្រាប់ធ្វើសកម្មភាពដែលទាក់ទងទៅនិងការត្រៀមជាស្រេច ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលដោយផ្អែកទៅតាមផ្សេងៗ និងសកម្មភាពនានារបស់ផែនការមេនៃជំងឺកូវីដ-១៩។ សកម្មភាពទាំងនោះរួមមាន (i) ការសម្របសម្រួលនៅថ្នាក់ជាតិ ខេត្ត និងស្រុក (ii) ការដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលប្រតិបត្តិការឆ្លើយតបបន្ទាន់ (Emergency Operation Center-EOC) រួមទាំងការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ និងការគាំទ្រសម្រាប់ការត្រៀមជាស្រេច (ដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលប្រតិបត្តិការឆ្លើយតបបន្ទាន់ ការបណ្តុះបណ្តាល និងការអភិបាល) (iii) ធនធានមនុស្សសម្រាប់អនុវត្ត ការអភិបាលគាំទ្រ និងការគាំទ្រនៅថ្នាក់ក្រោមជាតិ (iv) ផ្តល់ហិរញ្ញវត្ថុសម្រាប់ថ្លៃប្រតិបត្តិ ដូចជា ការជួលយានយន្ត ប្រេង និងថ្លៃទាក់ទងទៅនិងការងាររដ្ឋបាលសម្រាប់ការការអភិបាលគាំទ្រ និងការត្រួតពិនិត្យតាមដាន (v) គាំទ្រការស្រាវជ្រាវ (Screening) ប្រជាជនដែលចូលរួមមកក្នុងប្រទេសនៅតាមច្រកទ្វារអន្តរជាតិ (ព្រលានយន្តហោះព្រំប្រទល់ឆ្លងកាត់ ។ល។ (vi) ពង្រឹងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (Call/Hotline centers) និង (vii)ពង្រឹងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ តាមសហគមន៍ (Community- and Event- Based Surveillance)។ បន្ថែមពីនេះទៀត សមាសធាតុនេះនិងគាំទ្រដល់ (i) ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និង ការចូលរួមរបស់សហគមន៍ (ii) ការវាយតម្លៃកត្តាហានិភ័យវប្បធម៌សង្គម និងឥរិយាបទ (iii) ការផលិតនូវយុទ្ធសាស្ត្រសម្រាប់ ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និង ការចូលរួមរបស់សហគមន៍ ហើយនិងឯកសារបណ្តុះបណ្តាល (iv) ការផលិតនូវសម្ភារការប្រាស្រ័យទាក់ទង និង (vi) ការត្រួតពិនិត្យតាមដាន និងការបញ្ចូលទិន្នន័យជាភ័ស្តុតាង។
- សមាសធាតុទី៤៖ ការអនុវត្តគម្រោង និងការត្រួតពិនិត្យតាមដាន ដែលមានទឹកប្រាក់សរុប US$1.5 លានដុល្លារអាមេរិក។ ការអនុវត្តគម្រោងនេះនិងទាមទារឱ្យមានធនធានមនុស្ស និងរដ្ឋ

បាលដែលលើសពីសមត្ថភាពបច្ចុប្បន្នសម្រាប់ស្ថាប័នដែលអនុវត្តគម្រោង បន្ថែមទៅលើធនធានដែលបានកៀងគរនៅក្នុងគម្រោងលើកកម្ពស់គុណភាព និសមធម៌សុខាភិបាល។ សកម្មភាពនានានៃសមាសធាតុនេះរួមមាន (i) ការគាំទ្រការធ្វើលទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុការគាំពារបរិស្ថាន និងសង្គម ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ និងការរាយការណ៍ (ii) ការជ្រើសរើសបុគ្គលិក និងការបណ្ដុះបណ្ដាលស្ថាប័នអនុវត្តគម្រោង និងអ្នកចំនួយការបច្ចេកទេស (Consultants) និង (iii)ថវិកាសម្រាប់ប្រតិបត្តិ (Operating Costs)។

- គម្រោងឆ្លើយតបបន្ទាន់ទៅនិងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា កំពុងត្រូវបានរៀបចំនៅក្រោមក្របខណ្ឌបរិស្ថាន និងសង្គម (កបស) របស់ធនាគារពិភពលោក។ ចំពោះស្ដង់ដារបរិស្ថាន និងសង្គមទី១០ អំពីការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ ស្ថាប័នអនុវត្តគម្រោងគួរតែផ្ដល់ឱ្យអ្នកពាក់ព័ន្ធនូវព័ត៌មានដែលអាចយកមកប្រើបាន ទាន់ពេលវេលាងាយយល់ហើយធ្វើការពិគ្រោះពិភាក្សាជាមួយពួកគាត់ ដោយស្របតាមលក្ខណៈវប្បធម៌សមស្រប ហើយមិនមានការជ្រៀតជ្រែក ការបំភ្លៃព័ត៌មាន (Manipulation) ការបង្ខិតបង្ខំ (Coercion)ការរើសអើង និងការគម្រាមកំហែង។
- ការចូលរួមយ៉ាងសកម្មរបស់រាជរដ្ឋាភិបាលៈ ជំហានដំបូងដែលរដ្ឋាភិបាលកម្ពុជាប្រើដើម្បីប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ គឺការបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយសម្រាប់ប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ នៅដើមខែមេសា។ ដោយមានកិច្ចសហការជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការនេះទទួលខុសត្រូវរាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងកូវីដ១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចដែលបានណែនាំដោយអង្គការសុខភាពពិភពលោក នាពេលបច្ចុប្បន្ន គម្លាតសង្គមគឺជាវិធានការជួរមុខដ៏មានប្រសិទ្ធិភាពបំផុតក្នុងការគ្រប់គ្រងការរីករាលដាលនៃកូវីដ-១៩ ក្នុងកំឡុងពេលវ៉ាក់សាំងស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍។ រដ្ឋាភិបាលកម្ពុជាបានធ្វើតាមអនុសាសន៍របស់អ្នកជំនាញហើយបានឆ្លើយតបយ៉ាងឆាប់រហ័សចំពោះបញ្ហាទាំងនោះ។ សេចក្ដីណែនាំ និងគោលការណ៍ជាច្រើនអំពីវិធានការការពារកូវីដ១៩ រួមមានវិធានការបង្ការ ការអនុវត្តអនាម័យ ការរក្សាគម្លាតសង្គម ការធ្វើចត្តាលីស័ក និងវិធានការធ្វើដំណើរបរទេសផ្សេងទៀតត្រូវបានចេញដោយគណៈកម្មាធិការអន្តរក្រសួងសម្រាប់ការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ការយល់ដឹងអំពីជំងឺរាតត្បាតត្រូវបានលើកឡើងពាសពេញប្រទេស តាមរយៈការផ្សាយតាមបណ្ដាញសង្គមទូរទស្សន៍ វិទ្យុ និងបដាតាមផ្លូវ។ មានសំភារៈផ្សព្វផ្សាយផ្សេងៗគ្នារួមមានវីដេអូណែនាំខ្លីៗ។ គម្រោងទាំងនោះភាគច្រើនផលិតឡើងក្រោមភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ដូចជាអង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិក៏ដូចជាអង្គការសុខភាពពិភពលោកផងដែរ។

- រដ្ឋាភិបាលបានប្រឹងប្រែងពង្រីកវិសាលភាពនៃការអនុវត្តគម្លាតសង្គមដើម្បីទប់ស្កាត់ការការរីករាលដាលនៃជំងឺកូវីដ-១៩។ ឧទាហរណ៍អាជ្ញាធរបានបញ្ជាឱ្យសាលារៀននៅទូទាំងប្រទេសមានវិស្សមកាលតូចមុនកំណត់ សម្រេចចិត្តពន្យារការប្រឡងថ្នាក់ជាតិថ្នាក់ទី ៩ និងទី ១២ ឆ្នាំ ២០១៩ -២០២០ និងបញ្ឈប់រាល់គ្រឹះស្ថានអប់រំទាំងអស់ចាប់ពីថ្ងៃទី ១៦ ខែមីនា។ សាលាប្រមាណ ១៣, ៣០០ ត្រូវបានបិទទ្វាដោយការសម្រេចចិត្តនេះ។ លើសពីនេះ កន្លែងកម្សាន្តដូចជា កាស៊ីណូ រោងកុន និងកន្លែងហាត់កាយសម្ព័ន្ធសាធារណៈក៏ត្រូវបានបញ្ជាឱ្យបិទជាបណ្ដោះអាសន្នផងដែរ។ រដ្ឋាភិបាលក៏បានពន្យាពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ ២០២០ (តាមប្រពៃណីនៅពាក់កណ្ដាលខែមេសា) ដើម្បីការពារការប្រាស្រ័យសង្គម និងកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគកូវីដ -១៩ ។ ទោះបីមានការរិះគន់ជាសាធារណៈក៏ដោយ រដ្ឋាភិបាលបានធ្វើសេចក្តីព្រាងច្បាប់ស្តីពីការដាក់ប្រទេសក្នុងភាពអាសន្នក្នុងគោលបំណងទប់ស្កាត់កូវីដ-១៩ ក្នុងករណីមានការរាតត្បាតមិនអាចគ្រប់គ្រងបាន។ លើសពីនេះ ការរឹតត្បិតការធ្វើដំណើរចូលស្រុកពីបណ្ដាប្រទេសដែលមានហានិភ័យខ្ពស់ត្រូវបានហាមឃាត់ ដើម្បីបញ្ឈប់រាល់ការចម្លងមេរោគនានាដែលអាចកើតឡើងក្នុងប្រទេស។
- ការអនុវត្តគម្លាតសង្គម ដើម្បីកាត់បន្ថយហានិភ័យនៃការផ្ទុះមេរោគកូវីដ-១៩ បានបង្កឱ្យមានផលអវិជ្ជមានសម្រាប់វិស័យអប់រំព្រោះថាសិស្សមិនអាចរៀននៅក្នុងសាលាបានទេ។ ក្រសួងអប់រំបានប្រមើឃើញពីបញ្ហានេះហើយបានឆ្លើយតបជាមួយនឹងកម្មវិធីអប់រំតាមប្រព័ន្ធអ៊ីនធឺណិត។ ក្រសួងអប់រំ ដោយសហការជាមួយក្រសួងព័ត៌មានបានផ្ដួចផ្ដើមកម្មវិធីសិក្សាពីចម្ងាយ និងសិក្សាតាមអេឡិចត្រូនិកដើម្បីផ្ដល់ការអប់រំជាមូលដ្ឋានដល់សិស្សគ្រប់ជាន់ថ្នាក់ក្នុងប្រទេសកម្ពុជាជាពិសេសអ្នកនៅតាមជនបទដែលពួកគេមិនអាចទទួលបានការភ្ជាប់អ៊ីនធឺណិត។ រដ្ឋាភិបាលក៏បានសហការជាមួយសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលដូចជាមូលនិធិអាស៊ី និងយូណេស្កូ ដើម្បីអនុវត្តកម្មវិធីរៀនតាមអេឡិចត្រូនិច និងបង្កើតគំនិតផ្ដួចផ្ដើមបច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីជួយសម្រួលដល់ការរៀនសូត្ររបស់សិស្សនៅផ្ទះ។[១៣]

---

១២. សេចក្ដីសម្រេចរាជរដ្ឋាភិបាល ស្ដីពីការរស់នៅតាមបែបគន្លងថ្មីឆ្នាំ ២០២១ ២០២៣

១៣. ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ សម្រាប់គម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ថ្ងៃទី ១៥ មិនា ឆ្នាំ ២០២០

### ៣.៣ ផលប៉ះពាល់ចំពោះសេដ្ឋកិច្ច-សង្គម

កម្ពុជាមានកម្រិតឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ត្រូវបានរកឃើញថាមានកម្រិតមធ្យម និងស្ថិតនៅក្រោមការគ្រប់គ្រងបាន តាមរយៈការឆ្លើយតបយ៉ាងទាន់ពេលប្រកបដោយស្មារតីប្រុងប្រយ័ត្ន បុរេសកម្ម និងទទួលខុសត្រូវខ្ពស់។ ក្នុងឆ្នាំ ២០២០ ជំងឺកូវីដ-១៩ បានបង្កនូវទុក្ខលំបាកដែលគ្រប់ដណ្តប់សឹងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវភាពរស់នៅរបស់ប្រជាជន និងបង្ខំអោយរោងចក្រ-សហគ្រាសទាំងក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធមួយចំនួន បិទអាជីវកម្ម និងផ្អាកដំណើរការ។ ដោយសារកម្ពុជាជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្ពស់ កម្ពុជាមិនអាចគេចរួចពីផលអវិជ្ជមានមកលើសង្គម សេដ្ឋកិច្ចនោះទេ ជាពិសេសចាប់តាំងពីត្រីមាសទី ២ នៃឆ្នាំ២០២០ ដែលជារលកនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានដាក់សម្ពាធយ៉ាងខ្លាំងមកលើសកម្មភាពពាណិជ្ជកម្ម ធុរកិច្ច និងវិនិយោគ។ វិស័យទេសចរណ៍ បានទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាងគេ ដោយសារការដាក់ចេញនូវវិធានការហាមឃាត់ការធ្វើដំណើរ ព្រមទាំងវិធានការផ្សេងៗទៀត។ នៅក្នុងឆ្នាំ ២០២០ កម្ពុជាទទួលបានភ្ញៀវទេសចរបរទេសត្រឹមប្រមាណជាង ១,៣១ លាននាក់ ប៉ុណ្ណោះ ពោលគឺធ្លាក់ចុះក្នុងអាត្រា -៨០,២% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩។

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានផ្លាស់ប្តូរសេដ្ឋកិច្ចពិភពលោកយ៉ាងខ្លាំង និងបានជះឥទ្ធិពលលើគ្រប់វិស័យ និងគ្រប់ផ្នែកនៃជីវិតនៅក្នុងបណ្តាប្រទេសជាច្រើន។ ប្រទេសកម្ពុជាក៏ទទួលរងផលប៉ះពាល់ពីជំងឺនេះដែរ។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់ជំងឺកូវីដ-១៩ នៅកម្ពុជាគឺធំធេងណាស់។ ផ្នែកនេះវិញ នឹងធ្វើការស្វែងយល់ពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ដល់ផ្នែកសង្គម ជាពិសេសនៅក្នុងវិស័យអប់រំ និងទៅលើជនជាតិដើមភាគតិច។ដើម្បីទទួលបានការអប់រំតាមប្រព័ន្ធអ៊ីនធឺណិត សិស្សត្រូវការប្រព័ន្ធអ៊ីនធឺណិតដែលមានស្ថេរភាពនិងឧបករណ៍បច្ចេកវិទ្យា។ តម្រូវការទាំងនេះបានពង្រីកគម្លាតវិសមភាពក្នុងចំណោមសិស្សនៅតំបន់ជនបទនិងទីក្រុង។ អ្នករស់នៅតំបន់ទីក្រុងប្រហែលជាអាចនឹងមានលទ្ធភាពទទួលបានការអប់រំតាមប្រព័ន្ធអ៊ីនធឺណិតប្រសើរជាង និងមានគុណភាពជាងអ្នករស់នៅតាមតំបន់ជនបទ។ សាលាឯកជនហាក់ដូចជាមានកម្មវិធី និងសម្ភារៈអប់រំតាមប្រព័ន្ធអ៊ីនធឺណិតប្រសើរជាង បើប្រៀបធៀបទៅនឹងសាលារដ្ឋដែលមិនគិតថ្លៃសិក្សា។ យោងតាមក្រសួងអប់រំ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ មានសិស្សប្រមាណចំនួន ២១០ ០០០ នាក់ បានសិក្សានៅតាមសាលាឯកជនចំនួន ១ ២២២ បើប្រៀបធៀបនឹងសិស្សសាលារដ្ឋវិញ មានចំនួន ៣,២ លាននាក់។ ភាគច្រើននៃសាលាឯកជនចំនួន ១ ២២២ ផ្តោតលើតំបន់ទីប្រជុំជន - មានតែសិស្សរស់នៅតាមជនបទសចំនួន ៣៥ ៥១១ នាក់ប៉ុណ្ណោះដែលសិក្សានៅសាលាឯកជន។ ពាក់កណ្តាលនៃសិស្សដែលមានលទ្ធភាពចូលរៀនតាមប្រព័ន្ធអ៊ីនធឺណិត ឬរៀនដោយខ្លួនឯងនៅផ្ទះ ចំណាយពេលតិចជាង ១០ ម៉ោងក្នុងមួយសប្តាហ៍ដើម្បីសិក្សា ដែលចំនួននេះស្មើនឹងប្រមាណតែពាក់កណ្តាលនៃពេលវេលាធម្មតារបស់ពួកគេដែលធ្លាប់សិក្សានៅក្នុងថ្នាក់រៀនតែប៉ុណ្ណោះ។ នៅតំបន់ខ្លះដែលមិនមានប្រព័ន្ធអ៊ីនធឺណិត ការអប់រំក្រៅផ្លូវការត្រូវបានអនុវត្តក្នុងកំឡុងពេលបិទទ្វារសាលារៀនដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ជំងឺរាតត្បាត

នេះក៏បានជះឥទ្ធិពលអវិជ្ជមានដល់សិស្ស និស្សិតដែលមានពិការភាពក្នុងការទទួលបានការអប់រំស្មើៗគ្នា ដោយសារកង្វះកម្មវិធីគាំទ្រពិការភាពនៅផ្ទះ។[១៤]

## ៣.៤ វិធានការដោះស្រាយស្ដីពីផលប៉ះពាល់ចំពោះសេដ្ឋកិច្ច-សង្គម

បណ្ដាលរដ្ឋាភិបាលជាច្រើននៅក្នុងសកលលោក បានដាក់ចេញវិធានការគោលនយោបាយចម្រុះ ក្នុងទំហំ និងទ្រង់ទ្រាយមិនធ្លាប់មានពីមុន ដើម្បីកាត់បន្ថយផលប៉ះពាល់ និងគាំទ្រសកម្មភាពសង្គម-សេដ្ឋកិច្ច សំដៅគាំពារជីវិតសង្គម និងរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងធុរកិច្ចជាពិសេសការរក្សានូវស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងស្មារតីបុរេសកម្ម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តនូវកញ្ចប់ វិធានការអន្តរាគមន៍ចំនួន ១០ជុំជាបន្តបន្ទាប់ ក្នុងគោលបំណងទ្រទ្រង់ និងស្តារសកម្មភាពអាជីវកម្ម និងធុរកិច្ច អោយងើបឡើងវិញ និងជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ ជាក់ស្ដែង រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិការប្រមាណ ៨២៩ លានដុល្លាអាមេរិច ក្នុងឆ្នាំ ២០២០ សម្រាប់អន្តរាគមន៍ ទាំងផ្នែកសុខាភិបាល សង្គម និងសេដ្ឋកិច្ច ហើយទំហំថវិកានេះបានកើនឡើងរហូតដល់ទៅ ១ ៥៥៤លាន ដុល្លាអាមេរិក ក្នុងឆ្នាំ ២០២១។

ជាលទ្ធផល កម្ពុជារក្សាបានលំនឹងជីវភាពប្រជាជន ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា ព្រមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងលក្ខណៈបន្ទាន់នៅតាម ការដ្ឋានចំបាច់នានា។ ជាក់ស្ដែងសម្រាប់ឆ្នាំ ២០២១ តាមការវាយតម្លៃពាក់កណ្ដាលឆ្នាំរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទោះបីជាមាន ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ សេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបាន អាត្រាកំណើន ២,៤% ដែលគាំទ្រដោយការងើបឡើងវិញនូវសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ច ដោយឆ្លុះបញ្ចាំង តាមរយៈ៖

១. ការរក្សាកំណើនល្អនៃការនាំចេញផលិតផលមិនមែនកាត់ដេរ ជាពិសេស អង្ករ និងផលិតផលកសិកម្ម ផ្សេងទៀតមានដូចជា កង់ គ្រឿងបង្គុំអេឡិចត្រូនិច ជាដើម

២. ការបន្តសកម្មភាពទិញ-លក់បុរី ផ្ទះល្វែងថ្លៃទាប និងមធ្យម ទ្រទ្រង់ដោយវិនិយោគក្នុងស្រុក

៣. ការបន្តកើនឡើងនូវឥណទានសម្រាប់វិស័យសំណង់ និងអចលនទ្រព្យ បើទោះបីជាមានការថមថយ យ៉ាងណាក្តី។[១៥]

---

១៤. ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១ ២០២៣ (ទំព័រទី ៣)

១៥. ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១ ២០២៣ (ទំព័រទី ៦)

**ភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា** ក្នុងបរិការណ៍នៃការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ កម្ពុជាមានឧត្តមភាពដែលជាភាពខ្លាំងមួយចំនួនដូចជា៖

ទី១. កម្ពុជាអាចកសាងសម្ថភាពវិស័យសុខាភិបាលបាន ដោយឆ្លើតតបយ៉ាងរហ័សទៅនឹងស្ថានភាពនៃវិបត្តិនេះ ព្រមទាំងសម្រេចបានអត្រានៃការចាក់វ៉ាក់សាំងក្នុងអត្រាប្រមាណ ៥៨,៦១% នៃប្រជាជនសរុបចំនួន ១៦លាននាក់ គិតត្រឹមថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០២១។

ទី២. ស្ថានភាពជញ្ជីងទូទាត់បន្តស្ថិតក្នុងស្ថានភាពល្អប្រសើដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកម្រិតទុនបម្រុងអន្តរជាតិខ្ពស់ ដែលមានចំនួនប្រហែង ២០ ប៊ីលានដុល្លារអាមេរិក គិតត្រឹមខែសីហា ឆ្នាំ ២០២១ ដែលអាចធានាការនាំចូលបានប្រមាណ ៨,៧ខែ។

ទី៣. លទ្ធផលនៃការប្រមូលចំណូលមានកម្រិតប្រសើរជាអ្វីដែលធ្លាប់បានប៉ាន់ស្មាន ដោយការប្រមូលចំណូលក្នុងស្រុកសម្រាប់ឆ្នាំ ២០២២ សម្រេចបានក្នុងរង្វង់ ២១,៨១% នៃផសស ទោះជាមានការដាក់ចេញនូវគោលនយោបាយបន្ធូបន្ថយពន្ធ ដើម្បីទ្រទ្រង់ដំណើរការអាជីវកម្មក្នុងអំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

ទី៤.ស្ថានភាពបំណុលសាធារណៈភាពល្អប្រសើរខណៈដែលកម្ពុជាមានលំហសម្រាប់កៀរគរហិរញ្ញប្បទាន ទាំងក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី ព្រមទាំងហិរញ្ញប្បទានពីក្នុងស្រុក។ ជាការវាយតម្លៃលើសូចនាករសំខាន់ៗ ស្ថានភាពបំណុលសាធារណៈកម្ពុជាបន្តមានចីរភាព និងស្ថិតក្នុងកម្រិតហានិភ័យទាប

ទី៥. សម្រាប់វិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលមួយផ្នែកធំជាវិស័យធនាគារ មិនបានបង្ហាញនូវសញ្ញាណណាមួយនៃហានិភ័យខ្ពស់នោះឡើយ ទោះបីជាបន្តស្ថិតនៅក្នុងបរិបទនៃវិបត្តិកូវីដ-១៩ ក៏ដោយ។ ជាក់ស្តែង សន្ទនីយភាពក្នុងធានាគារពាណិជ្ជ និងស្ថាបនមីក្រូហិរញ្ញវត្ថុ ស្ថិតក្នុងកម្រិតប្រសើរ ក្រោមការទទួលបានការអនុគ្រោះ និងការលើកទឹកចិត្តតាមរយៈវិធានការធនាគារជាតិនៃកម្ពុជាជាពិសេស វិធានការនៃការរៀបចំឥណទានឡើងវិញ។

ទី៦. វិស័យកសិកម្មនៅមានសក្តានុពលខ្ពស់ក្នុងការជួយទ្រទ្រង់សន្តិសុខស្បៀងអាហារ ជាពិសេសការគាំទ្រកំណើន និងការស្រូបយកអ្នកអត់ការងារធ្វើ។ ជាមួយគ្នានេះដែល រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគាំទ្រនានា និងការលើកទឹកចិត្តទាំងផ្នែកសារពើពន្ធ និងហិរញ្ញប្បទាន សំដៅជំរុញការវិនិយោគក្នុងវិស័យកសិកម្មអោយរីកចម្រើន។ ការណ៍នេះបានជួយអោយកម្ពុជាលើកកម្ពស់ផលិតផលកសិកម្មក្នុងស្រុកដើម្បីបំពេញតម្រូវការប្រើប្រាស់ និងបង្កើនការនាំចេញផលិតផលកសិកម្មបានកាន់តែច្រើន។

ទី៧. កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងទីផ្សារសកល, តំបន់ និងទ្វេភាគីជាពិសេស ការចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃភាពជាដៃគូរសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ( RCEP ) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង។ ជារួម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងនេះដើរតួជាកម្លាំងចលករដ៏សំខាន់សម្រាប់ការស្តារឡើងវិញ និងការជំរុញកំណើន

ប្រកបដោយចីរភាព សម្រាប់រយៈពេលវែង តាមរយៈការផ្តល់លទ្ធភាពកាន់តែទូទំទូកាយ សម្រាប់ការនាំចេញ និងការទាក់ទាញវិនិយោគបន្ថែមទៀតមកកម្ពុជា។

ទី៨. អត្រាចាប់យកបច្ចេកវិទ្យាឌីជីថល (Digital Adoption) ក៏មាននិន្នាការកើនឡើងយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ជាមួយគ្នានេះ កម្ពុជាមានសក្តានុពលខ្ពស់ក្នុងការក្តាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី ៤ និងសេដ្ឋកិច្ចឌីជីថល ដោយសារ (ក). ភាគលាភប្រជាសាស្ត្រ ដែលក្នុងនោះមានយុវជនដ៏ច្រើនដែលងាយទទួលយកបច្ចេកវិទ្យាឌីជីថល (ខ). និន្នាការកើនឡើងការប្រើប្រាស់ឧបករណ៍ឆ្លាតវៃ (គ) រំហូរវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យបច្ចេកវិទ្យា និង (ឃ). ឥទ្ធិពលដ៏លឿននៃឌីជីថូបនីយកម្មក្នុងគ្រប់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ជាពិសេសក្នុងបរិបទកូវីដ-១៩ ។

វិបត្តិកូវីដ-១៩ បានផ្តល់នូវមេរៀន និងបទពិសោធន៍ជាច្រើនដល់កម្ពុជាក្នុងការដោះស្រាយរៀបចំ និងដាក់ចេញនូវវិធានការគោលនយោបាយសំខាន់ៗ សម្រាប់ការកសាងសង្គម-សេដ្ឋកិច្ចមួយប្រកបដោយភាពរឹងមាំ និងបរិយាប័ន្ន នាពេលអនាគតដូចខាងក្រោម៖

មេរៀនទី១. ភាពងាយរងគ្រោះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាពីការប្រែប្រួលនៃស្ថានភាព និងតម្រូវការខាងក្រៅប្រទេស៖ កម្ពុជាត្រូវកសាងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចអោយបានលឿនបំផុត ក្នុងការពង្រឹងភាពធន់ និងវិបត្ត ដោយចាប់អោយបាននូវឧស្សាហកម្មសាល ដូចជា គ្រឿងបង្គុំអេឡិចត្រូនិក និងអគ្គិសនី ព្រមទាំងគ្រឿងបង្គុំយានយន្ត និងការដំឡើងយានយន្តដែលមានតម្លៃបន្ថែមខ្ពស់ ឧស្សាហកម្មមានសក្តានុពលផ្សេងទៀត ព្រមទាំងឧស្សាហកម្មដែលគាំទ្រ និងបម្រើអោយខ្សែច្រវ៉ាក់ផលិតកម្មនៅក្នុងតំបន់។

មេរៀនទី២. សំណាញ់សុវត្ថិភាពសង្គមជាឧបករណ៍អន្តរាគមន៍ដ៏មានប្រសិទ្ធភាពក្នុងការទ្រទ្រង់សុខមាលភាពសង្គមក្នុងពេលមានវិបត្តិ៖ ការណ៍នេះតម្រូវអោយមានការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំកសាង និងពង្រឹងសមត្ថភាព ព្រមទាំងយន្តការអនុវត្ត តាមដាន និងវាយតម្លៃ ការសម្របសម្រួលស្ថាប័ន ជាដើម ដើម្បីលើកកម្ពស់សំណាញ់សុវត្ថិភាពសង្គម រួមទាំងការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម អោយកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។

មេរៀនទី ៣. ភាពចាំបាច់ក្នុងការរៀបចំអោយមានឧបករណ៍គោលនយោបាយហិរញ្ញវត្ថុ និងហិរញ្ញវត្ថុសាធារណៈបន្ថែមទៀត៖ កម្ពុជានឹងពង្រឹងយន្តការសម្របសម្រួល ដើម្បីចែករំលែកព័ត៌មាន និងទិន្នន័យក៏ដូចជារៀបចំវិធានការឆ្លើយឆ្លងតប ព្រមទាំងលើកកម្ពស់សមត្ថភាពតាមដាន វិភាគ និងវាយតម្លៃស្ថានភាពសង្គម-សេដ្ឋកិច្ច និងសមត្ថភាពអនុវត្តវិធានការនានាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលក្នុងពេលមានវិបត្តិ ព្រមទាំងត្រៀម និងបង្កើតឧបករណ៍គោលនយោបាយសម្រាប់អន្តរាគមន៍ក្នុងពេលចាំបាច់។ ទន្ទឹមនេះ, កម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ពុំបានផ្តល់លក្ខខណ្ឌអំណោយផលដល់ការអនុវត្តគោល

នយោបាយរូបិយវត្ថុ ប្រកបដោយប្រសិទ្ធភាពពេញលេញក្នុងដំណាក់កាល ដែលកម្ពុជាត្រូវការគោលនយោបាយរូបិយវត្ថុ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

មេរៀនទី៤. សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួនច្រើនដែលបង្កផលវិបាកកាន់តែខ្លាំងក្នុងពេលមានវិបត្តិ៖ ដោយកម្ពុជាមានអាជីវកម្ម និងធុរកិច្ចជាច្រើន ដែលមិនបានចុះបញ្ជីជាផ្លូវការ ជាពិសេសសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម រាជរដ្ឋាភិបាលមានការលំបាកក្នុងការជួយអោយបានទាន់ពេល និងគ្រប់ជ្រុងជ្រោយ ដោយសារកង្វះទិន្នន័យ និងសូចនាករសំខាន់ៗ ដូចជាព័ត៌មានអាជីវកម្ម ការចុះបញ្ជី និងការងារជាដើម។

មេរៀនទី៥ ប្រាក់សន្សំរាជរដ្ឋាភិបាល ជាប្រភពហិរញ្ញប្បទានដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានានា ក្នុងអំឡុងពេលមានវិបត្តិ៖ ប្រាក់សន្សំដែលសម្រេចបានមុនពេលមានវិបត្តិ បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវកម្មវិធីអន្តរាគមន៍សង្គម-សេដ្ឋកិច្ចសំខាន់ៗ សំដៅជួយសម្រួលបន្ទុកជីវភាពប្រជាពលរដ្ឋ និងកម្មករ-និយោជិត ព្រមទាំងរក្សាលំនឹងពាណិជ្ជកម្ម។ ការណ៍នេះទាមទារអោយរាជរដ្ឋាភិបាលបន្តផ្តោតការគិតគូរលើការរៀបចំនូវឧបករណ៍គោលនយោបាយ សម្រាប់កៀរគរហិរញ្ញប្បទាន ដែលមានមុខងារប្រតិបត្តិរហ័ស និងមានសក្តានុពលភាពនៅលើទីផ្សារ ដើម្បីធានានិរន្តភាពនៃការអភិវឌ្ឍទាំងក្នុងពេលធម្មតា និងពេលមានវិបត្តិ។

មេរៀនទី២. ប្រព័ន្ធពន្ធត្រូវតែបន្តអភិវឌ្ឍអោយមានលក្ខណៈទំនើប រឹងមាំ និងឆ្លើយតបខ្ពស់ទៅនិងស្ថានភាពសង្គម-សេដ្ឋកិច្ច ដែលជារួមអាចចូលរួមជួយសម្រាលផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ភាពជឿទុកចិត្តៈ អំឡុងពេលវិបត្តិកូវីដ-១៩ យន្តការពន្ធត្រូវបានអនុវត្ត និងមានដំណើរការល្អប៉ុន្តែមិនមានការដាក់សម្ពាធពន្ធដល់ប្រជាពលរដ្ឋ និងធុរជន សំដៅចូលរួមជួយសម្រួលបញ្ហាលំហូរសាច់ប្រាក់ និងដំណើរការអាជីវកម្ម ក៏ដូចជាជំរុញសកម្មភាពសេដ្ឋកិច្ច។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជំងឺកូវីដ-១៩ នៅតែបន្តជាបញ្ហាប្រឈមផ្នែកប្រព័ន្ធសុខាភិបាលសាធារណៈ និងសុខមាលភាពប្រជាជន ក៏ដូចជាសកម្មភាពសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីការពារអាយុជីវិតប្រជាជន និងជំរុញដំណើរការសកម្មភាពសង្គមសេដ្ឋកិច្ច, ពាណិជ្ជកម្ម និងការធ្វើដំណើរ ការការពារកម្ពុជាអោយចៀសផុតពីលេកថ្មីៗក៏ដូចជាមេរោគបំប្លែងថ្មីៗ ជាពិសេស ការបើកដំណើរការសង្គម-សេដ្ឋកិច្ចឡើងវិញប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ បុរេសកម្ម និងការថ្លឹងថ្លែងច្បាស់លាស់ គឺជាគោលដៅអាទិភាពចំពោះមុខក្នុងបរិបទកូវីដ-១៩ ។

ក្នុងបរិបទកូវីដ-១៩ នេះសម្រាប់ដំណាក់កាលចំពោះមុខ និងរយៈពេលខ្លីរាជរដ្ឋាភិបាលនៅតែបន្តពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាល សមត្ថភាពព្យាបាលចំពោះអ្នកជំងឺកូវីដ-១៩ ដែលមានភាពធ្ងន់ធ្ងរ ក៏ដូចជាសមត្ថភាពនៃប្រព័ន្ធអង្កេត តាមដាន រាយការណ៍ និងការឆ្លើយតប។

ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតអោតបាននូវភាពស៊ាំសហគមន៍នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា គឺជាវិធានការយុទ្ធសាស្ត្រគន្លឹះដ៏មានប្រសិទ្ធភាពមួយ ដែលត្រូវអនុវត្តគួបផ្សំជាមួយនឹងវិធានការចាំបាច់ផ្សេងទៀត ជាពិសេសវិធានការ ៣-កុំ និង ៣-ការពារ ដើម្បីធានាអោយកម្ពុជាអាចបន្តដំណើរអភិវឌ្ឍន៍ទៅមុខលើគន្លងនៃប្រក្រតីភាពថ្មី ។ ដោយឡែកគិតត្រឹម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ប្រទេសកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ដល់ប្រជាពលរដ្ឋដែលមានអាយុពី ១៨ឆ្នាំឡើងបានចំនួន ៧ ០៤៣ ៩៦៩នាក់ ឬស្មើនឹង ៧០,៤៤% និងដូសទី២ បាន ៤ ៦២៦ ៦៤៨នាក់ ឬស្មើនឹង ៤៦,២៦% នៃប្រជាពលរដ្ឋគោលដៅ ១០លាននាក់។ គួរកត់សម្គាល់ថា ០,៩៥% នៃប្រជាពលរដ្ឋ ៧ ០៤៣ ៩៦៩នាក់ ដែលបានស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនត្រូវបានគ្រូពេទ្យអោយចាក់វ៉ាក់សាំងដោយសារបញ្ហាសុខភាពផ្ទាល់ខ្លួន។ រីឯផលរំខានដែលបានកើតឡើងក្រោយពេលចាក់វ៉ាក់សាំងមានចំនួន ១៥៥ករណី ក្នុងចំណោម វ៉ាក់សាំងដែលបានចាក់សរុប ៥ ៧៩៦ ១៦៤ដូស (សរុបដូសទី១ និងដូសទី២) ឬក្នុងអត្រា ២ករណី ផលរំខានក្នុងវ៉ាក់សាំង ១០០ ០០០ដូស គិតត្រឹមថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២១។ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនអាចផ្តាច់ការចម្លងបានទាំងស្រុងក៏ដោយ ក៏ការចាក់វ៉ាក់សាំងពេញលេញត្រូវបានរំពឹងទុកថា ជួយកាត់បន្ថយការឆ្លងបានមួយកម្រោត ដោយសារបានចាក់វ៉ាក់សាំងដែលអាចកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ និងការសម្រាកព្យបាលនៅមន្ទីរពេទ្យ យោងតាមរបកគំហើញនៃការសិក្សាអំពីប្រសិទ្ធិភាពនៃវ៉ាក់សាំង និងបណ្តាលប្រទេសមួយចំនួន។

ជាមេរៀន និងបទពិសោធន៍នៃការគ្រប់គ្រង ការកាត់បន្ថយការឆ្លងរាលដាលអោយនៅកម្រិតអប្បបរមា និងការការពារសុវត្ថិភាពសាធារណៈ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដែលមានភាពធន់ខ្ពស់ និងអាចឆ្លើយតបបានយ៉ាងរហ័ស។ ដើម្បីកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ចមួយដែលរឹងមាំ ជាពិសេស ការគាំពារផ្នែកហិរញ្ញវត្ថុ ការការពារផ្នែកសុខភាព និងការធានាការទទួលបានសេវាសុខភាពប្រកបដោយគុណភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប រាជរដ្ឋាភិបាលនឹងគិតគូរជាសំខាន់លើការសម្រេចបាននូវ

ការគ្រប់ដណ្តប់សុខភាពជាសកល សំដៅធានាអោយប្រជាពលរដ្ឋគ្រប់រូបទទួលបានដោយសមធម៌ នូវសេវាសុខភាពប្រកបដោយគុណភាពព្រមទាំងបន្តពង្រឹងលើប្រព័ន្ធសុខាភិបាល ទាំងលើគុណភាព ហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំយន្តការត្រៀមខ្លួនឆ្លើយតបទៅនិងហានិភ័យសុខភាពសាធារណៈនៅពេលអនាគត។

ឈរលើទស្សនាទានរួមមួយ តាមរយៈក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១- ២០២៣ រាជរដ្ឋាភិបាលមានចក្ខុវិស័យ **ពង្រឹងការកសាងមាគ៌ា និងជីវភាព នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពរឹងមាំ និងចាប់យកកាលានុវត្តភាព ទាំងក្នុងនិងក្រៅប្រទេស ដើម្បីកែលម្អមូលដ្ឋានសេដ្ឋកិច្ចជាតិអោយមានភាពប្រកួតប្រជែង និងពិពិធកម្មខ្ពស់ ព្រមទាំងលើកកម្ពស់សុខមាលភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាអោយស្របទៅនឹងប្រក្រតីភាពថ្មីនៃការអភិវឌ្ឍ។**

# អនុសាសន៍

# អនុសាសន៍

ជាចុងក្រោយនេះ ក្នុងខ្ញុំជាប្រជាពលរដ្ឋមួយរូប និងជាសិស្សនិស្សិតមួយរូប សូមសំណូមពរក៏ដូចជាអនុសាសន៍មួយចំនួនដើម្បីចូលរួមចំណែកក្នុងការជំរុញឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលនូវជំងឺឆ្លងផ្សេងៗនឹងការយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងរាជរដ្ឋាភិបាល ក្នុងករណីដែលអាចមានបញ្ហាផ្សេងៗដែលពាក់ព័ន្ធជាមួយវិស័យសុខាភិបាល ដែលអាចកើតមាននៅពេលអនាគតដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិនៅខាងក្រោមៈ

- ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងផ្នែកវិស័យសុខាភិបាលឲ្យកាន់តែរឹងមាំ នឹងមានការបណ្តុះបណ្តាលបន្ថែមលើជំនាញផ្សេងៗដែលពាក់ព័ន្ធជាមួយនឹងជំងឺអាសន្នរោគ វិធីសាស្ត្រក្នុងការព្យាបាលការប្រើប្រាស់ឱសថ និងនិងការថែទាំអ្នកជំងឺតាមកម្រិត។
- ពង្រីកវិសាលភាពការគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលនៅថ្នាក់មូលដ្ឋានឲ្យមានលក្ខណៈល្អប្រសើរដូចនិងថ្នាក់ជាតិដែរ
- ការធានាឲ្យបាននូវការផ្តល់សេវាសាធារណៈផ្នែកវិស័យសុខាភិបាលប្រកបដោយប្រសិទ្ធភាពគុណភាពខ្ពស់និងឆ្លើយតបទាន់ពេលវេលាទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន
- ត្រៀមខ្លួនរួចជាស្រេចក្នុងការទប់ទល់នឹងជំងឺរាតត្បាតផ្សេងៗដែលអាចកើតមាន ទាំងប្រភេទនាំចូលពីក្រៅស្រុកដើម្បីឆ្លើយតបឲ្យទាន់ពេលវេលា
- ការបង្កើនសមត្ថភាពផ្សព្វផ្សាយព័ត៌មានខាងផ្នែកវិស័យសុខាភិបាលជូនដល់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយតាមរយៈសារអេឡិចត្រូនិកកាសែតទស្សនាវដ្តីជាដើម
- ពង្រឹងយន្តការអភិបាលកិច្ចក្នុងវិស័យសុខាភិបាលអោយមានប្រសិទ្ធភាពគឺមានសារៈសំខាន់យ៉ាងក្រោយឡើងសម្រាប់ការផ្តល់សេវាសុខាភិបាលប្រកបដោយសមធម៌និងមានគុណភាពដោយឈរលើគោការណ៍គណនេយ្យភាពសង្គម។ក្នុងវិស័យសុខាភិបាលពាក់ព័ន្ធនឹងការមានក្របខណ្ឌនយោបាយដែលផ្សារភ្ជាប់ជាមួយនឹងតួនាទីត្រួតពិនិត្យមានប្រសិទ្ធភាពដើម្បីដឹកនាំនិងគ្រប់គ្រងវិស័យសុខាភិបាលទាំងមូល។
- មើលរឿងរចនាសម្ព័ន្ធនិងសមត្ថភាពស្ថាប័នក្នុងការធានារ៉ាប់រងគុណភាពនៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាលដែលផ្តល់ទៅលើការអភិវឌ្ឍបមាណីយគុណភាពការត្រួតពិនិត្យតាមដាននិងការគ្រប់គ្រងគុណភាពនិងស្ថិរភាពនិយ័តកម្ម
- ពង្រឹងតួនាទីរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល អនុគណៈកម្មការនៃក្រុមការងារបច្ចេកទេសសុខាភិបាលនិងក្រុមការងារបច្ចេកទេសសុខាភិបាលរាជធានីខេត្ត ក្នុងគោលបំណងពង្រីកការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋានឲ្យបានគ្រប់ជ្រុងជ្រោយ

ជាពិសេសពាក់ព័ន្ធជាមួយនឹងការការពារនិងការទប់ស្កាត់នូវជំងឺឆ្លងផ្សេងៗដែលអាចកើតមាននៅថាអនាគត

- ភាពជាដៃគូផ្នែកសេវាសុខាភិបាលសាធារណៈ ជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសុខាភិបាលជូនដល់ប្រជាពលរដ្ឋនិងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សសុខាភិបាលដោយឈរលើមូលដ្ឋានសមត្ថភាពគ្រប់គ្រងនិងបច្ចេកទេស
- ពង្រឹងយន្តការក្នុងការត្រួតពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលនៅគ្រប់រចនាសម្ព័ន្ធសុខាភិបាលចាប់ពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់រាជធានីខេត្ត
- បង្កើនការផ្តល់ព័ត៌មានឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ដូចជាព័ត៌មានស្តីពីប្រភេទសេវាដែលអាចប្រើប្រាស់បាននៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកទំនាក់ទំនងក្នុងករណីត្រូវការសង្គ្រោះបន្ទាន់និងប្រភេទសេវានឹងកញ្ចប់សេវាព្យាបាលពាក់ព័ន្ធមួយជំងឺរាតត្បាតផ្សេងៗ
- ស្នើសុំដល់រាជរដ្ឋាភិបាលពង្រីកឱកាសក្នុងការទទួលបានចំណេះដឹងផ្សេងៗ ពាក់ព័ន្ធជាមួយវិស័យសុខាភិបាលជាមួយដៃគូអង្គការក្រោយរាជរដ្ឋាភិបាល និងភាពជាដៃគូនៅតាមបណ្តាប្រទេសផ្សេងៗ ដែលអនុញ្ញាតឱ្យសិស្សនិស្សិតទទួលបានឱកាសរៀនសូត្របន្ថែមពាក់ព័ន្ធជាមួយនឹងបច្ចេកទេសថ្មីៗរបស់វិស័យសុខាភិបាល
- ពង្រឹងយន្តការយុទ្ធសាស្ត្រភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយក្រសួងសុខាភិបាលក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពគុណភាពនិងគណនេយ្យភាព។

# គន្ថនិទេស

## គន្ថនិទ្ទេស

### ១. លិខិតបទដ្ឋានគតិយុត្ត

- ➢ សេចក្តីសម្រេចរាជរដ្ឋាភិបាល ការរស់នៅតាមបែបគន្លងថ្មីឆ្នាំ ២០២១ ២០២៣
- ➢ ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យអាយុពី ១២ ឆ្នាំទៅក្រោម ១៨ឆ្នាំ ខែកក្កដា ឆ្នាំ ២០២១
- ➢ សេចក្តីណែនាំស្តីពី ការអនុវត្តន៍យុទ្ធនាការជាតិ ក្រោមប្រធានបទ **រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩** ០២ សីហា ២០២១
- ➢ ក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣ ខែធ្នូ ឆ្នាំ ២០២១
- ➢ សេចក្តីណែនាំ ស្តីពីការផ្តល់សេវាគាំពារមាតានិងទារកក្នុងអំឡុងពេលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ឆ្នាំ ២០២០
- ➢ ច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោតគ្រោះថ្នាក់
- ➢ ប្រព័ន្ធសុខាភិបាល
- ➢ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ សម្រាប់គម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ថ្ងៃទី ១៥ មិនា ឆ្នាំ ២០២០

### ២. ឯកសារយោះពុម្ភ

- ➢ នីតិវិធីស្តង់ដារស្តីពី យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ខែមិថុនា ឆ្នាំ ២០២១
- ➢ នីតិវិធីស្តង់ដារ ស្តីពី ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគជំងឺកូវីដ-១៩ នៅមូលដ្ឋានសុខាភិបាល និងកន្លែងថែទាំអ្នកជំងឺនៅកម្ពុជា ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២០
- ➢ ការគ្រប់គ្រងច្រក-ចេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០២១
- ➢ សេចក្តីណែនាំបន្ថែម ដើម្បីឆ្លើយតបនឹងការវិវត្តថ្មីនៃសភាពការណ៍នៃការរាលដាលនៃជំងឺកូវីដ-១៩
- ➢ របាយការសមិទ្ធផលសុខាភិបាលឆ្នាំ ២០១៨ និងទិសដៅឆ្នាំ ២០១៩
- ➢ ផែនការយុទ្ធសាស្រ្តសុខាភិបាល ២០១៦-២០២០

### ៣. គេហទំព័រ

- ➢ www.who.int
- ➢ http://moh.gov.kh
- ➢ www.phnompenh.gov.kh
- ➢ http://www.cdcmoh.gov.kh/quarantine/vaccination-requirement

- Ministry of Health – Ministry of Health ( moh.gov.kh )
- ទីស្តីការគណៈរដ្ឋមន្ត្រី – OCM
- ខេមបូចា ព័ត៌មាន ( cambojanews.com )

# ឧបសម្ព័ន្ធ




( ១. សកម្មភាពក្រុមមន្ត្រីរដ្ឋាភិបាលក្នុងការបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ )



( ២. សកម្មភាពក្រុមមន្ត្រីរដ្ឋាភិបាលក្នុងការបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ )



( ៣. សកម្មភាពក្រុមមន្ត្រីសុខាភិបាលប្រមូលសំណាក ប្រជាពលរដ្ឋ )



( ៣. សកម្មភាពក្រុមមន្ត្រីសុខាភិបាលប្រមូលសំណាក ប្រជាពលរដ្ឋ )



( ៤. វ៉ាក់សាំងកូវីដ-១៩ )



( ៥. សកម្មភាពក្រុមសុខាភិបាលចាក់វ៉ាក់សាំងកូវីដ-១៩ )




( ៦. សកម្មភាពក្រុមមន្ត្រីសុខាភិបាល ពិនិត្យសុខាភាពមុនពេលចាក់វ៉ាក់សាំង )




( ៧.ការចាក់វ៉ាក់សាំង )